

## សុខាភិយាចនគាថា

**ពុទ្ធំសុមាលី ទិបទុត្តមោ តមោ**
**ហន្ត្វាន ពោធេសិធ បព្ពតំ គតំ**
**មគ្គគ្គសេលម្ហិ សុខុដ្ឋិតោ ឋិតោ**
**សោ មំ ចិរំ បាតុ សុខំ សទា សទា ។**

ព្រះពុទ្ធដូចអាទិត្យ ឧត្តមពិតជាងពួកជន
កំចាត់នូវមោហន្ធ ហើយចេញចាកសព្វកិលេស ។
ទ្រង់ឋិតនៅលើភ្នំ ដ៏ឧត្តមមគ្គវិសេស
ជាស់សត្វជាប់កិលេស ឲ្យភ្លឺថៃសក្នុងលោកា ។
សូមទ្រង់ប្រោសគ្រប់គ្រង យើងខ្ញុំផងរាល់វេលា
ឲ្យបានសុខគ្រប់គ្នា អស់កាលយូរអង្វែងទៅ ។

សម្រាប់ជាធម្មទាន

បែបរៀនភាសាបាលី ភាគទី ៣

ព.ស. ២៥៥៩

ប្រាក់ ឃុន

# បែបរៀនភាសាបាលី

## ភាគទី ៣

### វិធីទំនើបសម្រាប់រៀន និង បង្រៀនភាសាបាលី
### នៅកំរិតពុទ្ធិកបឋមសិក្សា


រៀបរៀងដោយ
ខ្ញុំព្រះករុណា អាត្មាភាព
**ធម្មបាលោ ប្រាក់ ឃុន**


កំណែលម្អជាថ្មី

ព.ស. ២៥៥៩ គ.ស. ២០១៥



# ធម្មបាលោ ប្រាក់ ឃុន

## ព្រះជន្មាយុ ៨៩ ឆ្នាំ

## កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

# បែបរៀនភាសាបាលី

## ភាគទី ៣

### វិធីថ្មីសម្រាប់រៀន និងបង្រៀនភាសាបាលី

### នៅកំរិតពុទ្ធិកបឋមសិក្សា

រៀបរៀងដោយ

ធម្មបាលោ ប្រាក់ ឃុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

បានពិនិត្យផ្ទៀងផ្ទាត់សារជាថ្មី

នៅវត្តព្រះគន្លង្កុដិ ខេត្តបាត់ដំបង

ព.ស. ២៥៥៩ គ.ស. ២០១៥

ឈ្មោះសៀវភៅ : បែបរៀនភាសាបាលី ភាគទី ៣

រៀបរៀងដោយ : ធម្មបាលោ ប្រាក់ យុន

កិត្តិបណ្ឌិតភាសាបាលី សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យ

ផ្នែកអក្ខរាវិរុទ្ធ

ភិក្ខុ ញាណកោសល បណ្ឌិត យ៉ន សេងយៀត

ព្រះសាកលវិទ្យាធិការរង ព.ស.ស ភ្នំពេញ

ភិក្ខុ ចូឡវរធម្មោ ហ៊ី ជីភៅ : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ ជោតបញ្ញោ ជឹម សុវណ្ណដា : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ យសបាលោ ជ័យ សុហុន : វិនយាចារ្យ និងធម្មាចារ្យ

ភិក្ខុ នាគទីបោ នាគ ទី : សមណសិស្ស

ផ្នែកកុំព្យូទ័រ

កោវិទោ ឡោះ សុវៀត

បោះពុម្ពលើកទី២ : ព.ស. ២៥៥៩ គ.ស. ២០១៥

# កំណែលម្អជាថ្មី

សៀវភៅ បែបរៀនភាសាបាលី ភាគទី ១ ដល់ភាគទី ៥ និងបាលីវេយ្យាករណ៍ ១ ក្បាល ដែលជាស្នាដៃរបស់ខ្ញុំព្រះករុណា អាត្មាភាព **ធម្មចារោ ប្រាក់ ឃុន** កំពុងតែចរាចរ ទៅក្នុងប្រទេសនិងក្រៅប្រទេស អមដំណើរដោយសម្លេងបង្រៀនវេយ្យាករណ៍ និងប្រែធម្មបទ - មង្គល - វិសុទ្ធិមគ្គ - នៅក្នុងខ្សែអាត់ និង ឌិសផង ដើម្បីឲ្យសិក្ខាកាមជាប់ចិត្តជិតអារម្មណ៍ ខំសិក្សារៀនសូត្រភាសាបាលីតរៀងទៅ ។

ដើម្បីសម្រួលដល់ការចង់ចេះដឹងភាសាបាលី របស់ព្រះសង្ឃ គ្រហស្ថ និងដើម្បីរក្សាវប្បធម៌មរតអក្សរសាស្ត្រខ្មែរ ឲ្យគង់វង្សនិងរីកចំរើនតរៀងទៅ ។

ខ្ញុំព្រះករុណា អាត្មាភាព និងព្រះសង្ឃវត្តព្រះគន្ធកុដិខេត្តបាត់ដំបង ជួយឧបត្ថម្ភ ព្រមទាំងសមណនិស្សិត សិស្សនៅខេត្ត ក្រុងដទៃទៀត ជួយឧបត្ថម្ភ **កំណែលម្អជាថ្មី** ធ្វើឲ្យ "បែបរៀនភាសាបាលី" ឲ្យមានភាពសុក្រឹត្យប្រសិទ្ធភាពពិត

ប្រាកដជាមូលដ្ឋាន នៃវប្បធម៌ព្រះពុទ្ធសាសនា និងអក្សរសាស្ត្រខ្មែរ រុងរឿង ស្ថិតស្ថេរចេរកាលយូរអង្វែងតរៀងទៅ ។

សូមថ្លែងអំណរគុណយ៉ាងប្រសើរបំផុត ចំពោះ សាស្ត្រាចារ្យ វិនយាចារ្យ ធម្មាចារ្យ និស្សិត សិស្ស ដែលបានជួយឧបត្ថម្ភតាមសមត្ថភាពគ្រប់ព្រះអង្គ ជួយផ្ដល់យោបល់ និងជួយកែតម្រូវ ដើម្បីធ្វើឲ្យសៀវភៅនេះ រឹងរឹតតែល្អប្រសើរឡើងទៀត ។

សូមអនុមោទនាយកផលានិសង្សនៃមហាធម្មទាន បានសម្រេចមគ្គ ផល ដល់ព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

វត្តព្រះគន្ធកុដិ ថ្ងៃ ១២ រោច ខែ ភទ្របទ ព.ស. ២៥៥៩ / គ.ស. ២០១៥

**អ្នករៀបរៀង**

**ធម្មបាលោ ប្រាក់ ឃុន**

# បុព្វកថា

នាងខ្ញុំមានសេចក្តីរីករាយ ចំពោះការសរសេរបុព្វកថានេះ ។ គឺឯកឧត្តម ឈន អៀម, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធសាសនបណ្ឌិត្យ, ដែលបានប្រាប់អោយនាងខ្ញុំដឹងមុនគេ ចំពោះហេតុដែលថា ការរៀនភាសាបាលីនៅកម្ពុជា ត្រូវបានប្រព្រឹត្តទៅតាមការរៀនសូធ្យចាំមាត់, ហើយដោយហេតុនេះ ត្រូវការយ៉ាងបន្ទាន់អោយមានការផ្លាស់ប្តូរក្នុងវិធីបង្រៀន ។ ការនិយាយប្រាប់នេះ បានកន្លងទៅពីរឆ្នាំហើយ តាំងពីពេលដែលនាងខ្ញុំកំពុងធ្វើការជាមួយអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជាម្ល៉េះ ។

ក្រោយពេលនាងខ្ញុំបានមកធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ នាដើមឆ្នាំ ១៩៩៦, ឯកឧត្តម ដោក ណារិន, អនុរដ្ឋលេខាធិការ ទទួលបន្ទុកពុទ្ធិកសិក្សា បានធ្វើសំណូមពរអោយនាងខ្ញុំជួយឧបត្ថម្ភថវិកាដល់កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លីសម្រាប់គ្រូបង្រៀនភាសាបាលី ជិត ២៥០ នាក់ ដែលមិនធ្លាប់បានទទួលការបណ្តុះបណ្តាលដ៏សមស្រប ។ នាងខ្ញុំបានឆ្លៀតយកឱកាសនោះ ពិនិត្យមើលសៀវភៅវេយ្យាករណ៍បាលីដែលមានស្រាប់ ហើយសរសេរជាភាសាខ្មែរ ។ ឯកឧត្តម ដោក ណារិន ក៏បានប្រាប់អោយនាងខ្ញុំដឹងផងដែរ អំពីសំណៅមេរៀនភាសាបាលីបែបថ្មីមួយ រៀបរៀងឡើងដោយលោក ប្រាក់ ឃុន ដែលមិនទាន់បានបោះពុម្ពផ្សាយនៅឡើយ ។ នៅក្នុងសំណៅនោះ នាងខ្ញុំបានមើលឃើញមានសក្តានុពល ដែលអាចនាំទៅកាន់ការធ្វើអោយមេរៀនភាសាបាលីបានត្រឹមត្រូវ ប្រកបដោយវិធីបង្រៀនទំនើប ។ នាងខ្ញុំ បានអង្គុយប្រជុំជាមួយលោក ប្រាក់ ឃុន និងក្រុមគ្រូបង្រៀនបាលីមកពីក្រសួងធម្មការ និងសាសនា និងមកពីពុទ្ធសាសនបណ្ឌិត្យ, ហើយបានណែនាំ

អស់លោកទាំងនោះ អំពីវិធីទំនើបបង្រៀនភាសាដល់អ្នករៀនដំបូង តាមរយៈការការតែងជាឃ្លាប្រយោគ ។ ដ៏ជាទិដ្ឋភាពមួយដែលខ្វះនៅក្នុងមេរៀនភាសាបាលីបច្ចុប្បន្ន ក្នុងប្រទេសកម្ពុជា ។ នេះគឺជាវិធីដែលព្រះតេជព្រះគុណ សាស្ត្រាចារ្យ អ.ប. ពុទ្ធទត្តៈ មហានាយកត្ថេរ នៃប្រទេសស្រីលង្កា ធ្លាប់បានប្រើនៅក្នុងសៀវភៅ « The New Pali Course » ( វិជ្ជាសិក្សាភាសាបាលិ បែបថ្មី ) បោះពុម្ពផ្សាយជាភាសាអង់គ្លេស ក្នុងឆ្នាំ ១៩៣៧ ដែលនាងខ្ញុំធ្លាប់បានសិក្សា និងធ្លាប់បានបង្រៀននៅក្នុងប្រទេសស្រីលង្កា និងនៅក្នុងប្រទេសអង់គ្លេសផងដែរ ។

បាលី ឬ មាគធី, ដូចដែលគេធ្លាប់ហៅពីកាលនោះ, គឺជាភាសាដែលព្រះពុទ្ធតែងបានប្រើសម្រាប់ទេសនា នៅក្នុងសតវត្សទី ៦ មុនគ្រិស្តសករាជ នៅក្នុងប្រទេសស្រីលង្កា ។ ចាប់តាំងពីពេលនោះមក អដ្ឋកថាព្រះត្រៃបិដកជាច្រើន, អត្ថបទស្តីពីទស្សនវិជ្ជាពុទ្ធសាសនាជាច្រើន, ក៏ដូចជាអត្ថបទផ្លូវលោកទាំងឡាយផងដែរ ត្រូវបានគេសរសេរជាភាសាបាលី នៅក្នុងប្រទេសឥណ្ឌា និងនៅក្នុងប្រទេសកាន់ពុទ្ធសាសនាថេរវាទ ដូចជា ស្រីលង្កា, ភូមា, សៀម, និងកម្ពុជា ។ ជាងនេះទៀត កាលណាបព្វជិតទាំងឡាយមកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ បាននិមន្តទៅកាន់ប្រទេសកាន់ពុទ្ធសាសនាថេរវាទមួយទៀត កាលពីអតីតកាល, ភាសាបាលី គឺជាភាសាអន្តរជាតិ ដែលបព្វជិតទាំងនោះបានប្រើ សម្រាប់ប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ថ្វីបើភាសាបាលិ មិនត្រូវបានប្រជាជននិយាយក៏ដោយ, ក៏ភាសានេះ នៅតែជាភាសារួមរហូតមកដល់សព្វថ្ងៃនៅឡើយ, ដែលតាមរយៈភាសានេះ បព្វជិតពុទ្ធ. សាសនិកពីប្រទេសកាន់ពុទ្ធសាសនាថេរវាទ តែងប្រាស្រ័យឆ្លើយឆ្លងគ្នា ។ ជាឧទាហរណ៍ បព្វជិតមកពីស្រីលង្កា, កាលណាលោកនិមន្តទៅកាន់ប្រទេសថៃ, តែងសន្ទនាជាមួយបព្វជិតថៃ ជាភាសាបាលិ ។ ដោយហេតុនេះ ការរៀនភាសាបាលី តាមរយៈការតែងជាឃ្លា . ប្រយោគ ជួយសម្រួលដល់ការសន្ទនា, បន្ថែមទៅលើការយល់

អត្ថបទជាភាសាបាលី ពីបុរាណកាលទៀតផង ។

សៀវភៅ « វិជ្ជាសិក្សាភាសាបាលី » នេះ គឺជាតម្រុយមួយ នៅក្នុងប្រទេសកម្ពុជា ពីព្រោះ នេះគឺជាការខិតខំមួយជាលើកដំបូង ដើម្បីបង្រៀនបាលីដល់អ្នករៀនដំបូង តាមរយៈការតែងជាឃ្លា-ប្រយោគ ។ នាងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោក ប្រាក់ ឃុន និងចំពោះក្រុមគ្រូបង្រៀនបាលីដែលបានធ្វើការយ៉ាងនឿយហត់ ដើម្បីបង្កើតឡើងនូវសៀវភៅនេះ, ព្រមទាំងអំណរគុណចំពោះសម្ដេចព្រះមង្គលទេពាចារ្យ អ៊ុម ស៊ុម, អគ្គាធិការនៃពុទ្ធិក-សិក្សា, ចំពោះព្រះពុទ្ធឃោសាចារ្យ ហេង លាងហោ , នាយកពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, និងចំពោះសម្ដេចព្រះធម្មលិខិត លាស់ ឡាយ ព្រះចៅអធិការវត្តសន្សំកុសល, ទីក្រុងភ្នំពេញ, ដែលបានពិនិត្យយ៉ាងល្អិតល្អន់នូវសំណៅចុងក្រោយ ។ នៅទីអវសាន, នាងខ្ញុំ សូមថ្លែងអំណរគុណ លោក ឱម ខែម, នាយកពុទ្ធសាសន-បណ្ឌិត្យ ដែលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ធ្វើអោយសៀវភៅនេះ សម្រេចបោះពុម្ពបាន ។

បណ្ឌិត *ហេម៉ា គូណាតិលកេ*

ពុទ្ធសាសនបណ្ឌិត្យ

ក្រសួងធម្មការ និង សាសនា

លេខ : 672 / 96 ក.ធ.ស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតបង្គាប់ការ

មន្ត្រីរាជការ នៃក្រសួងធម្មការ និង សាសនា ដូចមានរាយនាមខាងក្រោមនេះ ត្រូវបានចាត់តាំងឱ្យទៅពិនិត្យ និងសម្រេចបោះពុម្ពសៀវភៅសិក្សា « បាលីវេយ្យាករណ៍ » ជាមួយលោកស្រីបណ្ឌិត ហេម៉ា នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ ចាប់ពីថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ១៩៩៦ វេលាម៉ោង ៨ ព្រឹក តទៅ រហូតដល់ចប់ជាស្ថាពរ ។

១. លោក រស់ សាវេន

២. លោក នួច ជឹម

៣. លោក ប្រាក់ ឃុន

៤. លោក ម៉ែន ប្រាង

៥. លោក អាំ ឆន

៦. លោក អ៊ុង សុវណ្ណ

៧. លោក ជិត ជន

មន្ត្រីរាជការ ដូចមានរាយនាមខាងលើ ត្រូវអនុវត្តភារកិច្ចរៀងៗខ្លួនឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ។

…ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ១៩៩៦

…សខាធិការ…ធម្មការ និង សាសនា

…ះរៀន-វណ្ណៈអៀ

# និវេទនកថា

គណៈកម្មការឯកទេសភាសាបាលិ បានត្រួតពិនិត្យសំណៅ « បាលិវេយ្យាករណ៍ ភាគទី ១ » របស់លោក ប្រាក់ ឃុន គ្រូពុទ្ធិកបឋមសិក្សា វត្តពោធិវាល ខេត្តបាត់ដំបង ជាពីរលើក នៅសាលប្រជុំពុទ្ធសាសនបណ្ឌិត្យ ៖

. លើកទី ១ នៅខែកញ្ញា ឆ្នាំ ១៩៩៦ ។ គណៈកម្មការបានពិនិត្យ និងសម្រេចឱ្យកាត់បន្ថយត្រង់អន្លើខ្លះ ខាងផ្នែកមេរៀនវេយ្យាករណ៍ ទុកសម្រាប់សៀវភៅ ភាគទី ២ ហើយបានសុំឱ្យលោក ប្រាក់ ឃុន រៀបរៀង កែសម្រួល និងបំពេញបន្ថែមផ្នែកលំហាត់មួយចំនួនទៀត ។ បន្ទាប់មក អង្គប្រជុំបានសម្រេចដូរឈ្មោះ « បាលិវេយ្យាករណ៍ ភាគទី ១ » នេះទៅជា « បែបរៀនភាសាបាលិ » វិញ ដើម្បីឱ្យស្របទៅនឹងមេរៀន និងលំហាត់ ក្នុងសៀវភៅនេះ ។

. លើកទី ២ នៅដើមឆ្នាំ ១៩៩៧ ។ គណៈកម្មការបានពិនិត្យឃើញថា សៀវភៅ «បែបរៀនភាសាបាលិ ភាគទី ១ » ដែលបានរៀបរៀង កែសម្រួលឡើងវិញនេះ មានលក្ខណៈសមស្របតាមវិធីទំនើបសម្រាប់រៀន និងបង្រៀនភាសាបាលិ នៅពុទ្ធិកបឋមសិក្សា នាពេលបច្ចុប្បន្ននេះ ។

គណៈកម្មការឯកទេសភាសាបាលី បានធ្វើសំណូមពរឱ្យគណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា ដាក់បញ្ចូលសៀវភៅ បែបរៀនភាសាបាលិនេះ ក្នុងពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី » ក្នុងព្រះរាជាណាចក្រកម្ពុជា តទៅ ។

ភ្នំពេញ, ខៃ ១៣ ខែមករា ឆ្នាំ ១៩៩៧

ជ. គណៈកម្មការឯកទេសភាសាបាលី

ម៉ែន ប្រាជ

# សេចក្ដីដកស្រង់កំណត់ហេតុ
# របស់គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

បន្ទាប់ពីគណៈកម្មការឯកទេសភាសាបាលី បានពិនិត្យសំណៅ « *បែបរៀនភាសាបាលី ភាគទី ១* » ដែលរៀបរៀងឡើងដោយលោក ប្រាក់ យុន រួចមក គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សានៃក្រសួងធម្មការ និងសាសនា បានប្រជុំគ្នាត្រួតពិនិត្យយ៉ាងម៉ត់ចត់នូវសំណៅ បែបរៀនភាសាបាលី ភាគទី ១ នេះ នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ។ គណៈកម្មការយល់ឃើញថា ៖

. មេរៀនសង្ខេប លំហាត់តែង និងបំពេញពាក្យជាឃ្លា . ប្រយោគ ក្នុងសៀវភៅនេះ មានលក្ខណៈឆ្លើយតបតាមសំណូមពរ របស់សិស្សនិងគ្រូនៃសាលាពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួចចង់បានជាយូរមកហើយ ។

. សៀវភៅនេះ ជាជំហានដំបូង ស្របតាមទិសដៅនៃការអភិវឌ្ឍន៍ពុទ្ធិក-សិក្សា នៅក្នុងប្រទេសកម្ពុជា នាបច្ចុប្បន្ន ។

. សៀវភៅនេះ ស្របតាមសង្វាក់នៃការសិក្សាផ្នែកភាសាអន្តរជាតិផងដែរ ។

គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា បានសម្រេចបញ្ចូលសៀវភៅ *បែបរៀនភាសាបាលី* នេះ ក្នុងពួកសៀវភៅ « សម្រាប់ការសិក្សាភាសាបាលី កម្រិតពុទ្ធិកបឋមសិក្សា ឆ្នាំទី ១ » តទៅ ។

ភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ជ. គណៈកម្មការអភិវឌ្ឍន៍ពុទ្ធិកសិក្សា

**ដោក ណារិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និងសាសនា

លេខ ៣៧ / ៩៧ ក.ធ.ស

ភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

# សេចក្ដីសម្រេច

## ស្ដីពីការបោះពុម្ពសៀវភៅបែបរៀនភាសាបាលីភាគ ।

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣,
- បានឃើញព្រះរាជក្រម លេខ នស.រកម. ០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា,
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ១៩៩៧,

## សម្រេច

ប្រការ ១ : អនុញ្ញាតឱ្យបោះពុម្ពសៀវភៅ បែបរៀនភាសាបាលីភាគ ។ ។

ប្រការ ២ : សៀវភៅបែបរៀនភាសាបាលីភាគ ។ ត្រូវបោះពុម្ពខ្នាត ទំហំ ១៤ x ២០,៥ ។

ប្រការ ៣ : អនុអញ្ញាតឱ្យបោះពុម្ពលើកទី ។ ចំនួន ៣.៥០០ ក្បាល ។

ប្រការ ៤ : វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ អនុវិទ្យាល័យព្រះសុរាម្រឹទ្ធិ មានភារកិច្ចអនុវត្តឱ្យបាន សម្រេចលទ្ធផលល្អ តាមសេចក្ដីសម្រេចខាងលើនេះ ។

ចម្លងជូន :

- ក្រសួងសម្ដេចព្រះសង្ឃរាជទាំងពីរគណៈ
- ឯកសារ

ព្រៀង-ភណ្ណារ័ត្ន

# អារម្ភកថា

អ្នកសិក្សាភាសាបាលី ជាដំបូងត្រូវរៀនវេយ្យាករណ៍បាលី បន្ទាប់មកត្រូវរៀនវិធីសម្ពន្ធ និងវិធីប្រែបាលី តទៅទៀត គួររៀនវិធីរៀងប្រយោគ ភាសាបាលីតែងឆន្ទ .......... ។

ឯវិធីសម្ពន្ធ មានរបៀបច្រើនយ៉ាង តាមយោបល់របស់ លោកគ្រូឧទ្ទេសាចារ្យម្នាក់ៗ ទោះម្ដេចម្ដាក៏គង់ល្អប្រសើរ ជាងការមិនចេះ ព្រោះ បាន ស្គាល់ សព្ទ បទ វាចកៈ ជាដើម ច្បាស់លាស់ ។

ចំណែកខ្ញុំ ( **ប្រាក់ ឃុន** ) មានអាយុ ៨០ ឆ្នាំ ឋិតនៅ ក្នុងមាត់មច្ចុរាជចង់បានផលានិសង្សធម្មទាន ទៅកាន់បរលោក ទើបខំប្រឹងអស់ពីសមត្ថភាព បង្រៀនភាសាបាលី តាំងពី ឆ្នាំ ១៩៩០ មកដល់ឆ្នាំ ២០០៦ នេះ ហើយបានរៀបរៀង បែបរៀនភាសាបាលី ភាគទី ១ ភាគទី ២ និងភាគទី ៣ នេះ ផ្សព្វផ្សាយជាធម្មទានបើមាន ការខុសឆ្គងកន្លែងណា សូមលោកអ្នកប្រាជ្ញ ជួយកែសម្រួលចែកទាន ។

ខ្ញុំបាទសូមឧទ្ទិស ផលបុណ្យនេះ ជូនលោកអ្នកមាន គុណមាន មាតាបិតា គ្រូអាចារ្យជាដើម សូមបានសោយឥដ្ឋមនុញ្ញផលសព្វៗ កាលទៅហោង ។

ព.ស. ២៥៥០

វត្តដំរីស, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ──────

គ.ស. ២០០៦

**ច្រាក់ ឃុន**

# មាតិកា


ឈ្មោះអត្ថបទ ទំព័រ

១.សម្ពន្ធ........................................................ ១

២.ការសម្ពន្ធ.................................................... ៣

៣.បឋមាវិភត្តិ.................................................... ៤

៤.សយកត្តា...................................................... ៨

៥.ហេតុកត្តា.................................................... ១១

៦.វុត្តកម្ម........................................................ ១៣

៧.ទុតិយាវិភត្តិ.................................................. ១៦

៨.អវុត្តកម្ម...................................................... ១៧

៩.សម្បាបុណិយកម្ម.............................................. ១៨

១០.ការិតកម្មៈ ................................................. ២០

១១.អច្ចន្តសំយោគៈ ........................................... ២១

១២.អកថិតកម្ម................................................. ២៣

១៣.កិរិយាវិសេសនៈ ........................................... ២៤

១៤.តតិយាវិភត្តិ................................................ ២៦

១៥.ករណៈ ................................................ ២៧

១៦.គតិយាវិសេសនៈ ...................................... ២៨

១៧.អនភិហិតកត្តា........................................ ២៩

១៨.ហេតុ.................................................. ៣០

១៩.ឥត្ថម្ភូតៈ .............................................. ៣០

២០.សហត្ថតតិយា.......................................... ៣៥

២១.ចតុត្ថីវិភត្តិ........................................... ៣៧

២២.បញ្ចមីវិភត្តិ........................................... ៣៩

២៣.ឆដ្ឋីវិភត្តិ............................................... ៤១

២៤.សាមិសម្ពន្ធ........................................... ៤២

២៥.សមូហសម្ពន្ធ........................................... ៤២

២៦.ភាវាទិសម្ពន្ធ........................................... ៤៣

២៧.អនាទរៈ ............................................... ៤៤

២៨.និទ្ធារណៈ ............................................. ៤៦

២៩.ឆដ្ឋីកម្ម ................................................ ៤៧

៣០.សត្តមីវិភត្តិ ............................................ ៤៨

៣១.បដិច្ឆន្នាធារៈ ........................................ ៤៩

៣២.ព្យាបិកាធារៈ ........................................ ៥០

៣៣.វេសយិកាធារៈ ........................................ ៥១

៣៤.កាលត្ថសត្តមី ........................................ ៥២

៣៥.ឧបសិលេសិកាធារៈ ........................................ ៥៤

៣៦.លក្ខណៈ ........................................ ៥៥

៣៧.និមិត្តសត្តមី ........................................ ៥៧

៣៨.និទ្ធារណៈ ........................................ ៥៨

៣៩.សមីបាធារៈ ........................................ ៦០

៤០.អាលបនៈវិភត្តិ ........................................ ៦១

៤១.អគារវាលបនៈ ........................................ ៦៣

៤២.មេរៀនសង្ខេប ........................................ ៦៤

៤៣.គុណនាម ........................................ ៦៧

៤៤.សព្វនាម ........................................ ៦៩

៤៥.កិរិយាអាខ្យាត ........................................ ៨២

៤៦.កិរិយាកិតក: ........................................ ៨៤

៤៧.អព្យយកិរិយា ................................................ ៩១

៤៨.តថា លិង្គត្ថ: ................................................ ៩៦

៤៩.អលំ លិង្គត្ថ: ................................................ ៩៧

៥០.សាធុ លិង្គត្ថ: ................................................ ៩៨

៥១.សច្ចវាចក: លិង្គត្ថ: ........................................ ៩៩

៥២.កុមត្ថកត្តា ................................................ ៩៩

៥៣.កុមត្ថសម្បទាន ................................................ ១០០

៥៤.ភិន្នាធារ: ................................................ ១០១

៥៥.សត្តមីបច្ចត្ថ: ................................................ ១០៣

៥៦.គុណនាមពិសេស ................................................ ១០៤

៥៧.សញ្ញាវិសេសន: ................................................ ១០៥

៥៨.វិសេសលាភី ................................................ ១០៥

៥៩.សរូបនិទស្សន: ................................................ ១០៦

៦០.កិរិយាបធានន័យ................................................ ១០៧

៦១.កិរិយាបរាមាស ................................................ ១០៨

៧០.កិរិយាបទ ................................................ ១១០

៧១.សក្កា ចុះក្នុងអត្ថ ៣ យ៉ាង ................................ ១១២

៧២.អលំ ចុះក្នុងអត្ថ ៤ យ៉ាង ................................ ១១២

៧៣.ឯវំ-សព្ទមានអត្ថ ៤ យ៉ាង................................ ១១៣

៧៤.តថា មានអត្ថ ៥ យ៉ាង .................................... ១១៤

៧៥.ឥតិ-សព្ទចុះក្នុងអត្ថ ៨ យ៉ាង .............................. ១១៤

៧៦.វិយ, ឥវ, យថា, មានអត្ថ ៤ យ៉ាង......................... ១១៧

៧៧.វិកតិអវុត្តកម្ម ................................................ ១១៨

៧៨.ប្រយោគពិសេស ............................................ ១១៩

៧៩.ប្រយោគតាមវេយ្យាករណ៍មាន ៤ យ៉ាង.................. ១២៣

៨០.ប្រយោគតាមវិធីសម្ពន្ធមាន ៦ យ៉ាង...................... ១២៣

៨១.ប្រយោគតាមលក្ខណនៃការប្រែមាន ៥ យ៉ាង............. ១២៤

# **បាលីវេយ្យាករណ៍**

បាលីជា **តន្តិភាសា** មានរបៀបត្រឹមត្រូវ តាមក្បួនវេយ្យាករណ៍ ដែលពួកអ្នកកាន់ព្រះពុទ្ធសាសនា ទក្ខិណនិកាយតាក់តែងឡើងសម្រាប់ចារឹកគម្ពីររបស់ខ្លួន ។

តាំងពីកាលព្រះពុទ្ធអង្គ ទ្រង់គង់ធរមាននៅឡើយ រហូតដល់បរិនិព្វានទៅ អស់កាល ៤០០ ឆ្នាំ ព្រះអរហន្តជាសាវ័កទាំងឡាយ បានចេះព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកចាំស្ទាត់ដោយមាត់ទទេ មិនបានចារឹកទុកជាលាយល័ក្ខណ៍អក្សរនៅឡើយ ទើបមានឈ្មោះថាមុខបាឋោ ។

លុះព.ស. ៤៥២ ដល់ ៤៦៤ មតិខ្លះ ថា ព.ស. ៤៣៣ ដល់ ៤៥០ នៃពុទ្ធសករាជទើបព្រះថេរៈទាំងឡាយជាសង្គីតិកាចារ្យ ធ្វើសង្គាយនាទី ៥ នៅលង្កាទ្វីបបាន ចារឹកជាលាយល័ក្ខណ៍អក្សរចារទុកព្រះត្រៃបិដកក្នុងស្លឹករឹតឡើង ព្រោះហេតុនោះ ព្រះត្រៃបិដកចាត់ជាបាលីជាន់ខ្ពស់ ( ថ្នាក់ទី ១ ) ។

ក្នុងសតវត្សរ៍ទី ១០ ព.ស. ៩៥៦ ព្រះថេរៈមួយអង្គ ព្រះនាមពុទ្ធឃោសាចារ្យជា អ្នកប្រាជ្ញជាតិឥណ្ឌាបាន និមន្តទៅលង្កាទ្វីបធ្វើសំវណ្ណនា កែខៃព្រះត្រៃបិដកដែល មានឈ្មោះថា អដ្ឋកថា ចាត់ជាបាលីថ្នាក់ទី ២ ។

តមក ព្រះថេរៈទាំងឡាយ បានបង្កើតនូវដីកា, អនុដីកា, អត្ថយោជនា និងក្បួនវេយ្យាករណ៍បាលីតាមលំដាប់លំដោយ ។

ឯក្បួនបាលី មានឈ្មោះសំខាន់គឺ : កច្ចាយនៈ, មោគ្គល្លាន, និង សទ្ទនីតិ ។

កច្ចាយនៈ មានអាយុកាលចាស់ជាងគេត្រូវជា ដើមនៃវេយ្យាករណ៍ទាំងអស់ ។

តាម ដីកា កច្ចាយនសូត្រ ពោលថា : អ្នកនិពន្ធកច្ចាយនៈ នេះគឺព្រះមហាកច្ចាយនត្ថេរ ដែលគេលើក តម្កើងទុកដូចជាព្រះកច្ចាយនត្ថេរស្ថិតនៅ ក្នុងពួកអសីតិមហាសាវ័កដែលព្រះសម្ពុទ្ធទ្រង់លើកជាឯតទគ្គៈខាងចេះពង្រីកសេចក្តីដែលព្រះអង្គសំដែងដោយសង្ខេបអោយពិស្តារបាន ។

ព្រះមហាកច្ចាយនត្ថេរអង្គនេះនៅក្នុងដែនសុរសេនៈ ក្រុងមថុរា ( មធុរា ) ប្រទេសឥណ្ឌាភាគខាងត្បូង គឺអវន្តិ ខាងត្បូងបាននិពន្ធគម្ពីរ បាលីវេយ្យាករណ៍ឈ្មោះ កច្ចាយនៈ ក្នុងសតវត្សរ៍ទី ៥, ទី ៦, នៃ គ.ស. ។

ឯ មោគ្គល្លាន និង សទ្ទនីតិ កើតក្នុងព.ស. ១៦៩៥, ៩៦, ៩៧ គម្ពីរមោគ្គល្លាន កើតមានក្នុងលង្កាទ្វីបដោយស្នាព្រះហស្ថ នៃព្រះមហាមោគ្គល្លានត្ថេរ ជាអ្នកប្រាជ្ញមានកិត្តិស័ព្ទល្បីល្បាញ ក្នុងយុគនោះ

បន្ទាប់មកលោកបានប្រមូលរូបរួមសព្ទ ចងក្រងជាគម្ពីរមួយឈ្មោះ អភិធានប្បទីបិកា ។

ឯ **សទ្ទនីតិ** កើតឡើងក្នុងប្រទេសភូមានិពន្ធដោយ ព្រះ-អគ្គវង្សាចារ្យ ជាអ្នកប្រាជ្ញមាននាមល្បីល្បាញក្នុងប្រទេសនោះ សទ្ទនីតិជាវេយ្យាករណ៍ខ្ពង់ខ្ពស់វិចិត្រពិស្តារជាង កច្ចាយនៈ។ មតិនៃសទ្ទនីតិនេះអនុលោមស្របតាមព្រះត្រៃបិដក ជាមតិសំខាន់គួរនិយមព្រោះងាយមើលឆាប់យល់ជាងវេយ្យាករណ៍ ឯទៀតទាំងអស់ ។

# **សម្ពន្ធ**

សម្ពន្ធ គឺការចងផ្គុំពាក្យដែលលោកបានតែងទុកជាប្រយោគស្រេចហើយនោះដើម្បីឱ្យស្គាល់ថា : បទណាចូលនិងបទណាបាន បទណាចូលនិងបទណាមិនបាន ជាដើម ។

ការសម្ពន្ធ មានរបៀបច្រើនយ៉ាង សូមយកសម្ពន្ធ ភ្ជូង គឺ សម្ពន្ធ តាមវិធីប្រែបាលី បើប្រែបទណាមុនក៏សម្ពន្ធបទនោះមុនរហូតចប់ ប្រយោគ ។ មុននឹងសម្ពន្ធត្រូវស្គាល់ ពាក្យថា សព្ទ, បទ, វាក្យាង្គ នឹង វាក្យៈ ជាមុនសិនទើបងាយស្រួល សម្ពន្ធ ។

**១. សព្ទ** បានដល់ឧបសគ្គ និង ពួកនិបាតព្រមទាំងនាមនិងកិរិយាដែលមិនបានប្រកបដោយវិភត្តិហៅថា **សព្ទ** ពេលសម្ពន្ធ ថា "**សទ្ទ**" ប្រកបនិងវិភត្តិតាមត្រូវការដូចជា : **សទ្ទោ សទ្ទស្ស សទ្ទេ** ជាដើម ។

**២. បទ** សំដៅយកនាមសព្ទ និងកិរិយាសព្ទទាំងអស់ដែលប្រកបវិភត្តិស្រេចហើយហៅថា "បទ" ដោយអនុលោម [១] ។

**៣. វាក្យាង្គ** បទច្រើន តាំងពីត្រឹមពីរបទឡើងទៅ ល្មមផ្សំឱ្យ

---

(១) វេលាសម្ពន្ធថា "បទ" ប្រកបនិងវិភត្តិដូចជា បទ បទំ បទេន បទស្ស ។

ជាសេចក្ដីស្ដាប់បាន តែនៅជាវគ្គជាសង្កាត់ មិនទាន់បានសេចក្ដីពេញទីហើយឥតមានកិរិយា ឃុំគ្រង ប្រយោគហៅថា "វាក្យាង្គ (ចំណែកនៃពាក្យ)" មាន ៣ គឺ :

ក/ **នាមវាក្យាង្គ** មានពាក្យទាក់ទងនិងប្រធានជានាម គឺបទដែលសម្ពន្ធចូលនិងប្រធានជានាមនាម ដែលប្រកបដោយវិភត្តិទាំង ៧ វៀរលែង តែបឋមាវិភត្តិចេញ ឧ. **កុលស្ស បុត្តោ ៗ សព្វធាបស្ស អករណំ ៗ កិត្តកេហិ បន តេ ភិក្ខូហិ អត្តោ ៗ**

ខ/ **គុណវាក្យាង្គ** មានពាក្យទាក់ទងនិងប្រធានជាគុណ ឬ ជាវិសេសនៈ គឺបទប្រធាននោះមានគុណបទ ឬ វិសេសនៈ ឧ. **បិយោ បុត្តោ ៗ អនុបិយំ នាម មល្លានំ និគមោ ៗ សុខំ មេ ឆានំ ៗ**

គ/ **កិរិយាវាក្យាង្គ** មានកិរិយាជាពាក្យពង្រីកប្រធាន គឺ មានកិរិយាតូចៗ ដែលហៅថា អព្ភន្តរកិរិយា វៀរចាកកិរិយាអាខ្យាតនិងកិរិយាកិតកៈ ដែលឃុំគ្រងពាក្យចេញ ។ ឧ. **ពុទ្ធោ លោកេ ឧប្បន្នោ ៗ បុត្តោ មាតាបិតូសុ សម្មា បដិបជ្ជន្តោ ៗ ថេរស្ស និទ្ទំ អនោក្កមន្តស្ស, បឋមមាសេ អតិក្កន្តេ, ( អគ្គិរោគោ ឧប្បជ្ជិ ) ៗ**

ឃ/ **វាក្យៈ** បទច្រើនឬវាក្យាង្គច្រើន តាំងពីត្រឹមពីរបីឡើងទៅ

ដែលផ្សំបាន ជាសេចក្ដីពេញទី ហៅថា វាក្យៈ ប្រែថា "សំដីដែលគេនិយាយ" ។ ឧ. **ពុទ្ធោ លោកេ ឧប្បន្នោ, សោ ទេវមនុស្សានំ អត្ថាយ ហិតាយ សុខាយ ធម្មំ ទេសេតិ ២** សង្កាត់មួយៗ ឬប្រយោគមួយៗ ដែលមានកិរិយាអាខ្យាតមួយៗ ឃុំគ្រងពាក្យហៅថា វាក្យៈមួយៗ ។ វាក្យាង្គច្រើនផ្សំឱ្យ ជាសេចក្ដីស្ដាប់បាន ឧ. **បុត្តោ មាតាបិតូសុ សម្មា ( បដិបជ្ជន្តោ ) តេសំ កិច្ចាកិច្ចេសុ ឧស្សុក្កំ អាបន្នោ, បសំសំ លភតិ ២** តាំងពី **បុត្តោ** ដល់ **បដិបជ្ជន្តោ** ជាវាក្យាង្គមួយ, រហូតដល់ **អាបន្នោ** ជាវាក្យាង្គមួយទៀត, រហូតដល់កិរិយាអាខ្យាតគឺ **លភតិ** ពេញទីគ្រប់ជា វាក្យៈ ។

## ការសម្ពន្ធ

រប្បៀបនៃការសម្ព័ន្ធ ដែលនឹងសម្ពន្ធថា យ៉ាងនេះ យ៉ាងនោះកើត ត្រូវថាតាមអត្ថរបស់អាយតនិបាតខ្លះ តាមគុណនាមខ្លះ តាមកិរិយាអាខ្យាតខ្លះ តាមកិរិយាកិតកៈខ្លះ តាមអព្យយសព្ទខ្លះ ដូចតទៅនេះ :

អត្ថរបស់អាយតនិបាត វិភត្តិមួយៗ តែងតែមានអាយតនិបាតគឺពាក្យប្រែរបស់វិភត្តិផ្សេងៗ គ្នា, អាយតនិបាតទាំងនោះមានអត្ថ ប្រព្រឹត្តទៅតាមទំនងសេចក្ដី ល្មមឱ្យអ្នកប្រាជ្ញអាចកំណត់សម្គាល់បាន ។

## ១.បឋមាវិភត្តិ

បទនាមនាមដែលប្រកបផ្សំនិងបឋមាវិភត្តិ (**សិ**-**យោ**) ប្រែថា " វី..., វី...ទ." ជាបទប្រធានមានអត្ថ ៤ យ៉ាង គឺៈ

**១. លិង្គត្ថោ** ប្រែតាមរូបសព្ទថា "អត្ថនៃលិង្គ" ព្រោះសមគួរដល់លិង្គ តាមជាតិកំណើតរបស់ខ្លួនដូច **បុរិសោ** វីបុរស ជាបុំលិង្គ, ឥត្ថី វីស្រី ជាឥត្ថីលិង្គ, **វត្ថុំ** វីសំពត់ ជានបុំសកលិង្គ ទាំងអស់នេះសុទ្ធតែប្រកបដោយបឋមាវិភត្តិមានសេចក្តីផ្សេងៗ គ្នាទៅតាមលិង្គហៅថា **លិង្គត្ថោ** សំដៅយកប្រយោគ ជានាមវាក្យាង្គ ឬ គុណវាក្យាង្គដែលឥតកិរិយាអាខ្យាត ឬឥតមានកិរិយាកិតកៈទទួលគឺមានតែនាម-នាម និង នាមនាម ។

**២. កុលស្ស បុត្តោ** "កូនរបស់ត្រកូល" ឬ ដែលមានតែនាមនាម និង គុណនាម ។

**៣. បិយោ បុត្តោ** " កូនជាទីស្រលាញ់ " ក្នុងប្រយោគមិនមាន កិរិយាទទួលបែបនេះហៅថា **លិង្គត្ថោ** ។

**៤. ភិក្ខុនោ ចីវរំ** "វីចីវរ របស់ភិក្ខុ", **នវំ ចីវរំ** "ចីវរថ្មី " ។

### វិធីសម្ពន្ធ

**ភិក្ខុនោ** សាមិសម្ពន្ធក្នុង **ចីវរំ**ៗ លិង្គត្ថៈ ។ **នវំ** វិសេសនៈ

របស់ **ចីវរំ** លិង្គត្ថៈ ។

## ប្រែលោតប្រយោគ និង សម្ពន្ធ

**១. ពុទ្ធស្ស សាវកា** វីសាវ័កទ. របស់ព្រះពុទ្ធ , **ពុទ្ធស្ស** សាមិសម្ពន្ធក្នុង **សាវកា** លិង្គត្ថៈ ។

**២. ធម្មេ បសាទោ** វីសេចក្តីជ្រះថ្លា ក្នុងព្រះធម៌ , **ធម្មេ** ភិន្នាធារៈក្នុង **បសាទោ** លិង្គត្ថៈ ។

**៣. សាវកានំ សង្ឃោ** វីពួក នៃសាវ័កទ. , **សាវកានំ** សាមិសម្ពន្ធក្នុង **សង្ឃោ** លិង្គត្ថៈ ។

**៤. អាចរិយស្ស សិស្សោ** វីសិស្សទ. របស់អាចារ្យ , **អាចរិយស្ស** សាមិសម្ពន្ធក្នុង **សិស្សោ** លិង្គត្ថៈ ។

**៥. គាមេ អាវាសោ** វីអាវាស ជិតស្រុក , **គាមេ** សមីបាធារៈ ក្នុង **អាវាសោ** លិង្គត្ថៈ ។

**៦. គាមេសុ ទារកា** វីក្មេងទ. ក្នុងស្រុកទ. , **គាមេសុ** វេសយិកាធារៈក្នុង **ទារកា** លិង្គត្ថៈ ។

**៧. មរណស្មា ភយំ** វីភ័យ អំពីសេចក្តីស្លាប់ , **មរណស្មា** អបាទានក្នុង **ភយំ** លិង្គត្ថៈ ។

**៨. អរិម្ហា ឧត្រាសោ** វីសេចក្តីតក់ស្លុត អំពីសត្រូវ , **អរិម្ហា**

អបាទានក្នុង **ឧត្តរាសោ។** លិង្គត្ថៈ ។

**៩. រុក្ខេ សិខី** វីក្ងោក លើដើមឈើ , **រុក្ខេ** ឧបសិលេសិកា-ធារៈក្នុង **សិខី។** លិង្គត្ថៈ ។

**១០. គោដ្ឋេ វីហយោ** វីស្រូវទាំងឡាយ ក្នុងជង្រុក , **គោដ្ឋេ** បដិច្ឆន្នាធារៈក្នុង **វីហយោ។** លិង្គត្ថៈ ។

**១១. អគ្គោ ពុទ្ធោ** វីព្រះពុទ្ធ ទ្រង់ប្រសើរលើស , **អគ្គោ** វិសេសនៈរបស់ **ពុទ្ធោ។** លិង្គត្ថៈ ។

**១២. អគ្គស្ស ពុទ្ធស្ស សាសនំ** វីសាសនា របស់ព្រះពុទ្ធ ទ្រង់ប្រសើរលើស , **អគ្គស្ស** វិសេសនៈរបស់ **ពុទ្ធស្ស។** សាមិសម្ពន្ធ ក្នុង **សាសនំ។** លិង្គត្ថៈ ។

**១៣. សុន្ទរោ ធម្មោ** វីព្រះធម៌ ល្អ , **សុន្ទរោ** វិសេសនៈរបស់ **ធម្មោ។** លិង្គត្ថៈ ។

**១៤. សុន្ទរស្ស ធម្មស្ស វិបាកោ** វីវិបាក របស់ធម៌ ល្អ , **សុន្ទរស្ស** វិសេសនៈរបស់ **ធម្មស្ស។** សាមិសម្ពន្ធក្នុង **វិបាកោ។** លិង្គត្ថៈ ។

**១៥. កុសលោ អាចរិយោ** វីអាចារ្យ អ្នកឈ្លាស , **កុសលោ** វិសេសនៈរបស់ **អាចរិយោ។** លិង្គត្ថៈ ។

**១៦. កុសលស្ស អាចរិយស្ស សិស្សា** វីសិស្សទ.,
របស់អាចារ្យ អ្នកឈ្លាស , **កុសលស្ស** វិសេសនៈរបស់ **អាចរិយស្ស**ៗ
សាមិសម្ពន្ធ ក្នុង **សិស្សា**ៗ លិង្គត្ថៈ ។

**១៧. មហតី សាលា** វីសាលា ធំ , **មហតី** វិសេសនៈរបស់
**សាលា**ៗ លិង្គត្ថៈ ។

**១៨. មហតិយំ សាលាយំ ជនា** វីជនទាំងឡាយ
ក្នុងសាលា ធំ , **មហតិយំ** វិសេសនៈរបស់ **សាលាយំ**ៗ ភិន្នាធារៈក្នុង
**ជនា**ៗ លិង្គត្ថៈ ។

**១៩. លោកេ អគ្គោ ធម្មោ បសាទោ** វីសេចក្ដីជ្រះថ្លា
ក្នុងធម៌ ដ៏ប្រសើរលើស ក្នុងលោក , **លោកេ** អាធារៈក្នុង **អគ្គោ**ៗ
វិសេសនៈ របស់ **ធម្មោ**ៗ ភិន្នាធារៈក្នុង **បសាទោ**ៗ លិង្គត្ថៈ ។

**២០. សីតា ចន្ទស្ស អាភា** វីពន្លឺ នៃព្រះចន្ទ ត្រជាក់ , **សីតា**
វិសេសនៈរបស់ **អាភា**, **ចន្ទស្ស** សាមិសម្ពន្ធក្នុង **អាភា**ៗ លិង្គត្ថៈ ។

## លំហាត់ប្រែលោតប្រយោគ និង សម្ពន្ធ

**១. អរិយា បុគ្គលា ៤**

**២. អរិយស្ស បុគ្គលស្ស បុត្តា ៤**

**៣. គតា អាទិច្ចស្ស អាភា ៤**

៤. មហន្តា បព្វតេ រុក្ខា ២

៥. កណ្ហានំ គោណានំ តចោ ២

៦. ខត្តិយាយ នារិយា បុត្តោ ២

៧. មាគធស្ស រញ្ញោ ជេដ្ឋោ បុត្តោ ២

៨. ឧច្ចស្ស ថូបស្ស សិខរេ ធជោ ២

៩. មហន្តំ ព្រហ្មនោ វិមានំ ២

១០. តមេ នភេ តារាយោ ២

## ២.សយកត្តា

**សយកត្តា** ប្រែថា "អ្នកធ្វើដោយខ្លួនឯង" បានដល់បទ នាម-នាម ដែលប្រកបដោយបឋមាវិភត្តិជាបទប្រធាន ក្នុងប្រយោគជាកត្តុវាចកៈ ហៅថា សយកត្តា សម្ពន្ធចូលនិងកិរិយាអាខ្យាត ឬកិរិយា-កិតកៈហើយ ភ្ជាប់ពាក្យថា "ក្នុង" ដូចឧទាហរណ៍ តទៅនេះ **ភិក្ខុ គាមំ បវិដ្ឋោ** "វីភិក្ខុ ចូលទៅហើយ កាន់ស្រុក"។

## វិធីសម្ពន្ធ

**ថេរោ** សយកត្តាក្នុង **ទេសេតិ** អាខ្យាតបទកត្តុវាចកៈ **ធម្មំ** អវុត្តកម្មក្នុង **ទេសេតិ**, **ភិក្ខុ** សយកត្តាក្នុង **បវិដ្ឋោ** កិតបទកត្តុវាចកៈ **គាមំ** សម្បាបុណិយកម្មក្នុង **បវិដ្ឋោ** ។

## ប្រែលោតប្រយោគ និង សម្ពន្ធ

**១. ពុទ្ធោ លោកេ ឧប្បជ្ជតិ** វិ ព្រះពុទ្ធ កើតឡើង ក្នុងលោក, **ពុទ្ធោ** សយកត្តាក្នុង **ឧប្បជ្ជតិ**ៗ អាខ្យាតបទកត្តុវាចកៈ **លោកេ** វេសយិកាធារៈក្នុង **ឧប្បជ្ជតិ** ។

**២. សុរិយោ នភេ ឧគ្គតោ** វិ ព្រះអាទិត្យ រះឡើងហើយ ត្រង់ផ្ទៃអាកាស , **សុរិយោ** សយកត្តាក្នុង **ឧគ្គតោ**ៗ កិតបទកត្តុវាចកៈ **នភេ** អាធារៈក្នុង **ឧគ្គតោ** ។

**៣. វាណិជោ នគរា និក្ខមិ** វិ ពាណិជ ចេញទៅហើយ ចាកទីក្រុង, **វាណិជោ** សយកត្តាក្នុង **និក្ខមិ**ៗ អាខ្យាតបទ កត្តុវាចកៈ **នគរា** អបាទានៈក្នុង **និក្ខមិ** ។

**៤. ភិក្ខុ គាមំ បិណ្ឌាយ បវិដ្ឋោ** វិ ភិក្ខុទ. ចូលទៅហើយ កាន់ស្រុក ដើម្បីដុំបាយ, **ភិក្ខុ** សយកត្តាក្នុង **បវិដ្ឋោ** , **បិណ្ឌាយ** សម្បទានៈក្នុង **បវិដ្ឋោ**, **គាមំ** សម្បាបុណិយកម្មៈក្នុង **បវិដ្ឋោ**ៗ កិតបទ កត្តុវាចកៈ ។

**៥. ហត្ថី ជិណ្ណាយ សាលាយ ឋិតោ** វិ ដំរី ឈរហើយ ក្នុងរោង ដែលគ្រាំគ្រាហើយ , **ហត្ថី** សយកត្តាក្នុង **ឋិតោ**ៗ កិតបទ កត្តុវាចកៈ **ជិណ្ណាយ** វិសេសនៈរបស់ **សាលាយ**ៗ វេសយិកាធារៈក្នុង

**ឋិតោ** ។

**៦. នីលំ ឧប្បលំ ឧទកេ ជាយតេ** ផ្កាឧប្បលខៀវដុះក្នុងទឹក, **នីលំ** វិសេសនៈរបស់ **ឧប្បលំ**ៗ សយកត្តាក្នុង **ជាយតេ**ៗ អាខ្យាតបទ កត្តុវាចកៈ **ឧទកេ** វេសយិកាធារៈក្នុង **ជាយតេ** ។

**៧. សុក្ខា សាខា រុក្ខា បតិតា** មែក ស្ងួត ធ្លាក់ហើយ ចាកឈើ , **សុក្ខា** វិសេសនៈរបស់ **សាខា**ៗ សយកត្តាក្នុង **បតិតា**, **រុក្ខា** អបាទានៈក្នុង **បតិតា**ៗ កិតបទ_កត្តុវាចកៈ ។

**៨. សេដ្ឋិនោ ទ្វេ ធីតរោ គព្ភេ និសីទឹសុ** ធីតាទ. ពីរនាក់ របស់សេដ្ឋី អង្គុយហើយ ក្នុងបន្ទប់ , **សេដ្ឋិនោ** សាមិសម្ពន្ធក្នុង **ធីតរោ**, **ទ្វេ** វិសេសនៈរបស់ **ធីតរោ**ៗ សយកត្តាក្នុង **និសីទឹសុ**, **គព្ភេ** បដិច្ឆន្នាធារៈក្នុង **និសីទឹសុ**ៗ អាខ្យាតបទ កត្តុវាចកៈ ។

**៩. ឯកសដ្ឋី អរហន្តោ លោកេ ឧប្បន្នា** ព្រះអរហន្តទ. ៦១ អង្គកើតឡើងហើយក្នុងលោក, **ឯកសដ្ឋី** វិសេសនៈរបស់ **អរហន្តោ**ៗ សយកត្តាក្នុង **ឧប្បន្នា** , **លោកេ** វេសយិកាធារៈក្នុង **ឧប្បន្នា**ៗ កិតបទ_កត្តុវាចកៈ ។

**១០. ចតុទ្ទស បុរិសា ឯកវីសតិយា ឥត្ថីហិ វីថិយំ គច្ឆឹសុ** បុរសទ. ១៤នាក់ ទៅហើយ ក្នុងវិថី ដោយស្ត្រីទ. ២១នាក់ ,

ចតុត្ថស វិសេសនៈរបស់ បុរិសា។ សយកត្តាក្នុង គច្ឆីសុ, ឯកវីសតិយា វិសេសនៈរបស់ ឥត្ថីហិ។ ករណៈក្នុង គច្ឆីសុ, វីថិយំ អាធារៈក្នុង គច្ឆីសុ។ អាខ្យាតបទ កត្តុវាចកៈ ។

## លំហាត់ប្រែលោតប្រយោគ និង សម្ពន្ធ

១. ធម្មោ សប្បុរិសានំ សន្តានេ តិដ្ឋតិ ។

២. ឥសយោ អរញ្ញេ អារាមេ វុត្ថា ។

៣. រាជា មហន្តេន បរិវារេន នគរា និក្ខមិស្សតិ ។

៤. អមច្ចោ នាវាយ នទិយំ គតោ ។

៥. អសីតិ ភគវតោ មហន្តា សាវកា ។

៦. ភិក្ខូ បច្ចន្តគាមេ បិណ្ឌាយ បវិសីសុ ។

៧. ចន្ទោ រត្តិយំ នភេ ឧគ្គតោ ។

៨. កុមារា គាមេ ឧច្ចាយ សាលាយ និបជ្ជិស្សន្តិ ។

៩. អគ្គិ គេហស្ស ឆទនា ឧដ្ឋិតោ ។

១០. កញ្ញា បតិនោ កុលំ អគមាសិ ។

## ៣.ហេតុកត្តា

ហេតុកត្តា ប្រែថា "អ្នកធ្វើឱ្យជាហេតុ" គឺអ្នកប្រើគេឱ្យធ្វើ មិនបានធ្វើដោយខ្លួនឯងទេ បានដល់បទប្រធានដែលប្រកបដោយ

បឋមាវិភត្តិក្នុងប្រយោគ ហេតុកត្តុវាចកៈ ប្រាប់សេចក្តីថា ជាអ្នកប្រើគេ ។ ឧ. **ជនោ កម្មំ ការេតិ** " រីជន ញ៉ាំងគេឱ្យធ្វើ នូវអំពើ " **ជនោ** ជាបឋមាវិភត្តិ ជាអ្នកប្រើគេឱ្យធ្វើដែលជាប្រធានក្នុងប្រយោគនេះ ឈ្មោះថា "**ហេតុកត្តា**" សម្ពន្ធចូលនិងកិរិយា ប្រើពាក្យថា "ក្នុង" ដូច ឧទាហរណ៍តទៅ :

**អាចរិយោ សិស្សេ សិក្ខាបេតិ** " រីអាចារ្យ ញ៉ាំងសិស្សទ. ឱ្យរៀន " ។ **សាមិកោ ទាសំ ការាបិកោ** " រីម្ចាស់ ញ៉ាំងខ្ញុំប្រុសឱ្យធ្វើ " ។

## សម្ពន្ធ

**អាចរិយោ** ហេតុកត្តាក្នុង **សិក្ខាបេតិ**ៗ អាខ្យាតបទហេតុកត្តុវាចកៈ **សិស្សេ** ការិតកម្មៈក្នុង **សិក្ខាបេតិ** ។

**សាមិកោ** ហេតុកត្តាក្នុង **ការាបិកោ**ៗ កិតបទ_ហេតុកត្តុវាចកៈ **ទាសំ** ការិតកម្មៈក្នុង **ការាបិកោ** ។

**សាមិកោ សូទំ ឱទនំ បាចេតិ** " រីម្ចាស់ ញ៉ាំងអ្នកគ្រួ ឱ្យចំអិន នូវបាយ" , **សាមិកោ** ហេតុកត្តាក្នុង **បាចេតិ**ៗ អាខ្យាតបទ_ហេតុកត្តុវាចកៈ **សូទំ** ការិតកម្មៈក្នុង **បាចេតិ** , **ឱទនំ** អវុត្តកម្មក្នុង **បាចេតិ** ។

**បិតា បុត្តំ សិប្បំ ឧគ្គណ្ហាបេតិ** "របិតា ញ៉ាំងកូន ឱ្យរៀន នូវសិប្បៈ, **បិតា** ហេតុកត្តាក្នុង **ឧគ្គណ្ហាបេតិ** អាខ្យាតបទ-ហេតុកត្តុវាចកៈ **បុត្តំ** ការិតកម្មៈក្នុង **ឧគ្គណ្ហាបេតិ** , **សិប្បំ** អវុត្តកម្ម ក្នុង **ឧគ្គណ្ហាបេតិ** ។

**សេដ្ឋី ទាសេ កម្មានិ ការាបិតោ** "រសេដ្ឋី ញ៉ាំងខ្ញុំប្រុសទ. ឱ្យធ្វើ នូវការងារទាំងឡាយ" , **សេដ្ឋី** ហេតុកត្តាក្នុង **ការាបិតោ** កិតបទ-ហេតុកត្តុវាចកៈ **ទាសេ** ការិតកម្មក្នុង **ការាបិតោ**, **កម្មានិ** អវុត្តកម្មក្នុង **ការាបិតោ** ។

### លំហាត់ប្រែលោតប្រយោគ និង សម្ពន្ធ

**១. បិតា បុត្តេ កម្មំ ការាបិស្សតិ ។**

**២. មាតា បុត្តធីតរោ ធម្មំ សុណាបយតិ ។**

**៣. គរុ មហន្តេ សិស្សេ សិក្ខាគារំ អាគច្ឆាបេតិ ។**

**៤. ពុទ្ធស្ស សាវកា មហាជនេ ធម្មវិនយំ ឧគ្គណ្ហាបេន្តិ ។**

**៥. កសកោ បច្ចេកពុទ្ធស្ស បណ្ណសាលំ ឈាបេសិ ។**

### ៤.វុត្តកម្មៈ

**វុត្តកម្មៈ** ប្រែថា "អំពើដែលគេត្រូវធ្វើ" ឬ "អំពើដែលគេត្រូវប្រើឱ្យធ្វើ" កំណត់យកបទ ដែលប្រកបដោយបឋមាវិភត្តិ ជាប្រធាន

ក្នុងប្រយោគកម្មវាចកៈ ឬហេតុកម្មវាចកៈហៅថា "វុត្តកម្មៈ" ដូច ឧទាហរណ៍ ថា : (កម្មវាចកៈ) **អយំ ធម្មោ ថេរេន ភាសិតោ** " វិធម៌នេះ គឺព្រះថេរៈ សំដែងហើយ" **ធម្មោ** ជាបឋមាវិភត្តិ ជាតួប្រធាន ហៅថា "វុត្តកម្មៈ" , (ហេតុកម្មវាចកៈ) **អយំ ធម្មោ ថេរេន ភាសាបេតព្វោ** " វិធម៌ នេះ គឺព្រះថេរៈ គប្បីឱ្យសំដែង " **ធម្មោ** ក្នុងទីនេះជាសភាវៈ ត្រូវព្រះថេរៈប្រើគេឱ្យសំដែង ហើយចាត់ជាតួប្រធានក្នុងប្រយោគនេះហៅថា "វុត្តកម្មៈ" សម្ពន្ធចូល និងកិរិយា ត្រូវប្រើពាក្យថា "ក្នុង" ដូចគ្នា ឧទាហរណ៍ : **កុសលកម្មំ កត្តព្វំ** " វិអំពើ ជាកុសល (**កេនចិ** គឺអ្នកណាក៏ដោយ ) គប្បីធ្វើ" (កម្មវាចកៈ) ។ **ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ** " វិសង្ឃ គឺភិក្ខុ ឈ្លាសប្រតិពល គប្បីឱ្យដឹង" (ហេតុកម្មវាចកៈ) ។ ត្រង់ពាក្យ **កេនចិ** មិនមានក្នុងប្រយោគនេះទេ ប៉ុន្តែ ត្រូវទាញបញ្ចូលមកទើបត្រូវតាម បែបផែនប្រយោគតែឱ្យល្អមបានសេចក្តី ។

## សម្ពន្ធ

**កុសលកម្មំ** វុត្តកម្មៈក្នុង **កត្តព្វំ**ៗ កិតបទ កម្មវាចកៈ (**កេនចិ** អនភិហិតកត្តា ) ក្នុង **កត្តព្វំ**, **សង្ឃោ** វុត្តកម្មក្នុង **ញាបេតព្វោ**ៗ

កិតបទ ហេតុកម្មវាចកៈ, **ព្យគ្គេន** និង **បជិតលេន** ទាំងពីរបទ វិសេសនៈរបស់ **ភិក្ខុនា។** អនភិហិតកត្តាក្នុង **ញ្ញាបេតព្វោ** ។

## ប្រែលោតប្រយោគ និង សម្ពន្ធ

**១. សូទេន ឱទនោ បចិយតេ** " វីបាយ គឺអ្នកគ្រូ ចំអិន " ។ **សាមិកេន សូទំ ឱទនោ បាចាបិយតេ** " វីបាយ គឺម្ចាស់ ញុំាងអ្នកគ្រូ ឱ្យចំអិន" ។ **ឱទនោ** វុត្តកម្មៈក្នុង **បាចាបិយតេ។** អាខ្យាតបទ ហេតុកម្មវាចកៈ **សូទំ** ការិតកម្មៈក្នុង **បាចាបិយតេ, សាមិកេន** អនភិហិតកត្តាក្នុង **បាចាបិយតេ** ។

**២. តុយ្ហំ សហាយកេន បណ្ណំ មម បេសិតំ** " វីសំបុត្រ គឺសំឡាញ់ របស់លោក បញ្ជូនមកហើយ ដើម្បីខ្ញុំ " ។ **បណ្ណំ** វុត្តកម្មៈក្នុង **បេសិតំ។** កិតបទ កម្មវាចកៈ **តុយ្ហំ** សាមិសម្ពន្ធក្នុង **សហាយ-កេន។** អនភិហិតកត្តាក្នុង **បេសិតំ, មម** សម្បទានៈក្នុង **បេសិតំ** ។

**៣. តយា បានីយំ បរិភោជនីយំ ឧបដ្ឋាបិតំ** " វីទឹកផឹក វីទឹកប្រើ គឺនាងចូលទៅដម្កល់ទុកហើយឬ ? " **បានីយំ** ក្តី **បរិភោជនីយំ** ក្តី វុត្តកម្មៈក្នុង **ឧបដ្ឋាបិតំ។** កិតបទ ហេតុកម្មវាចកៈ, **តយា** អនភិហិតកត្តាក្នុង **ឧបដ្ឋាបិតំ** ។

**៤. សុនន្ទាយ បោក្ខរណី ការិតា** " វីស្រះបោក្ខរណី គឺនាង

សុនន្ទា (ញុំាងជន) ឱ្យធ្វើហើយ”, **ចោទ្ទរណី** វុត្តកម្មៈក្នុង **ការិតា**ៗ កិតបទ ហេតុកម្មវាចកៈ , **សុនន្ទាយ** អនភិហិតកត្តាក្នុង **ការិតា** , ( **ជនំ** ការិតកម្មៈ ) ក្នុង **ការិតា** ។

## លំហាត់ប្រែលោតប្រយោគ និង សម្ពន្ធ

**១. កុលស្ស បុត្តោ ឬ បិយោ បុត្តោ ឬ មយា កតំ បុញ្ញំ ឬ**

**២. បុត្តោ ជាយតិ ឬ មាតា បុត្តំ ជនេតិ ឬ**

**៣. យេន បុគ្គលេន ធម្មស្សវនំ ការិតំ ឬ**

**៤. ចណ្ឌោ ហត្ថី យូថា និក្ខមិ ឬ**

**៥. ភគវា អនុបុព្វេន រាជគហំ បត្តោ ឬ**

**៦. កណ្ហានំ គោណានំ តចោ ឬ មហន្តំ ព្រហ្មុនោ វិមានំ ឬ**

**៧. ផលានិ រុក្ខា បតិតានិ ឬ**

**៨. ត្វំ អញ្ញំ វេជ្ជំ តិកិច្ឆាបេហិ ឬ**

**៩. កសកោ បណ្ណសាលំ ឃាបេសិ ឬ**

**១០. មយា បច្ចេកពុទ្ធស្ស បណ្ណសាលា ឃាបិតា ឬ**

## ទុតិយាវិភត្តិ

បទនាមនាម ដែលប្រកបផ្សំនិងទុតិយាវិភត្តិ មានអត្ថ ៦ យ៉ាង

សម្ពន្ធចូលនិងកិរិយា ដូច្នេះ

## ១.អវុត្តកម្មៈ

នេះជាឈ្មោះសម្រាប់ហៅ នាមនាម ដែលប្រកបដោយទុតិយាវិភត្តិ ដែលប្រែចេញអាយតនិបាតថា "នូវ" ចំពោះតែបទដែលគេត្រូវធ្វើ ភ្ជាប់ចូលនិងកិរិយាថា "ក្នុង" ដូចឧទាហរណ៍ តទៅនេះ

**១. សោ ធម្មំ សុណាតិ** "គេ ស្តាប់ នូវធម៌" **សោ** សយកត្តាក្នុង **សុណាតិ**។ អាខ្យាតបទ_កត្តុវាចកៈ **ធម្មំ** អវុត្តកម្មៈក្នុង **សុណាតិ** ។

**២. សូទោ ឱទនំ បចតិ** "អ្នកគ្រួ ចំអិន នូវបាយ" **សូទោ** សយកត្តាក្នុង **បចតិ**។ អាខ្យាតបទ_កត្តុវាចកៈ **ឱទនំ** អវុត្តកម្មៈក្នុង **បចតិ** ។

**៣.ថេរោ ធម្មំ ទេសេតិ** "ព្រះថេរៈ សំដែង នូវធម៌ " **ថេរោ** សយកត្តាក្នុង **ទេសេតិ**។ អាខ្យាតបទ_កត្តុវាចកៈ **ធម្មំ** អវុត្តកម្មៈក្នុង **ទេសេតិ** ។

**៤. មនុស្សា ធម្មំ សុណន្តិ** "មនុស្សទ. តែងស្តាប់ នូវធម៌ " **មនុស្សា** សយកត្តាក្នុង **សុណន្តិ**។ អាខ្យាតបទ_កត្តុវាចកៈ **ធម្មំ** អវុត្តកម្មៈក្នុង **សុណន្តិ** ។

**៥. យោ បាបំករោតិ, តំ បាបំ តស្ស វិបាកំ ទេតិ** " (បុគ្គល) ណាធ្វើនូវបាប, បាបនោះរមែងឱ្យនូវផល (ដល់បុគ្គល ) នោះ ", **យោ** វិសេសនៈរបស់ (**បុគ្គលោ**ៗ សយកត្តា ) ក្នុង **ករោតិ**ៗ អាខ្យាតបទ_កត្តុវាចកៈ **បាបំ** អវុត្តកម្មៈក្នុង **ករោតិ**, **តំ** វិសេសនៈ_របស់ **បាបំ**ៗ សយកត្តាក្នុង **ទេតិ**ៗ អាខ្យាតបទ_កត្តុវាចកៈ, **តស្ស** វិសេសនៈរបស់ (**បុគ្គលស្ស**ៗ សម្បទានៈ) ក្នុង **ទេតិ**, **វិបាកំ** អវុត្តកម្មៈក្នុង **ទេតិ** ។

## ២.សម្បាបុណិយកម្មៈ

នេះជាឈ្មោះសម្រាប់ហៅ ទុតិយាវិភត្តិ ត្រង់ដែលប្រែចេញអាយតនិបាតថា " កាន់ " ចំពោះតែបទដែលជាដំណើរ ឬជាទីទៅដល់សម្ពន្ធចូលនិងកិរិយាថា "ក្នុង " ឧទាហរណ៍

**១. គាមំ គច្ឆតិ** " (គេ ) ទៅកាន់ស្រុក " (**សោ** សយកត្តា) ក្នុង **គច្ឆតិ**ៗ អាខ្យាតបទ_កត្តុវាចកៈ **គាមំ** សម្បាបុណិយកម្មៈក្នុង **គច្ឆតិ** ។

**២. ភិក្ខូ អារាមំ គតា** " ភិក្ខុទ. ទៅហើយ កាន់អារាម " **ភិក្ខូ** សយកត្តាក្នុង **គតា**ៗ កិតបទ_កត្តុវាចកៈ **អារាមំ** សម្បាបុណិយកម្មៈក្នុង **គតា** ។

**៣. (តេ ជនា) និពន្ធំ យាគុភត្តំ វិហារមេវ បេសេន្តិ** " (វីជនទ. នោះ) តែងបញ្ជូនទៅ នូវបបរនិងបាយកាន់វត្តមែនពិត ជាប់មិនដាច់" **តេ** វិសេសនៈរបស់ **ជនា**ៗ សយកត្តាក្នុង **បេសេន្តិ**ៗ អាខ្យាតបទ_កត្តុវាចកៈ **យាគុភត្តំ** អវុត្តកម្មៈក្នុង **បេសេន្តិ**, **ឯវ**_សព្ទ អវធារណៈក្នុង **វិហារំ**ៗ សម្បាបុណិយកម្មៈក្នុង **បេសេន្តិ**, **និពន្ធំ** កិរិយាវិសេសនៈក្នុង **បេសេន្តិ** ។

**៤. ភិក្ខូ និពន្ធំ តមេវ គាមំ បិណ្ឌាយ បវិសន្តិ** "ភិក្ខុទ. រមែងចូលទៅកាន់ស្រុក នោះមែនពិត ដើម្បីបិណ្ឌបាត ជាប់មិនដាច់ " **ភិក្ខូ** សយកត្តាក្នុង **បវិសន្តិ**ៗ អាខ្យាតបទ_កត្តុវាចកៈ **និពន្ធំ** កិរិយា_វិសេសនៈក្នុង **បវិសន្តិ**, **ឯវ**_សព្ទ អវធារណៈក្នុង **តំ**ៗ វិសេសនៈរបស់ **គាមំ**ៗ សម្បាបុណិយកម្មៈក្នុង **បវិសន្តិ**, **បិណ្ឌាយ** សម្បទានៈក្នុង **បវិសន្តិ** ។

**៥. វិសាខា មហាឧបាសិកា ពុទ្ធុបដ្ឋានំ គច្ឆតិ** "មហាឧបាសិកាឈ្មោះវិសាខា តែងទៅកាន់ទីបំរើនៃព្រះពុទ្ធ" **វិសាខា** សញ្ញាវិសេសនៈរបស់ **មហាឧបាសិកា**ៗ សញ្ញីវិសេសយៈ និងជាសយកត្តាក្នុង **គច្ឆតិ**ៗ អាខ្យាតបទ_កត្តុវាចកៈ **ពុទ្ធុបដ្ឋានំ** សម្បា_បុណិយកម្មក្នុង **គច្ឆតិ** ។

## ៣.ការិតកម្មៈ

ពាក្យនេះជាឈ្មោះសម្រាប់ ហៅ ទុតិយាវិភត្តិ ត្រង់ដែល ប្រែចេញ អាយតនិបាតថា "ញ៉ាំង" ចំពោះតែបទ ដែលគេត្រូវប្រើឱ្យធ្វើដូចពាក្យថា "មាតាប្រើកូនឱ្យធ្វើការងារ" ត្រូវគ្នានិងពាក្យថា "មាតាញ៉ាំងកូនឱ្យធ្វើការងារ" ប្រើបានតែក្នុងប្រយោគ ហេតុកត្តុវាចកៈ និងហេតុកម្មវាចកៈ ត្រូវភ្ជាប់ពាក្យ ចូលនិងកិរិយាសព្ទថា "ក្នុង" ។

**១. សុរិយោ លោកំ ឱភាសេតិ** "ព្រះអាទិត្យ ញ៉ាំងលោកឱ្យភ្លឺ " **សុរិយោ** ហេតុកត្តាក្នុង **ឱភាសេតិ**១ អាខ្យាតបទហេតុកត្តុវាចកៈ **លោកំ** ការិតកម្មៈក្នុង **ឱភាសេតិ** ។

**២. សាមិកោ ទាសំ អគ្គឹ ជាលេតិ** "ម្ចាស់ញ៉ាំងខ្ញុំប្រុសឱ្យអុជ នូវភ្លើង" **សាមិកោ** ហេតុកត្តាក្នុង **ជាលេតិ**១ អាខ្យាតបទហេតុកត្តុវាចកៈ **ទាសំ** ការិតកម្មៈក្នុង **ជាលេតិ**, **អគ្គឹ** អវុត្តកម្មៈក្នុង **ជាលេតិ** ។

**៣. ភិក្ខុ សាមណេរំ ធម្មំ បរិយាបុណាបេតិ** "ភិក្ខុញ៉ាំងសាមណេរ ឱ្យរៀននូវធម៌ ", **ភិក្ខុ** ហេតុកត្តាក្នុង **បរិយាបុណាបេតិ**១ អាខ្យាតបទ-ហេតុកត្តុវាចកៈ **សាមណេរំ** ការិតកម្មៈក្នុង

**បរិយាបុណាបេតិ**, ធម្មំ អវុត្តកម្មៈក្នុង **បរិយាបុណាបេតិ ។**

**៤. សេដ្ឋិនា សូទេន ឱទនោ បាចាបិយតេ** " បាយ គឺសេដ្ឋីញ៉ាំងអ្នកគ្រួ ឱ្យចំអិន ", **ឱទនោ** វុត្តកម្មៈក្នុង **បាចាបិយតេ។** អាខ្យាតបទ_ហេតុកម្មវាចកៈ, **សេដ្ឋិនា** អនភិហិតកត្តាក្នុង **បាចាបិយតេ, សូទេន** តតិយាការិតកម្មៈក្នុង **បាចាបិយតេ ។**

**៥. ធម្មោ ភិក្ខុនា សាមណេរំ បរិយាបុណាបេតព្វោ** "ធម៌ គឺភិក្ខុញ៉ាំងសាមណេរ គប្បីឱ្យរៀន", **ធម្មោ** វុត្តកម្មៈក្នុង **បរិយាបុណាបេតព្វោ។** កិតបទ_ហេតុកម្មវាចកៈ **ភិក្ខុនា** អនភិហិត_កត្តាក្នុង **បរិយាបុណាបេតព្វោ, សាមណេរំ** ការិតកម្មៈក្នុង **បរិយាបុណាបេតព្វោ ។**

## ៤.អច្ចន្តសំយោគៈ

ពាក្យនេះ ជាឈ្មោះសម្រាប់ហៅទុតិយាវិភត្តិដែល ប្រែចេញ អាយតនិបាតថា "អស់..." ចំពោះសេចក្តីដែល កន្លងរំលងលុះរហូត ដូចប្រយោគថា :

**១. បុរិសោ យោជនំ ធាវតិ** "បុរសស្ទុះទៅហើយ អស់ យោជន៍ ១ " **បុរិសោ** សយកត្តាក្នុង **ធាវតិ។** អាខ្យាតបទ_កត្តុវាចកៈ **យោជនំ** អច្ចន្តសំយោគៈក្នុង **ធាវតិ ។**

**២. តីណិ វស្សានិ ភតឹ អកាសឹ** "(ខ្ញុំ) បានធ្វើហើយនូវការឈ្នួល អស់ឆ្នាំទ. បី ", ( **អហំ** សយកត្តា ) ក្នុង **អកាសឹ**ៗ អាខ្យាតបទ កត្តុវាចកៈ **ភតឹ** អវុត្តកម្មៈក្នុង **អកាសឹ**, **តីណិ** វិសេសនៈរបស់ **វស្សានិ**ៗ អច្ចន្តសំយោគៈក្នុង **អកាសឹ** ។

**៣.ទីបិនី អាគន្ត្វា តយោ វារេ បុត្តកេ ខាទិ** "មេខ្លាដំបងមកហើយ ទំពារស៊ីហើយនូវកូនទ. អស់វារៈទ. បីដង ", **ទីបិនី** សយកត្តាក្នុង **ខាទិ**ៗ អាខ្យាតបទ កត្តុវាចកៈ **អាគន្ត្វា** បុព្វកាលកិរិយាក្នុង **ខាទិ**, **តយោ** វិសេសនៈរបស់ **វារេ**ៗ អច្ចន្តសំយោគៈក្នុង **ខាទិ**, **បុត្តកេ** អវុត្តកម្មៈក្នុង **ខាទិ** ។

**៤.(សា) ទ្វេ វារេ គព្ភំ ឃាតេសិ** "(វា) ញុំាំងគភ៌ ឱ្យធ្លាក់ហើយ អស់វារៈទ. ពីរដង", **សា** ហេតុកត្តាក្នុង **ឃាតេសិ**ៗ អាខ្យាតបទ ហេតុកត្តុវាចកៈ, **ទ្វេ** វិសេសនៈរបស់ **វារេ**ៗ អច្ចន្តសំយោគៈក្នុង **ឃាតេសិ**, **គព្ភំ** ការិតកម្មៈក្នុង **ឃាតេសិ** ។

**៥. សោ សព្វរត្តឹ សមណធម្មំ អកាសិ** " លោកបានធ្វើហើយ នូវសមណធម៌អស់រាត្រីទាំងពួង ", **សោ** សយកត្តាក្នុង **អកាសិ**ៗ អាខ្យាតបទ_កត្តុវាចកៈ, **សព្វរត្តឹ** អច្ចន្តសំយោគៈក្នុង **អកាសិ**, **សមណធម្មំ** អវុត្តកម្មៈក្នុង **អកាសិ** ។

## ៥.អកថិតកម្មៈ

ពាក្យនេះសម្រាប់ហៅទុតិយាវិភត្តិ ដែលប្រែចេញ អាយតនិ-បាតថា "នឹង, ឬ ចំពោះ" គឺជាទីទទួលពាក្យរបស់អ្នកនិយាយ ។ ឯវិធីដែល ប្រែថា "នឹង" ឬ " ចំពោះ " បាននោះលុះតែមាន ទុតិយាវិភត្តិពីរនៅជិតគ្នា, កាលបើទុតិយាវិភត្តិមួយជា " អកថិតកម្មៈ " យ៉ាងនេះត្រង់បទទុតិយាវិភត្តិដែលប្រែថា "នូវ..." ដែលជាអវុត្តកម្មៈ នោះត្រឡប់ទៅជា ហៅថា " កថិតកម្ម " ទៅវិញដូច្នេះ ។

**១. ភគវន្តំ ឯតទវោច** "( ភិក្ខុនោះ ) បានពោលហើយនូវ-ពាក្យនុ៎ះ នឹងព្រះដ៏មានព្រះភាគ" ។ (**សោ** វិសេសនៈរបស់ **ភិក្ខុ**ៗ សយកត្តា)ក្នុង **អវោច**ៗ អាខ្យាតបទ-កត្តុវាចកៈ, **ភគវន្តំ** អកថិត-កម្មៈក្នុង **អវោច**, **ឯតំ** វិសេសនៈរបស់ (**វចនំ**ៗ កថិតកម្មៈ) ក្នុង **អវោច** ។

**២. អាចរិយោ សិស្សំ ឯតំ វចនំ អាហ** " អាចារ្យពោលហើយនូវពាក្យនេះ នឹងសិស្ស ", **អាចរិយោ** សយកត្តាក្នុង **អាហ**ៗ អាខ្យាតបទ-កត្តុវាចកៈ **សិស្សំ** អកថិតកម្មៈក្នុង **អាហ**, **ឯតំ** វិសេសនៈរបស់ **វចនំ**ៗ កថិតកម្មៈក្នុង **អាហ** ។

**៣. តាបសោ ហិមវន្តតោ អាគន្ត្វា កុម្ភការំ ឯករត្តិវាសំ**

**យាចិ** "តាបសមកហើយ អំពីព្រៃហេមពាន្ត សូមហើយនូវការស្នាក់នៅ អស់រាត្រីមួយ នឹងជាងស្នូនផ្ទាំង", **តាបសោ** សយកត្តាក្នុង **យាចិ**។ អាខ្យាតបទ_កត្តុវាចកៈ, **ហិមវន្តតោ** អបាទានៈក្នុង **អាគន្ត្វា**។ បុព្វកាលកិរិយាក្នុង **យាចិ**, **ភូម្ពការំ** អកថិតកម្មៈក្នុង **យាចិ**, **ឯករត្តិវាសំ** កថិតកម្មៈក្នុង **យាចិ** ។

**៤. (មហាបាលោ) សត្ថារំ បព្វជ្ជំ យាចិ** " (**មហាបាល**) សុំហើយនូវផ្នួសនឹងព្រះសាស្ដា " , **មហាបាលោ** សយកត្តាក្នុង **យាចិ**។ អាខ្យាតបទ_កត្តុវាចកៈ , **សត្ថារំ** អកថិតកម្មៈក្នុង **យាចិ** , **បព្វជ្ជំ** កថិតកម្មៈក្នុង **យាចិ** ។

**៥. គច្ឆ នំ ឱាយជ្ជំ យាចាហិ** " ឯង ចូរទៅចូរសុំ នូវកេរមតីក នឹងព្រះអង្គ ", (**ត្វំ** សយកត្តា) ក្នុង **គច្ឆ** និង **យាចាហិ**។ អាខ្យាតបទ_កត្តុវាចកៈ, **នំ** អកថិតកម្មៈក្នុង **យាចាហិ** , **ឱាយជ្ជំ** កថិតកម្មៈក្នុង **យាចាហិ** ។

## ៦.កិរិយាវិសេសនៈ

**បទ** ដែលសម្រាប់ធ្វើកិរិយាឱ្យមានសេចក្ដី ប្លែក ជាង ប្រក្រតី ដូចជាគុណរបស់កិរិយាសព្ទហៅថា " កិរិយាវិសេសនៈ " វេលាប្រែមិនចេញអាយតនិបាតទេ គឺប្រែតែរូបសព្ទប៉ុណ្ណោះ ដូចឧទាហរណ៍តទៅនេះ :

**១. ធម្មចារី សុខំ សេតិ** "បុគ្គលអ្នកប្រព្រឹត្តធម៌ដេកសប្បាយ", **ធម្មចារី** សយកត្តាក្នុង **សេតិ**ៗ អាខ្យាតបទ_កត្តុវាចកៈ, **សុខំ** កិរិយា_វិសេសនៈក្នុង **សេតិ** ។

**២.(សោ) ពាឡ្ហំ រោទតិ** " (វា) យំ ខ្លាំង " (សោ សយកត្តា) ក្នុង **រោទតិ**ៗ អាខ្យាតបទ_កត្តុវាចកៈ, **ពាឡ្ហំ** កិរិយាវិសេសនៈក្នុង **រោទតិ** ។

**៣. ឧទកកីឡំ កីឡិ** "( គេ ) លេងហើយ លេងនូវទឹក" ( សោ សយកត្តា) ក្នុង **កីឡិ**ៗ អាខ្យាតបទ_កត្តុវាចកៈ, **ឧទកកីឡំ** កិរិយា_វិសេសនៈក្នុង **កីឡិ** ។

**៤. មហាវិរវំ វិរវិ** "(វា) ស្រែកហើយ ស្រែកខ្លាំង" (សោ សយកត្តា) ក្នុង **វិរវិ**ៗ អាខ្យាតបទ_កត្តុវាចកៈ , **មហាវិរវំ** កិរិយាវិ_សេសនៈក្នុង **វិរវិ** ។

**៥. តថាគតោ និគ្រោធមហាវិហារេ ឯកមេវ វស្សាវាសំ វសិ** "ព្រះតថាគតគង់នៅហើយ គង់នៅចាំវស្សាតែមួយគត់ ក្នុងមហាវិហារ ឈ្មោះនិគ្រោធ" **តថាគតោ** សយកត្តាក្នុង **វសិ**ៗ អាខ្យាតបទ_កត្តុវាចកៈ , **និគ្រោធមហាវិហារេ** វេសយិកាធារៈក្នុង **វសិ**, **ឯវ**_សព្ទ អវធារណៈក្នុង **ឯកំ**ៗ វិសេសនៈរបស់ **វស្សាវាសំ**ៗ

កិរិយាវិសេសនៈក្នុង **វសិ** ។

## លំហាត់ប្រែលោតប្រយោគ និង សម្ពន្ធ

**១. សាមិកោ សុនំ ឱទនំ បាចេតិ ។**

**២. សត្ថារំ ឧបសង្កមិត្វា ទានំ ទេហិ ធម្មំ សុណាហិ បញ្ហំ បុច្ឆាហិ ។**

**៣. សោ មយ្ហំ សន្តិកំ កញ្ញំយេវ បហិណិស្សតិ ។**

**៤. លដុកិកាបិ សកុណិកា ហត្ថិនាគំ ជីវិតក្ខយំ បាបេសិ ។**

**៥. សោ ថេរំ វន្ទិត្វា អឌ្ឍមាសមត្តំ វត្តប្បដិវត្តំ អកាសិ ។**

**៦. សោ ខេត្តំ វិភជិត្វា ពហូ មនុស្សេ ហត្ថកម្មំ យាចិ ។**

**៧. តេ វស្សសហស្សានិ បញ្ច សីលានិ រក្ខឹសុ ។**

**៨. តេ ភគវន្តំ ឯតទវោចុំ ។**

**៩. ធម្មចារី សុខំ សេតិ, បាបការី ទុក្ខំ សេតិ ។**

**១០. ឥមេ សត្ត ទិវសេ សូករេ មារេតិ ។**

## តតិយាវិភត្តិ

បទនាមនាម ដែលប្រកបផ្សំនិងតតិយាវិភត្តិ មានអត្ថ ៦ យ៉ាង សម្ពន្ធចូលនិងកិរិយាក៏មាន ចូលនិងនាមនាមក៏មាន, ចូលនិង និបាតសព្ទ គឺ **សហ** ឬ **សទ្ធឹ** ក៏មាន ដូច្នេះ :

## ១.ករណៈ

ពាក្យនេះសម្រាប់ហៅឈ្មោះតតិយាវិភត្តិ ដែលប្រែចេញអាយតនិបាតថា "ដោយ" ជាបទជាប់ទាក់ទង ដល់វត្ថុជាគ្រឿងធ្វើ ត្រូវសម្ពន្ធថា "ករណៈ" ភ្ជាប់ពាក្យថា "ក្នុង" ដូច្នេះ ។

១. **កាយេន កម្មំ ករោតិ** "(គេ) ធ្វើនូវអំពើដោយកាយ "(សោ សយកត្តា) ក្នុង **ករោតិ**ៗ អាខ្យា_កត្តុ., **កាយេន** ករណៈក្នុង **ករោតិ**, **កម្មំ** អវុត្តកម្មៈក្នុង **ករោតិ** ។

២. **កស្សកោ** កដ្ឋកណ្ឌកេន **សស្សំ** **វបតិ** "អ្នកស្រែស្ទូងនូវសន្ទូង ដោយឈើច្រាន " **កស្សកោ** សយកត្តាក្នុង **វបតិ**ៗ អាខ្យា_កត្តុ., កដ្ឋកណ្ឌកេន ករណៈក្នុង **វបតិ** , **សស្សំ** អវុត្តកម្មៈក្នុង **វបតិ** ។

៣. **នារី ទាត្តេន ធញ្ញំ លុនាតិ** "នារីច្រូត នូវស្រូវដោយកណ្ដៀវ" **នារី** សយកត្តាក្នុង **លុនាតិ**ៗ អាខ្យា_កត្តុ., **ទាត្តេន** ករណៈក្នុង **លុនាតិ**, **ធញ្ញំ** អវុត្តកម្មៈក្នុង **លុនាតិ** ។

៤. **ព្រាហ្មណស្ស សកលសរីរំ បីតិយា បរិប្ផុរិ** "សរីរៈទាំងមូល របស់ព្រាហ្មណ៍ពេញប្រៀបហើយ ដោយបីតិ" **ព្រាហ្មណ~ស្ស** សាមិសម្ពន្ធក្នុង **សកលសរីរំ**ៗ សយកត្តាក្នុង **បរិប្ផុរិ**ៗ អាខ្យាត_

កត្តុ., **បីតិយា**ករណៈក្នុង **ចរិប្ជូរិ** ។

**៥. តេ ទយប្បត្តេ យះពន្ធនេន ពន្ធិំសុ** "(ញាតិទ.) ចង ហើយ (នូវកូនទ.) នោះ ដែលដល់ហើយ នូវវ័យ ដោយចំណងគឺផ្ទះ" (**ញាតយោ** សយកត្តា) ក្នុង **ពន្ធិំសុ**។ អាខ្យា.កត្តុ., **តេ** ក្តី **ទយប្បត្តេ** ក្តី វិសេសនៈរបស់ **បុត្តេ**។ អវុត្តកម្មៈក្នុង **ពន្ធិំសុ**, **យះពន្ធនេន** ករណៈក្នុង **ពន្ធិំសុ** ។

## ២.តតិយាវិសេសនៈ

នេះជាឈ្មោះបទនាមនាមដែលប្រកបដោយតតិយាវិភត្តិ ត្រង់ ប្រែថា "ដោយនូវ" ឬ "តាម" ជាគ្រឿង ធ្វើឱ្យប្លែកឬជាប់ដោយផ្លូវ ដោយទំនង ត្រូវសម្ពន្ធភ្ជាប់ពាក្យថា "ក្នុង" ដូច្នេះ

**១. ពុទ្ធោ តបតិ តេជសា** "ព្រះពុទ្ធរុងរឿង ដោយនូវ តេជះ" **ពុទ្ធោ** សយកត្តាក្នុង **តបតិ**។ អាខ្យាត.កត្តុ., **តេជសា** តតិយាវិសេសនក្នុង **តបតិ** ។

**២. មម វចនេន ករោហិ** "(ឯង) ចូរធ្វើតាមពាក្យ នៃ អញ", (**ត្វំ** សយកត្តា) ក្នុង **ករោហិ**។ អាខ្យាត.កត្តុ., **មម** សាមិសម្ពន្ធ ក្នុង **វចនេន**។ តតិយាវិសេសនក្នុង **ករោហិ** ។

**៣. ទ្វារេន និក្ខមតិ** "(គេ) ចេញទៅតាមទ្វារ" (**សោ**

សយកត្តា) ក្នុង **និក្ខមតិ** ៗ អាខ្យាត_កត្តុ., **ទ្វារេន** តតិយាវិសេសនៈ ក្នុង **និក្ខមតិ** ។

**៤. មយា ភត្តបត្តម្ភេន សោ ទេវសិកំ ជីវតិ** "(វា) រស់នៅសព្វថ្ងៃ ដោយសារតែសេចក្តីទំនុកបំរុង ដែលខ្ញុំធ្វើហើយ" **សោ** សយកត្តាក្នុង **ជីវតិ**ៗ អាខ្យាត_កត្តុ., **មយា** អនភិហិតកត្តាក្នុង **ភត**, **ភត្តបត្តម្ភេន** តតិយាវិសេសនៈក្នុង **ជីវតិ**, **ទេវសិកំ** កិរិយា_វិសេសនៈក្នុង **ជីវតិ** ។

**៥. ហំសា អាកាសេន គមឹសុ** " ហង្សទ. ទៅហើយ តាមអាកាស" **ហំសា** សយកត្តាក្នុង **គមឹសុ**ៗ អាខ្យាត_កត្តុ., **អាកាសេន** តតិយាវិសេសនៈក្នុង **គមឹសុ** ។

## ៣.អនភិហិតកត្តា

នេះជាឈ្មោះបទនាមនាម ដែលប្រកបដោយតតិយាវិភត្តិ ត្រង់ប្រែថា " គឺ " ឬ " ដែល " ក្នុងប្រយោគកម្មវាចកៈ_ភាវវាចកៈ និងហេតុកម្មវាចកៈ ត្រូវភ្ជាប់ពាក្យថា "ក្នុង" ។

**១. ចិត្តេន នីយតិ លោកោ** " សត្វលោក គឺចិត្តដឹកនាំទៅ " **លោកោ** វុត្តកម្មៈក្នុង **នីយតិ**ៗ អាខ្យាតបទ_កម្មវាចកៈ, **ចិត្តេន** អនភិហិតកត្តាក្នុង **នីយតិ** ។

**២. អធិគតោ ខោ ម្យាយំ ធម្មោ** " ធម៌នេះ ដែលតថាគត ត្រាស់ដឹងហើយ មែនពិត ", **ធម្មោ** វុត្តកម្មៈក្នុង **អធិគតោ។** កិត. កម្ម., **ខោ**-សព្ទ បទបូរណៈក្នុង **អធិគតោ**, **មេ** អនភិហិតកត្តាក្នុង **អធិគតោ**, **អយំ** វិសេសនៈរបស់ **ធម្មោ** ។

**៣. ន បុនេវំ តយា កត្តព្វំ** " គឺអ្នកឯង មិនត្រូវធ្វើយ៉ាងនេះទៀតឡើយ" **តយា** អនភិហិតកត្តាក្នុង **កត្តព្វំ។** កិត.ភាវ. , **ន**-សព្ទ បដិសេធក្នុង **កត្តព្វំ** , **បុន** ក្តី **ឯវំ** ក្តី កិរិយាវិសេសនៈរបស់ **កត្តព្វំ** ។

**៤. សត្ថា តុម្ហេហិ ខមាបេតព្វោ** "ព្រះសាស្តា គឺអ្នកទ. គប្បីឱ្យអត់ទោស" **សត្ថា** វុត្តកម្មៈក្នុង **ខមាបេតព្វោ។** កិត.ហេតុកម្ម., **តុម្ហេហិ** អនភិ.ក្នុង **ខមាបេតព្វោ** ។

**៥. អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា បារិសុទ្ធិំ ទាតុំ** "ម្នាលភិក្ខុទ. តថាគតអនុញ្ញាត ដើម្បីគឺភិក្ខុមានជំងឺឱ្យ នូវបារិសុទ្ធិ " **ភិក្ខវេ** អគារវាលបនៈ, **អហំ** សយកត្តាក្នុង **អនុជានាមិ។** អាខ្យាត. កត្តុ., **គិលានេន** វិសេនៈរបស់ **ភិក្ខុនា។** អនភិហិតកត្តាក្នុង **ទាតុំ។** តុមត្ថសម្បទានក្នុង **អនុជានាមិ** , **បារិសុទ្ធិំ** អវុត្តកម្មៈក្នុង **ទាតុំ** ។

## ៤.ហេតុ

ពាក្យនេះ ជាឈ្មោះតតិយាវិភត្តិ ដែលប្រែថា " ហេតុ " ឬ

"ព្រោះ " ឬ "ព្រោះតែ" ក្នុងទីដែលទាក់ទងប្រយោជន៍ ឬ សេចក្ដីចំរើនជាតួផល ដែលសម្រេចមកពីហេតុត្រូវភ្ជាប់ពាក្យថា "ក្នុង" ដូចតទៅ :

**១. សក្ការេន បន សោ តត្ថ វសតិ** "បានជាគាត់នៅក្នុងទីនេះព្រោះតែសក្ការៈ " **បន**_សព្ទ គរហត្ថវាចកៈ **សោ** សយកត្តាក្នុង **វសតិ**ៗ អាខ្យាតបទ_កត្តុវាចកៈ **សក្ការេន** ហេតុក្នុង **វសតិ**, **តត្ថ** វិសេសនៈរបស់ **ឋានេ**ៗ វេសយិកាធារៈក្នុង **វសតិ** ។

**២. លាភេន ឧន្នតោ លោកោ អលាភេន ច ឱនតោ** "សត្វលោក មានចិត្តខ្ពស់ឡើង ព្រោះលាភ ក៏សត្វលោកមានចិត្តទ្រោមចុះ ព្រោះមិនមានលាភ" **លោកោ** សយកត្តាក្នុង **ឧន្នតោ**ៗ កិតបទ_កត្តុវាចកៈ **លាភេន** ហេតុក្នុង **ឧន្នតោ**, **ច**_សព្ទ វាក្យារម្ភ-វាចកៈ **លោកោ** សយកត្តាក្នុង **ឱនតោ**ៗ កិតបទ_កត្តុវាចកៈ **អលាភេន** ហេតុក្នុង **ឱនតោ** ។

**៣. តតោ នំ ទុក្ខមន្វេតិ** "សេចក្ដីទុក្ខរមែងជាប់តាម នូវបុគ្គលនោះ ព្រោះទុច្ចរិតមានប្រការបីនោះ" **ទុក្ខំ** សយកត្តាក្នុង **អន្វេតិ**ៗ អាខ្យាតបទ_កត្តុវាចកៈ **តំ** វិសេសនៈរបស់ **បុគ្គលំ**ៗ អវុត្តកម្មៈក្នុង **អន្វេតិ**, **តតោ** វិសេសនៈរបស់ **តិវិធទុច្ចរិតតោ**ៗ ហេតុក្នុង

អន្វេតិ ។

៤. អម្ម តយា ភតសស្សំ នេវ អច្ចោទកេន នស្សតិ ន អនោទកេន នស្សតិ “ម្នាលនាង សន្ទូងដែលនាងធ្វើហើយមិនវិនាសមែនពិតព្រោះទឹកក្រៃពេក មិនវិនាស ព្រោះកិរិយាមិនមានទឹក” អម្ម អគារវាលបនៈ តយា អនភិហិតកត្តាក្នុង ភត , ភតសស្សំ សយកត្តាក្នុង នស្សតិ និង នស្សតិ។ អាខ្យាតបទ_កត្តុវាចកៈ ឯវ_សព្ទ អវធារណៈក្នុង ន។ ទាំងពីរសព្ទបដិសេធក្នុង នស្សតិ និង នស្សតិ ។ អច្ចោទកេន និង អនោទកេន ហេតុក្នុង នស្សតិ និង នស្សតិ ។

៥. អយំ តវ ឥស្សរិយភយេន គព្ភបាតនភេសជ្ជំ យោជេត្វា ទេតិ “ស្រីនេះផ្សំហើយនូវថ្នាំសម្រាប់ញុំាងគភ៌អោយធ្លាក់ ឱ្យដល់នាងព្រោះ កិរិយាខ្លាចអំពីភាវៈនៃបុគ្គលជាឥស្សរៈ” អយំ វិសេសនៈរបស់ ឥត្ថី។ សយកត្តាក្នុង ទេតិ។ អាខ្យាតបទ_កត្តុវាចកៈ តវ សម្បទានក្នុង ទេតិ, ឥស្សរិយភយេន ហេតុក្នុង ទេតិ , គព្ភបាតនភេសជ្ជំ អវុត្តកម្មៈក្នុង យោជេត្វា។ បុព្វកាលកិរិយាក្នុង ទេតិ ។

## ៥.ឥត្ថម្ភូតៈ

ពាក្យនេះជាឈ្មោះតតិយាវិភត្តិដែលប្រែថា "មាន" ហាក់ដូចជាគុណរបស់បឋមាឯកវចនៈ មានលំនាំដូចជាប្រយោគ លក្ខណៈ និង អនាទរៈដែលជ្រែកចូលមក ។ ឯវិធីសម្ពន្ធក៍មិនបានចូល នឹង នាម ឬកិរិយាក្នុងប្រយោគទេ, តួនាមត្រូវសម្ពន្ធថា "**ឥត្ថម្ភូតៈ**" ចូល និងកិរិយារបស់ខ្លួន ដែលប្រើកិរិយាកិតកៈមានលិង្គ, វចនៈ, វិភត្តិស្មើគ្នាជូនកាលមិនមាន កិរិយាឥត្ថម្ភូតៈ ក៏គួរដាក់បញ្ចូលមកហើយសម្ពន្ធថា "**ឥត្ថម្ភូតកិរិយា**" ដូច្នេះ

**១. មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា** "បើ (បុគ្គល) មានចិត្ត គឺទោសប្រទូស្តហើយ ពោលក្តី ធ្វើក្តី" **ចេ**-សព្ទ បរិកប្បត្ថៈ (**បុគ្គលោ** សយកត្តា) ក្នុង **ភាសតិ, ករោតិ**ៗ អាខ្យា-កត្តុ., **មនសា** ឥត្ថម្ភូតៈក្នុង **បទុដ្ឋេន**ៗ ឥត្ថម្ភូតៈកិរិយា, **វា** ទាំងពីរ សព្ទ បទវិកប្បក្នុង **ភាសតិ, ករោតិ** ។

**២. យោ បន ភិក្ខុ ឩនបញ្ចពន្ធនេន បត្តេន អញ្ញំ បត្តំ ចេតាបេយ្យ** "ភិក្ខុឯណាមួយមានបាត្រ មានស្នាមមិនទាន់ដល់ប្រាំ អន្លើ (កាលមាន) គប្បីសុំបាត្រថ្មី" **បន**-សព្ទ វាក្យារម្ភ, **យោ** វិសេសនៈរបស់ **ភិក្ខុ**ៗ សយកត្តាក្នុង **ចេតាបេយ្យ**ៗ អាខ្យា.កត្តុ., **ឩនបញ្ច**-

**ពន្ធនេន** វិសេសនៈរបស់ **បត្តេន**។ ឥត្ថម្ភូតៈក្នុង (**សមានេន**)។ ឥត្ថម្ភូ-តៈកិរិយា, **នទី** វិសេសនៈរបស់ **បត្តិ**។ អវុត្តកម្មៈក្នុង **ចេតាបេយ្យ** ។

**៣. សា ទាសី ភិន្នេន សីសេន លោហិតេន បគ្ឃរន្តេន បដិវិស្សកានំ ឧជ្ឈាបេសិ** "ទាសី នោះមានក្បាល បែកហើយ មានឈាមកាលហូរចេញ ញុំាងជនអ្នកស្និទ្ធស្នាលទាំងឡាយ ឱ្យខ្វាត់ខ្វាយហើយ" ។

**៤. សា បសន្នេន ចិត្តេន កាលំ កត្វា តិកាវុតេន អត្តភាវេន និព្វត្តតិ** "នាងមានចិត្តជ្រះថ្លាហើយធ្វើមរណកាលហើយ កើតដោយអត្តភាពបីគាវុត" **សា** សយកត្តាក្នុង **និព្វត្តតិ**។ អាខ្យា-កត្តុ., **ចិត្តេន** ឥត្ថម្ភូតៈក្នុង **បសន្នេន**។ ឥត្ថម្ភូតៈកិរិយា, **កាលំ** អវុត្តកម្មៈក្នុង **កត្វា**។ បុព្វកាលកិរិយាក្នុង **និព្វត្តតិ**, **តិកាវុតេន** វិសេសនៈរបស់ **អត្តភាវេន**។ករណៈក្នុង **និព្វត្តតិ** ។

**៥. តំខណញ្ញេវ រាជា ឧក្កាហិ ធារិយមានាហិ តត្ថ គច្ឆតិ** " ក្នុងខណៈនោះឯងព្រះរាជាមានគប់ភ្លើងទ. គឺជនកាលទ្រោលទ្រង់យាងទៅ ក្នុងទីនោះ" **ឯវ**-សព្ទ អវធារណៈក្នុង **តំ ខណំ**។ ទុតិយាបសង្គកាលត្ថសត្តមី **រាជា** សយកត្តាក្នុង **គច្ឆតិ**។ អាខ្យា.កត្តុ., **ឧក្កាហិ** ឥត្ថម្ភូតៈក្នុង **ធារិយមានាហិ**។ ឥត្ថម្ភូតៈកិរិយា, **តត្ថ** វិសេសនៈ

របស់ **ឋានៃ១** វេសយិកាធារៈក្នុង **គច្ឆតិ** ។

## ៦.សហត្ថតតិយា

ពាក្យនេះ ជាឈ្មោះតតិយាវិភត្តិ ប្រែថា "ដោយ" ក្នុងប្រយោគមាន សេចក្តីចូលរួមជាមួយ **សហ** ឬ **សទ្ធឹ** ត្រូវសម្គាល់ថា "**សហត្ថ~តតិយា**" ភ្ជាប់ពាក្យថា "ក្នុង" គប្បីសង្កេតឧទាហរណ៍ ដូចតទៅនេះ : **សមេតាយស្មា សង្ឃេន សទ្ធឹ** ប្រែបាន ៣ យ៉ាងគឺ :

**១. ទព្វសមវាយវិសេសនៈ** " **ភិក្ខុ** វីភិក្ខុ **អាយស្មា** ដ៏មានអាយុ **សទ្ធឹ** មួយអន្លើ **សង្ឃេន** ដោយសង្ឃ **សមេតុ** ចូរព្រមព្រៀង", **អាយស្មា** វិសេសនៈរបស់ **ភិក្ខុ១** សយកត្តាក្នុង **សមេតុ១** អាខ្យា. កត្តុ., **សង្ឃេន** សហត្ថតតិយាក្នុង **សទ្ធឹ១** ទព្វសមវាយក្នុង **ភិក្ខុ** ។

**២. គុណសមវាយវិសេសន** "**អាយស្មា** វីភិក្ខុដ៏មានអាយុ **សទ្ធឹ** មួយអន្លើ........ **សង្ឃេន**........ **សមេតុ**........", **អាយស្មា** សយកត្តាក្នុង **សមេតុ១** អាខ្យា.កត្តុ., **សង្ឃេន** សហត្ថតតិយាក្នុង **សទ្ធឹ១** គុណសមវាយក្នុង **អាយស្មា**។

**៣. កិរិយាសមវាយវិសេសន** "**អាយស្មា** វីភិក្ខុដ៏... **សមេតុ... សទ្ធឹ... សង្ឃេន...**", **អាយស្មា** សយកត្តាក្នុង **សមេតុ១** អាខ្យា.កត្តុ., **សង្ឃេន** សហត្ថតតិយាក្នុង **សទ្ធឹ១** កិរិយាសមវាយក្នុង

**សមេត្ត** ។

**៤. មយា សទ្ធឹ តយា គន្តព្វំ** "ឯងត្រូវទៅជាមួយនឹងអញ", **តយា** អនភិហិតកត្តាក្នុង **គន្តព្វំ** ៗ កិតបទ_ភាវវាចកៈ, **មយា** សហត្ថ_តតិយាក្នុង **សទ្ធឹ** ៗ កិរិយាសមវាយក្នុង **គន្តព្វំ** ។

**៥. សិរីមំបិ អត្តនា សទ្ធឹ ន គច្ឆតិ** "សូម្បីសិរីវៈមិនទៅជាមួយនឹងខ្លួន", **បិ**_សព្ទ អបេក្ខត្ថក្នុង **សិរីំ** ៗ សយកត្តាក្នុង **គច្ឆតិ** ៗ អាខ្យា.កត្តុ., **អត្តនា** សហត្ថតតិយាក្នុង **សទ្ធឹ** ៗ កិរិយាសមវាយក្នុង **គច្ឆតិ** ។

## លំហាត់ប្រែលោតប្រយោគ និង សម្ពន្ធ

១. តុម្ហំ បុត្តោ ពាលេន បហតោ ។

២. សេដ្ឋិនោ ទាសេន អាហារោ បច្ចតេ ។

៣. សេដ្ឋិនោ ទាសោ អាហារំ បច្ចតិ ។

៤. មនុស្សា នាវាយ នទឹ តរន្តិ ។

៥. ភគវា អនុបុព្វេន រាជគហំ បត្តោ ។

៦. សា ទសមាសច្ចយេន បុត្តំ វិជាយិ ។

៧. អហំ ខោ អាកិណ្ណោ វិហរាមិ ហត្ថីហិ ហត្ថិនីហិ ។

**៨. តុម្ហេ មម វចនេន ទសពលញ្ច អសីតិមហាថេរេ ច វន្ទថ ២**

**៩. សាបិ តំ សុត្វា ឧទកពិន្ទូហិ បគ្ឃរន្តេហេវ អស្សុល្លិខិតេហិ កេសេហិ វេគេន គច្ឆតិ ២**

**១០. សព្វេវ សហ បដិសម្ភិទាហិ អរហត្តំ បាបុណឹសុ ២**

## ចតុត្ថីវិភត្តិ

**បទនាមនាម** ដែលប្រកបដោយបទចតុត្ថីវិភត្តិមានអត្ថ ៣ យ៉ាង ហៅថា **សម្បទាន** សម្ពន្ធចូលនឹងកិរិយាដូច្នេះ

១. ជាទីអោយ ឬជាទីទទួលអំណោយ ប្រែថា "ដល់"

ឧ. **សង្ឃស្ស ទានំ ទេតិ** "(ទាយក) ឱ្យនូវទានដល់សង្ឃ " (**ទាយកោ** សយកត្តា) ក្នុង **ទេតិ**១ អាខ្យាត.កត្តុ., **សង្ឃស្ស** សម្បទានក្នុង **ទេតិ**, **ទានំ** អវុត្តកម្មៈក្នុង **ទេតិ** ។

២. ជាទីបំរុង, ជាទីផ្ញើ ឬជាទីបញ្ជូន ប្រែថា "ដើម្បី " ឬ "បំរុង"

ឧ. **ភិក្ខុសង្ឃស្ស អាសនានិ បញ្ញាបេតិ** "( គេ ) ញុំាងមនុស្សឱ្យក្រាលនូវអាសនៈទ. ដើម្បី ឬ បំរុងភិក្ខុសង្ឃ", (**សោ** ហេតុកត្តា) ក្នុង **បញ្ញាបេតិ**១ អាខ្យាត.ហេតុកត្តុ., **ភិក្ខុសង្ឃស្ស**

សម្បទានក្នុង **បញ្ញាបេតិ**, **អាសនានិ** អវុត្តកម្មៈក្នុង **បញ្ញាបេតិ** ។

៣. ជាទីត្រូវគេប្រទូស្ត, គេបៀតបៀន ប្រែថា " នឹង " ឬ " ចំពោះ "

១. **យោ អប្បទុដ្ឋស្ស នរស្ស ទុស្សតិ** "អ្នកណាប្រទូស្ត ចំពោះឬ នឹងមនុស្សដែលមិនប្រទូស្ត" **យោ** សយកត្តាក្នុង **ទុស្សតិ**។ អាខ្យាត.កត្តុ., **អប្បទុដ្ឋស្ស** វិសេសនៈរបស់ **នរស្ស**។ សម្បទានក្នុង **ទុស្សតិ** ។

៤. **អថ តេ គន្ត្វា តថាគតស្ស អារោចេសុំ** "គ្រានោះ លោកទ. ទៅហើយ ក្រាបទូលហើយ ដល់ព្រះតថាគត", **អថ** កាលត្ថសត្តមី **តេ** សយកត្តាក្នុង **អារោចេសុំ**។ អាខ្យាត.កត្តុ, **គន្ត្វា** បុព្វកាលកិរិយាក្នុង **អារោចេសុំ**, **តថាគតស្ស** សម្បទានក្នុង **អារោចេសុំ** ។

៥. **សោ តំ អាហរិត្វា បុត្តស្ស ភេសជ្ជំ ករោតិ** "ព្រាហ្មណ៍ នោះនាំមកហើយ នូវវត្ថុមានសំបកឈើជាដើមនោះ ធ្វើនូវភេសជ្ជៈ ដើម្បីកូន " **សោ** វិសេសនៈរបស់ **ព្រាហ្មណោ**។ សយកត្តាក្នុង **ករោតិ**។ អាខ្យាត.កត្តុ., **តំ** វិសេសនៈរបស់ (**វក្ខតចាទឹ**)។ អវុត្តកម្មៈ ក្នុង **អាហរិត្វា**។ បុព្វកាលកិរិយាក្នុង **ករោតិ**, **បុត្តស្ស** សម្បទានៈក្នុង

**ករោតិ**, **ភេសជ្ជំ** អវុត្តកម្មៈក្នុង **ករោតិ** ។

## បញ្ចមីវិភត្តិ

**បទនាមនាម** ដែលប្រកបដោយបញ្ចមីវិភត្តិមានអត្ថ ៣ យ៉ាង ច្រើនតែសម្ពន្ធចូលនឹងកិរិយាដូច្នេះ :

១.ជាដែនចេញ ឬជាទីគេត្រូវវៀរលែង ប្រែថា "អំពី" ឬ "ចាក" ហៅថា "**អបាទាន**" ។

ឧ. **បាបា ចិត្តំ និវារយេ** "(បុគ្គល) គប្បីឃាត់ នូវចិត្តចាក-បាប " **បុគ្គលោ** សយកត្តាក្នុង **និវារយេ** ។ អាខ្យាត.កត្តុ., **បាបា** អបាទានក្នុង **និវារយេ**, **ចិត្តំ** អវុត្តកម្មៈក្នុង **និវារយេ** ។

២.ជាដែនប្រៀបធៀបឱ្យដឹងថា លើសឬថយជាងគ្នា ប្រែថា "ជាង" ហៅថា "**អបាទាន**" ជួនកាលប្រើ **តោ**-បច្ច័យជំនួសបញ្ចមីវិភត្តិ ។

ឧ. **ទានតោ សីលំ មហប្ផលតរំ ហោតិ** " សីលជាគុណ-ជាតមានផលច្រើន ជាងទាន", **សីលំ** បកតិកត្តាក្នុង **ហោតិ** ។ អាខ្យាត.កត្តុ., **ទានតោ** អបាទានក្នុង **ហោតិ**, **មហប្ផលតរំ** វិកតិកត្តាក្នុង **ហោតិ** ។

៣. ជាមូលហេតុ គឺជាដើមហេតុ ដើមចម ប្រែថា " ហេតុ ឬ

ព្រោះ, ព្រោះតែ " ហៅថា "ហេតុ"

**៣. អវិជ្ជាបច្ចយា សង្ខារា, សង្ខារប្បច្ចយា វិញ្ញាណំ** "សង្ខារទ. (កើតព្រម) ព្រោះអវិជ្ជាជាបច្ច័យ, វិញ្ញាណ (កើតព្រម) ព្រោះសង្ខារជាបច្ច័យ..." **សង្ខារា** សយកត្តាក្នុង **(សម្ភវន្តិ)**។ អាខ្យាត.កត្ត., **អវិជ្ជាបច្ចយា** ហេតុក្នុង **សម្ភវន្តិ**, **វិញ្ញាណំ** សយកត្តាក្នុង **(សម្ភវតិ)**។ អាខ្យាត.កត្ត., **សង្ខារប្បច្ចយា** ហេតុក្នុង **សម្ភវតិ** ។

**៤. មយំ ហិ ពុទ្ធស្ស សន្តិកា កម្មដ្ឋានំ ឧគ្គណ្ហាម** "ពិតមែនយើងទ. រៀននូវកម្មដ្ឋាន អំពីសំណាក់នៃព្រះពុទ្ធ" **ហិ** ផលជោតកៈ **មយំ** សយកត្តាក្នុង **ឧគ្គណ្ហាម**។ អាខ្យាត.កត្ត., **ពុទ្ធស្ស** សាមិសម្ពន្ធក្នុង **សន្តិកា**។ អបាទានក្នុង **ឧគ្គណ្ហាម**, **កម្មដ្ឋានំ** អវុត្តកម្មៈក្នុង **ឧគ្គណ្ហាម** ។

**៥. កស្មា ឯត្តកំ កាលំ មយ្ហំ នត្ថិភាវំ ន បចិត្ថ** "លោកមិនចំអិនហើយ នូវនំគ្មានដល់ខ្ញុំអស់កាល មានប្រមាណប៉ុណ្ណេះ ព្រោះហេតុអ្វី" **តុម្ហេ** សយកត្តាក្នុង **បចិត្ថ**។ អាខ្យាត.កត្ត., **កស្មា** ហេតុក្នុង **បចិត្ថ**, **ឯត្តកំ** វិសេសនៈរបស់ **កាលំ**។ អច្ចន្តសំយោគក្នុង **បចិត្ថ**, **មយ្ហំ** សម្បទានក្នុង **បចិត្ថ**, **នត្ថិភាវំ** អវុត្តកម្មៈក្នុង **បចិត្ថ**,

ន បដិសេធក្នុង បចិត្ត ។

## សំហាត់ប្រែលោតប្រយោគ និង សម្ពន្ធ

១. អគ្គិហិ អស្សុធារា បគ្ឃរន្តិ ។

២. នន្ទោ អច្ឆរានំ ហេតុ ព្រហ្មចរិយំ ចរតិ ។

៣. តេ ទូរតោ ว អាគច្ឆន្តេ ទិស្វា ភិក្ខូ អាមន្តេសិ ។

៤. អហមេវ សមណំ គោតមំ ជីវិតា វោរោបេស្សាមិ ។

៥. បេមតោ ជាយតេ សោកោ, បេមតោ ជាយតេ ភយំ ។

៦. ចក្កវត្តិសម្បត្តិតោ តេ សោតាបត្តិផលមេវ វរំ (ហោតិ) ។

៧. សព្វទានេហិ ធម្មទានមេវ សេដ្ឋំ (ហោតិ) ។

៨. ភវប្បច្ចយា ជាតិ, ជាតិប្បច្ចយា ជរាមរណំ ។

៩. អថ កស្មា មហាមោគ្គល្លានតោ ចិរតរេន បារមីញាណំ បាបុណិ ។

១០. អថ កស្មា ឯវមាហ ។ (ធម្មបទ.ភាគ ១)

## ឆដ្ឋីវិភត្តិ

បទនាមនាម ដែលប្រកបដោយឆដ្ឋីវិភត្តិមានអត្ថ ៦ យ៉ាង សម្ពន្ធចូលបានតែនឹងនាមនាមដូច្នេះ

## ១.សាមិសម្ពន្ធ

ពាក្យនេះសំរាប់ហៅឆដ្ឋីវិភត្តិដែលប្រែថា "នៃ" ឬ "របស់" ជាប់ដោយម្ចាស់ មនុស្ស សត្វ ទ្រព្យ ឬ ទីកន្លែង សម្ពន្ធចូលបានតែនឹងនាមនាមម្យ៉ាង ភ្ជាប់ពាក្យថា " ក្នុង " ។

១. **ភិក្ខុនោ ចីវរំ** "ចីវរ នៃ (ឬ របស់) ភិក្ខុ" ។ **ភិក្ខុនោ** សាមិសម្ពន្ធក្នុង **ចីវរំ**ៗ លិង្គត្ថៈ ។

**២.បិតុ បុត្តោ អារាមំ គច្ឆតិ** "កូនទ. របស់បិតា ទៅហើយកាន់អារាម ។ **បិតុ** សាមិសម្ពន្ធក្នុង **បុត្តោ**ៗ សយកត្តាក្នុង **គច្ឆតិ**ៗ អាខ្យាត.កត្តុ., **អារាមំ** សម្បាបុណិយកម្មៈក្នុង **គច្ឆតិ** ។

**៣.មម វចនំ ករោហិ** "ឯងចូរធ្វើតាមពាក្យនៃអញ" (ត្វំ សយកត្តា) ក្នុង **ករោហិ**ៗ អាខ្យាត.កត្តុ., **មម** សាមិសម្ពន្ធក្នុង **វចនំ**ៗ អវុត្តកម្មៈក្នុង **ករោហិ** ។

## ២.សមូហសម្ពន្ធ

ពាក្យនេះ សំរាប់ហៅឆដ្ឋីវិភត្តិដែលប្រែថា "នៃ" ឬ "របស់" ដែរ តែជាម្ចាស់នៃបក្សពួក ហ្វូង ឬក្រុម គឺជាប់ដោយរបស់ច្រើនៗ សម្ពន្ធចូលនឹងបទនោះថា "ក្នុង" ។

១. **ជនានំ សមូហោ** "ប្រជុំនៃជនទ.", **ជនានំ** សមូហសម្ពន្ធ

ក្នុង **សមុហោ**ៗ លិង្គត្ថៈ ។

**២. គាវានំ យូថោ** "ហ្វូង នៃគោទ.", **គាវានំ** សម្ពហសម្ពន្ធ ក្នុង **យូថោ**ៗ លិង្គត្ថៈ ។

**៣. ឥត្ថីនំ គណោ** "បនរបស់ស្រីទ.", **ឥត្ថីនំ** សម្ពហសម្ពន្ធក្នុង **គណោ**ៗ លិង្គត្ថៈ ។

## ៣.ភាវាទិសម្ពន្ធ

នេះជាឈ្មោះឆដ្ឋីវិភត្តិ ប្រែថា "នៃ" ឬ "របស់" ដែលសម្ពន្ធចូលនឹង **ភាវ**-សព្ទ ឬចូលនឹងបច្ច័យក្នុង ភាវតទ្ធិត ឬក៏ចូលនឹង សព្ទដែលជា ភាវសាធនៈ ។

**១. ឥទានិ សុរិយាលោកស្ស អត្ថិតាយ បទីបកិច្ចំ នត្ថិ** "កិច្ច ដោយប្រទីបមិនមានឡើយ ព្រោះភាវៈនៃពន្លឺ របស់ព្រះអាទិត្យមានក្នុងកាលឥឡូវនេះ", **បទីបកិច្ចំ** សយកត្តាក្នុង **នត្ថិ**ៗ អាខ្យាត. កត្តុ., **ឥទានិ** កាលត្ថសត្តមីក្នុង **នត្ថិ**, **សុរិយាលោកស្ស** ភាវាទិសម្ពន្ធក្នុង **អត្ថិតាយ**ៗ ហេតុក្នុង **នត្ថិ** ។

**២. មច្ឆានំ ខីណភាវោ វិយ ឥមេសំ ភោគានំ អភាវោ** "ការមិនមាននៃភោគទ. របស់ជនទ. នេះ ដូចជាភាវៈនៃត្រីទ. អស់ហើយ" **មច្ឆានំ** ភាវាទិសម្ពន្ធក្នុង **ភាវោ**, **វិយ**-សព្ទ

ឧបមាជោតកៈក្នុង **ខីណាសវោ** វិសេសនៈរបស់ **អរហា** លិង្គត្ថៈ, **ឥមេសំ** វិសេសនៈរបស់ **(ជនានំ)** សាមិសម្ពន្ធ ក្នុង **អរហានំ** ភាវាទិសម្ពន្ធក្នុង **អរហា** ។

**៣. ឯកស្ស ចរិតំ សេយ្យោ (ហោតិ)** "កិរិយាត្រាច់ទៅនៃបុគ្គលម្នាក់ឯង ជាការប្រសើរជាង", **ឯកស្ស** វិសេសនៈរបស់ **(បុគ្គលស្ស)** ភាវាទិសម្ពន្ធ) ក្នុង **ចរិតំ** បកតិកត្តាក្នុង **ហោតិ** អាខ្យាត.កត្តុ., **សេយ្យោ** វិកតិកត្តាក្នុង **ហោតិ** ។

## ៤.អនាទរៈ

សម្រាប់ហៅ ឆដ្ឋីវិភត្តិដែលប្រែថា " កាល, កាលបើ " ឬថា "កាលដែល..." ជាសេចក្តីជ្រែកចូលមកនៅអាស្រ័យ ត្រូវមានកិរិយាកិតកៈដែលមានលិង្គ វចនៈ វិភត្តិស្មើគ្នា សម្ពន្ធថា " អនាទរៈ" ចូលនឹងកិរិយារបស់ខ្លួន ភ្ជាប់ពាក្យថា "ក្នុង" អនាទរកិរិយា ដូច្នេះ :

**១. រុទតោ ទារកស្ស បិតា និក្ខមិត្វា បព្វជិ** "កាលដែលទារកកំពុងយំបិតាចេញទៅហើយបួសហើយ", **ទារកស្ស** អនាទរៈក្នុង **រុទតោ** អនាទរកិរិយា, **បិតា** សយកត្តាក្នុង **បព្វជិ** អាខ្យាត.កត្តុ., **និក្ខមិត្វា** បុព្វកាលកិរិយាក្នុង **បព្វជិ** ។

**២. ឯត្ថ តាវ ថោកំ អាគមេថ, បវិសថាតិ មេ វទតោ សីឃំ បវិសេយ្យាថ** “(អ្នកទ.) ចូររង់ចាំ ក្នុងទីនេះបន្តិចសិន, កាលបើខ្ញុំនិយាយថា (អ្នកទ.) ចូរចូលមកចុះ ត្រូវចូលមកឱ្យឆាប់”, **តាវ**_សព្ទ បរិច្ឆេទត្ថវាចកៈ (**តុម្ហេ** សយកត្តា) ក្នុង **អាគមេថ**ៗ អាខ្យាត.កត្តុ., **ឯត្ថ** វិសេសនៈរបស់ **ឋានេ**ៗ វេសយិកាធារៈក្នុង **អាគមេថ**, **ថោកំ** កិរិយាវិសេសនៈនៃ **អាគមេថ**, (**តុម្ហេ** សយកត្តា) ក្នុង **បវិសថ**ៗ អាខ្យាត.កត្តុ., **ឥតិ**_សព្ទ អាការៈក្នុង **វទតោ**, **មេ** អនាទរៈក្នុង **វទតោ**ៗ អនាទរកិរិយា, (**តុម្ហេ** សយកត្តា)ក្នុង **បវិសេយ្យាថ**ៗ អាខ្យាត.កត្តុ., **សីឃំ** កិរិយាវិសេសនៈក្នុង **បវិសេ**~**យ្យាថ** ។

**៣. ថេរស្ស និទ្ទំ អនោក្កមន្តស្ស, បឋមមាសេ អតិក្កន្តេ, អក្ខិរោគោ ឧប្បជ្ជិ** “កាលបើព្រះថេរៈមិនលង់ចុះកាន់កិរិយាសឹងលក់, នាកាលខែទីមួយកន្លងទៅហើយ, រោគក្នុងភ្នែក កើតឡើងហើយ”, **ថេរស្ស** អនាទរៈក្នុង **អនោក្កមន្តស្ស**ៗ អនាទរកិរិយា, **និទ្ទំ** អវុត្តកម្មៈក្នុង **អនោក្កមន្តស្ស** , **បឋមមាសេ** លក្ខណៈក្នុង **អតិក្កន្តេ**ៗ លក្ខណកិរិយា, **អក្ខិរោគោ** សយកត្តាក្នុង **ឧប្បជ្ជិ**ៗ អាខ្យាត.កត្តុ.,។

## ៥.និទ្ធារណៈ

នេះសម្រាប់ហៅឆដ្ឋីវិភត្តិ ដែលប្រែថា "ជំនុំ" ឬ "បណ្តា" ជាចំនួននៅរួមគ្នាឬប្រមូលផ្តុំគ្នា ហើយត្រូវដកលើកចេញតែមួយឬពីរប៉ុណ្ណោះ ញែកចេញឱ្យដាច់ដោយឡែកហៅថា និទ្ធារណីយៈ ។ បទនិទ្ធារណៈត្រូវសម្ពន្ធថា "ក្នុង" ចូលនិង បទដែលដកចេញ ដូច្នេះ ។

១. **មនុស្សានំ ខត្តិយោ សូរតមោ** "បណ្តាមនុស្សទ. ក្សត្រិយ៍ក្លៀវក្លាបំផុត", **មនុស្សានំ** និទ្ធារណៈក្នុង **ខត្តិយោ**ៗ និទ្ធារណីយៈរបស់ **មនុស្សានំ** និងជាលិង្គត្ថៈ , **សូរតមោ** ជាវិសេសនៈរបស់ **ខត្តិយោ** ។

២. **កោ ឥធ កន្ទតំ ពាលតរោ (ហោតិ)** "បណ្តា យើងទ. កំពុងកន្ទក់កន្ទេញក្នុងទីនេះ អ្នកណាជាបុគ្គលល្ងង់ជាង", **ឥធ** វិសេសនៈរបស់ **ឋានេ**ៗ វេសយិកាធារៈក្នុង **កន្ទតំ**ៗ វិសេសនៈរបស់ **នោ**ៗ និទ្ធារណៈក្នុង **កោ**ៗ និទ្ធារណីយៈរបស់ **នោ** និងជាបកតិកត្តាក្នុង **ហោតិ**ៗ អាខ្យាត.កត្តុ., **ពាលតរោ** វិកតិកត្តាក្នុង **ហោតិ** ។

៣. **មុនីនំ សេដ្ឋោ ពុទ្ធោ** "បណ្តាអ្នកប្រាជ្ញទ. ព្រះពុទ្ធប្រសើរបំផុត", **មុនីនំ** និទ្ធារណៈក្នុង **ពុទ្ធោ**ៗ និទ្ធារណីយៈរបស់ **មុនីនំ** និង ជាលិង្គត្ថៈ, **សេដ្ឋោ** វិសេសនៈរបស់ **ពុទ្ធោ** ។

## ៦.ឆដ្ឋីកម្មៈ

ពាក្យនេះ សម្រាប់ហៅ ឆដ្ឋីវិភត្តិ ដែលប្រែថា " នូវ " ដោយអំណាចនាមកិតកៈខ្លះ ដែលប្រកបដោយ **ណ្វុ, ណី, តុ, យុ**-បច្ច័យ ឱ្យប្រែឆដ្ឋីវិភត្តិថា "នូវ" ត្រូវសម្ពន្ធថា "ឆដ្ឋីកម្ម" ចូលនឹងនាមកិតកៈ ភ្ជាប់ពាក្យថា "ក្នុង" ដូច្នេះ ។

**១. ចិត្តស្ស ទមថោ សាធុ** "កិរិយាទូន្មាន នូវចិត្ត ជាការប្រពៃ" **ចិត្តស្ស** ឆដ្ឋីកម្មក្នុង **ទមថោ, សាធុ** វិសេសនៈរបស់ **ទមថោ។** លិង្គត្ថៈ ។

**២. តាសំ បាណាតិបាតស្ស ករណំ វា អករណំ វា ជានិស្សសិ** "(ព្រះអង្គ) នឹងទ្រង់ជ្រាបនូវការធ្វើ ឬនូវការមិនធ្វើនូវបាណាតិបាត នៃស្រីទ. នោះ" (**ត្វំ** សយកត្តា)ក្នុង **ជានិស្សសិ។** អាខ្យាត.កត្តុ., **តាសំ** វិសេសនៈរបស់ (**ឥត្ថីនំ។**) ភាវាទិសម្ពន្ធក្នុង **ករណំ** និង **អករណំ, បាណាតិបាតកម្មស្ស** ឆដ្ឋីកម្មក្នុង **ករណំ** និង **អករណំ។** អវុត្តកម្មៈក្នុង **ជានិស្សសិ, វា** ទាំងពីរសព្ទ បទវិកប្បត្ថ ក្នុង **ករណំ** និង **អករណំ** ។

**៣. សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ** " (បុគ្គល) មានប្រាជ្ញា ជាអ្នកឱ្យនូវសេចក្តីសុខ, លោករមែងបាននូវ

សេចក្ដីសុខវិញ", សុខស្ស ឆដ្ឋីកម្មក្នុង នានា។ វិសេសនៈរបស់ មេធាវី។ លិង្គត្ថៈ, សោ សយកត្ដាក្នុង អធិគច្ឆតិ។ អាខ្យាត.កត្តុ., សុខំ អវុត្តកម្មៈក្នុង អធិគច្ឆតិ ។

## លំហាត់ប្រែលោតប្រយោគ និង សម្ពន្ធ

១. អម្ហាកំ ឯកំ ភិច្ចំ អត្ថិ ៕

២. យស្ស ទោសោ អត្ថិ, តស្សេវ ឧបរិ សាបោ បតតុ ៕

៣. អាចរិយ មយ្ហំ ទោសោ នត្ថិ, មម វចនន្តស្សេវ ត្វម្ពេ អភិសបិត្ថ ៕

៤. រោគស្ស អភាវោ ជនានំ លាភោ ហោតិ ៕

៥. បឋវី សព្វេសំ សត្តានំ និវាសា ហោតិ ៕

៦. ភគវតោ សាវកានំ សង្ឃោ សុបដិបន្នោ ហោតិ ៕

៧. បិយានំ ហិ វិយោគវសេន អនស្សនំ ទុក្ខំ ហោតិ ៕

៨. មតកេហិ សទ្ធឹ មយ្ហំ យុទ្ធំ នាម នត្ថិ ៕

៩. តេសំ ឯកោ (ឧបាសកោ) និសិន្នកោវ និទ្ទាយិ ៕

១០. ធម្មស្ស ញាតារោ បុញ្ញំ ករោន្តិ ៕

## សត្តមីវិភត្តិ

បទនាមនាមដែលប្រកបផ្សំនឹង សត្តមីវិភត្តិ មានអត្ថ ៦ យ៉ាង

សម្ពន្ធចូលនឹងកិរិយាក៏មាន ចូលនិងនាមក៏មាន ដូច្នេះ ។

## ១.បដិច្ឆន្នាធារៈ

ឈ្មោះនេះសម្រាប់ហៅបទនាមនាមដែលប្រកបដោយសត្តមីវិភត្តិប្រែថា "ក្នុង" ជាទីកំបាំងជិត មើលមិនឃើញ ជាធម្មតា សម្ពន្ធចូលនឹងសព្ទដែលទាក់ទងគ្នា ប្រើពាក្យថា "ក្នុង" ផង ។

១. **អន្តោគេហេ និសីទតិ** "(គេ) អង្គុយក្នុង ខាងក្នុងនៃបន្ទប់ " **សោ** សយកត្តាក្នុង **និសីទតិ**ៗ អាខ្យាត.កត្តុ., **អន្តោគេហេ** បដិច្ឆន្នាធារៈក្នុង **និសីទតិ** ។

២. **ធីតរោ គព្ភេ និបជ្ជន្តិ** " ធីតាទ. តែងដេកក្នុងបន្ទប់ " **ធីតរោ** សយកត្តាក្នុង **និបជ្ជន្តិ**ៗ អាខ្យាត.កត្តុ., **គព្ភេ** បដិច្ឆន្នាធារៈក្នុង **និបជ្ជន្តិ** ។

៣. **កុដេ បក្ខិបិត្វា ភូមិយំ និខនិត្វា ឋបេសិ** ។ "(សេដ្ឋី) ដាក់ចុះហើយក្នុងក្អម ជីកកប់ទុកហើយក្នុងផែនដី" **(សេដ្ឋី)** សយកត្តាក្នុង **ឋបេសិ**ៗ អាខ្យាត.កត្តុ., **កុដេ** បដិច្ឆន្នាធារៈក្នុង **បក្ខិបិត្វា**ៗ បុព្វកាលកិរិយាក្នុង **ឋបេសិ**, **ភូមិយំ** បដិច្ឆន្នាធារៈក្នុង **និក្ខនិត្វា ឋបេសិ**, **និក្ខនិត្វា** សមានកាលកិរិយាក្នុង **ឋបេសិ** ។

## ២.ព្យាបិកាធារៈ

ពាក្យនេះជាឈ្មោះសត្តមីវិភត្តិ ដែលប្រែថា "ក្នុង" សំដៅរបស់ដែលជ្រួតជ្រាប លាយឡំច្របូកច្របល់ជាមួយគ្នាដូចជា ឱជាឆ្ងាញ់ ឬមិនឆ្ងាញ់ជ្រួតជ្រាប ក្នុងអាហារ សម្ពន្ធចូល នឹងសព្ទដែលទាក់ទងគ្នា ភ្ជាប់ពាក្យថា "ក្នុង" ផង ។

**១. តិលេសុ តេលំ តិដ្ឋតិ** "ប្រេងស្ថិតក្នុងល្ង." , **តេលំ** សយកត្តាក្នុង **តិដ្ឋតិ**ៗ អាខ្យាត.កត្តុ., **តិលេសុ** ព្យាបិកាធារៈក្នុង **តិដ្ឋតិ** ។

**២. ជលេ ខីរំ តិដ្ឋតិ** "ទឹកដោះស្រស់ ស្ថិតនៅក្នុងទឹក" **ខីរំ** សយកត្តាក្នុង **តិដ្ឋតិ**ៗ អាខ្យាត.កត្តុ., **ជលេ** ព្យាបិកាធារៈក្នុង **តិដ្ឋតិ** ។

**៣. ធម្មោ សប្បុរិសានំ សន្តានេ ឋិតោ** "ព្រះធម៌តាំងនៅក្នុងសន្តាននៃសប្បុរសទាំងឡាយ" **ធម្មោ** សយកត្តាក្នុង **ឋិតោ**ៗ កិតបទ_កត្តុវាចកៈ **សប្បុរិសានំ** សាមិសម្ពន្ធក្នុង **សន្តានេ**ៗ ព្យាបិកាធារៈក្នុង **ឋិតោ** ។

**៤. គន្ធោ សត្តានំ សរីរេ អត្ថិ** "ក្លិនមានក្នុងសរីរៈរបស់សត្វទ." **គន្ធោ** សយកត្តាក្នុង **អត្ថិ**ៗ អាខ្យាត.កត្តុ., **សត្តានំ** សាមិសម្ពន្ធក្នុង **សរីរេ**ៗ ព្យាបិកាធារៈក្នុង **អត្ថិ** ។

**៥. លោណម្ពិលានិ សូបព្យញ្ជនេសុ តិដ្ឋន្តិ** " អំបិលនិង

ម្ហូរទ. តាំងនៅហើយ ក្នុងម្ហូបទឹក និងម្ហូបក្រៀមទ." **លោណម្ពិលានិ** សយកត្តាក្នុង **តិដ្ឋីសុ**ៗ អាខ្យាត.កត្តុ., **សូបព្យញ្ជនេសុ** ព្យាបិកាធារៈក្នុង **តិដ្ឋីសុ** ។

## ៣.វេសយិកាធារៈ

ពាក្យនេះជាឈ្មោះ សត្តមីវិភត្តិ ដែលប្រែថា "ក្នុង" សំដៅកន្លែងជាទីនៅអាស្រ័យសម្ពន្ធចូលនិង សព្ទដែលទាក់ទងគ្នាថែមពាក្យថា "ក្នុង" វេលាសម្ពន្ធ ។

**១. ជលេ មច្ឆា វសន្តិ** " ត្រីទ. នៅក្នុងទឹក", **មច្ឆា** សយកត្តាក្នុង **វសន្តិ**ៗ អាខ្យាត.កត្តុ., **ជលេ** វេសយិកាធារៈក្នុង **វសន្តិ** ។

**២. ហត្ថី ជិណ្ណាយ សាលាយ ឋិតោ**" ដំរីឈរក្នុងរោងចាស់", **ហត្ថី** សយកត្តាក្នុង **ឋិតោ**ៗ កិតបទ-កត្តុ., **ជិណ្ណាយ** វិសេសនៈរបស់ **សាលាយ**ៗ វេសយិកាធារៈក្នុង **ឋិតោ** ។

**៣. ឥសយោ អស្សមេ វិហរន្តិ** " ឥសីទ. តែងគង់នៅក្នុងអាស្រម", **ឥសយោ** សយកត្តាក្នុង **វិហរន្តិ**ៗ អាខ្យាត.កត្តុ., **អស្សមេ** វេសយិកាធារៈក្នុង **វិហរន្តិ** ។

**៤. ឯកសដ្ឋី អរហន្តោ លោកេ ឧប្បន្នា** "ព្រះអរហន្តទ. ៦១ អង្គ កើតឡើងហើយក្នុងលោក" **ឯកសដ្ឋី** វិសេសនៈរបស់

**អរហន្តោ**ៗ សយកត្តាក្នុង **ឧប្បន្នា**ៗ កិតបទ_កត្តុ., **លោកេ** វេសយិកាធារៈក្នុង **ឧប្បន្នា** ។

**៥. មម បុត្តោ ពុទ្ធសាសនេ បព្វជិតោ** "កូនទ. របស់ខ្ញុំបួសហើយក្នុងព្រះពុទ្ធសាសនា", **មម** សាមិសម្ពន្ធក្នុង **បុត្តោ**ៗ សយកត្តាក្នុង **បព្វជិតោ**ៗ អាខ្យាត.កត្តុ., **ពុទ្ធសាសនេ** វេសយិកាធារៈក្នុង **បព្វជិតោ** ฯ

## ៤.កាលត្ថសត្តមី

ពាក្យនេះជាឈ្មោះសម្រាប់ហៅ បទនាមនាម ជាគ្រឿងសម្គាល់ពេលវេលា ឆ្នាំ ខែ ថ្ងៃ សម័យ ខណៈជាដើម ដែលប្រកបសត្តមីវិភត្តិ ប្រែថា "ក្នុង", ម្យ៉ាងទៀត និបាតប្រាប់កាលដូចជា **អថ បាតោ ទិវា សាយំ** ជាដើម ។ មួយវិញទៀត បច្ច័យគឺ **ទា, ទានិ, រហិ, ធុនា, ទាចនំ, ជ្ជ, ជ្ជុ** ដែលប្រើចុះក្នុងកាល ត្រូវសម្ពន្ធថា កាលត្ថសត្តមី ដូច្នេះដែរ :

**១. យស្មឹ សមយេ កាមាវចរំ កុសលចិត្តំ ឧប្បន្នំ ហោតិ** " កុសលចិត្តជាកាមាវចរ ជាចិត្តកើតឡើងហើយ មានក្នុងសម័យឯណា", **កុសលចិត្តំ** បកតិកត្តាក្នុង **ហោតិ**ៗ អាខ្យាត.កត្តុ., **យស្មឹ** វិសេសនៈរបស់ **សមយេ**ៗ កាលត្ថសត្តមីក្នុង **ហោតិ** , **កាមាវចរំ**

វិសេសនៈរបស់ **កុសលចិត្តំ, ឧប្បន្នំ** វិកតិកត្តាក្នុង **ហោតិ** ។

**២. សុរិយោ បុព្វណ្ហេ ឧគ្គតោ, សោ សាយណ្ហេ អដ្ឋង្គតោ** " ព្រះសុរិយារះហើយ ក្នុងពេលព្រឹក, ព្រះអាទិត្យនោះ អស្តង្គត ក្នុងពេលល្ងាច ", **សុរិយោ** សយកត្តាក្នុង **ឧគ្គតោ**ៗ កិតបទ-កត្តុ., **បុព្វណ្ហេ** កាលត្ថសត្តមីក្នុង **ឧគ្គតោ** ។ **សោ** វិសេសនៈរបស់ **សុរិយោ**ៗ សយកត្តាក្នុង **អដ្ឋង្គតោ**ៗ កិតបទ-កត្តុ., **សាយណ្ហេ** កាលត្ថសត្តមីក្នុង **អដ្ឋង្គតោ** ។

**៣. បុរេភត្តំ ទានំ ទេន្តិ** "(អរិយសាវ័កទ.) តែងថ្វាយនូវទាន ក្នុងកាលមុននៃភត្ត", **(អរិយសាវកា)** សយកត្តាក្នុង **ទេន្តិ**ៗ អាខ្យាត. កត្តុ., **ទានំ** អវុត្តកម្មក្នុង **ទេន្តិ**, **បុរេភត្តំ** ទុតិយាកាលត្ថសត្តមីក្នុង **ទេន្តិ** ។

**៤. អន្តោវស្សំ តយោ មាសេ ន និបជ្ជិស្សាមិ** "(ខ្ញុំ) នឹងមិនដេក អស់ខែទ. ៣ ក្នុងខាងក្នុងនៃវស្សា", **(អហំ)** សយកត្តាក្នុង **និបជ្ជិស្សាមិ**ៗ អាខ្យាត.កត្តុ., **ន** បដិសេធក្នុង **និបជ្ជិស្សាមិ**, **តយោ** វិសេសនៈរបស់ **មាសេ**ៗ អច្ចន្តសំយោគក្នុង **និបជ្ជិស្សាមិ**, **អន្តោវស្សំ** ទុតិយាកាលត្ថសត្តមីក្នុង **ន និបជ្ជិស្សាមិ** ។

**៥. តតិយវារេ ន កថេសិ** "(កុលធីតា) មិនប្រាប់ហើយ

ក្នុងវារៈទី ៣ ", **(ភុលធីតា)** សយកត្តាក្នុង **ភវេសិ**ៗ អាខ្យាត.កត្តុ., **ន** បដិសេធក្នុង **ភវេសិ**, **តតិយវារេ** កាលត្ថសត្តមីក្នុង **ភវេសិ** ។

## ៥.ឧបសិលេសិកាធារៈ

ពាក្យនេះ សម្រាប់ហៅ សត្តមីវិភត្តិដែលប្រែថា "លើ, ឰដ៏, ត្រង់, នា" ពាក្យណាមួយជាគ្រឿងសម្គាល់ថា ជាទីរង ជាទីទ្រ ឬជាទីភ្ជាប់, សម្ពន្ធចូលនឹងនាមនាម ឬនិងកិរិយា ប្រើភ្ជាប់ពាក្យថា "ក្នុង" ។

**១. ភគវា បញ្ញត្តេ អាសនេ និសីទិ** "ព្រះមានព្រះភាគគង់ហើយ លើអាសនៈ ដែលគេក្រាលហើយ ", **ភគវា** សយកត្តាក្នុង **និសីទិ**ៗ អាខ្យាត.កត្តុ., **បញ្ញត្តេ** វិសេសនៈរបស់ **អាសនេ**ៗ ឧបសិលេសិកាធារៈក្នុង **និសីទិ** ។

**២. ឧរសិ លោមា** "រោមទ. ឰដ៏ទ្រូង ឬត្រង់ទ្រូង", **ឧរសិ** ឧបសិលេសិកាធារៈក្នុង **លោមា**ៗ លិង្គត្ថៈ ។

**៣. អត្តនោ អង្គុលិយំ បិលន្ធិ** "(ព្រះនាង) ពាក់ហើយត្រង់ម្រាមរបស់ខ្លួន ", **(សា)** សយកត្តាក្នុង **បិលន្ធិ**ៗ អាខ្យាត.កត្តុ., **អត្តនោ** សាមិសម្ពន្ធក្នុង **អង្គុលិយំ**ៗ ឧបសិលេសិកាធារៈក្នុង **បិលន្ធិ** ។

**៤. គន្ធមាទនបព្វតេ ឯកោ បច្ចេកពុទ្ធោ សមាបត្តិតោ**

វុដ្ឋហិ "ព្រះបច្ចេកពុទ្ធមួយអង្គ លើភ្នំគន្ធមាទន៍ចេញហើយចាក សមាបត្តិ" **ឯកោ** វិសេសនៈរបស់ **បច្ចេកពុទ្ធោ។** សយកត្តាក្នុង វុដ្ឋហិ។ អាខ្យាត.កត្តុ., **សមាបត្តិតោ** អបាទានក្នុង វុដ្ឋហិ , **គន្ធមាទនបព្វតេ** ឧបសិលេសិកាធារៈក្នុង **បច្ចេកពុទ្ធោ** ។

**៥. អាកាសេ ច បទំ នត្ថិ** "ស្នាមជើងឰដ៏អាកាសតែងមិន មាន", **ច**_បទបូរណក្នុង **អាកាសេ។** ឧបសិលេសិកាធារៈក្នុង **បទំ។** សយកត្តាក្នុង **នត្ថិ។** អាខ្យាត.កត្តុ., ។

## ៦.លក្ខណៈ

ពាក្យនេះសម្រាប់ហៅសត្តមីវិភត្តិដែលប្រែថា " នាកាល, កាលបើ, កាលដែល" ពាក្យណាមួយ សម្ពន្ធចូលនឹងកិរិយារបស់ខ្លួន ដែលប្រកបដោយ **អន្ត, មាន, ត**~បច្ច័យ មានលិង្គ, វចនៈ វិភត្តិ ស្មើគ្នា, ចាត់ជាប្រយោគ ជ្រែកចូលក្នុងប្រយោគធំ ។

**១. សុរិយេ អត្ថង្គតេ ចន្ទោ ឧគ្គច្ឆតិ** "នាកាលព្រះអាទិត្យ អស្តង្គតហើយ ព្រះចន្ទរះឡើង", **សុរិយេ** លក្ខណៈក្នុង **អត្ថង្គតេ។** លក្ខណៈកិរិយា, **ចន្ទោ** សយកត្តាក្នុង **ឧគ្គច្ឆតិ។** អាខ្យាត.កត្តុ., ។

**២. ឯវំ សន្តេ អម្ហេហិ បន ន គន្តព្វំ** " កាលបើ (ហេតុ) យ៉ាងនេះមាន, មានតែយើងទ. ត្រូវកុំទៅ", **ឯវំ** វិសេសនៈរបស់

**ការណោ**ៗ លក្ខណៈក្នុង **សន្តេ**ៗ លក្ខណកិរិយា, **បន**-សព្ទ បក្ខន្តរត្ថ-វាចកៈ, **អម្ហេហិ** អនភិហិតកត្តាក្នុង **គន្តព្វំ**ៗ កិតបទ-ភាវ., **ន**-សព្ទ បដិសេធក្នុង **គន្តព្វំ** ។

**៣. តស្មឹ កថេន្តេ កថេន្តេយេវ, ព្រាហ្មណស្ស សកលសរីរំ បីតិយា បរិបូរិ** "កាលដែល (មាណព) នោះកំពុងនិយាយច្រើនៗទៅ, សរីរៈទាំងអស់របស់ព្រាហ្មណ៍ ពេញផ្សព្វផ្សាយហើយដោយបីតិ", **តស្មឹ** វិសេសនៈរបស់ **មាណវេ**ៗ លក្ខណៈក្នុង **កថេន្តេ**ៗ លក្ខណៈកិរិយា , **ឯវ**-សព្ទ អវធារណៈក្នុង **កថេន្តេ, កថេន្តេ, ព្រាហ្មណស្ស** សាមិសម្ពន្ធក្នុង **សកលសរីរំ**ៗ សយកត្តាក្នុង **បរិបូរិ**ៗ អាខ្យាត.កត្ត., **បីតិយា** ករណៈក្នុង **បរិបូរិ** ។

**៤. តិត្ថិយា ពុទ្ធេ ឧប្បន្នេ លាភា បរិហាយឹសុ** " តិរ្ថិយទ. នាកាលព្រះពុទ្ធ ទ្រង់កើតឡើងហើយ សាបសូន្យហើយ ចាកលាភ", **តិត្ថិយា** សយកត្តាក្នុង **បរិហាយឹសុ**ៗ អាខ្យាត.កត្ត., **ពុទ្ធេ** លក្ខណៈក្នុង **ឧប្បន្នេ**ៗ លក្ខណកិរិយា, **លាភា** អបាទានក្នុង **បរិហាយឹសុ** ។

**៥. ភិក្ខុសង្ឃោ បណ្ណរសិយា តិថិយា សម្បត្តាយ សីមាយំ ឧបោសថំ ករោតិ** " ភិក្ខុសង្ឃ កាលបើតិថីទី ១៥ ដល់ព្រមហើយ រមែងធ្វើនូវឧបោសថ ក្នុងសីមា", **ភិក្ខុសង្ឃោ** សយកត្តាក្នុង

**ករោតិ**ៗ អាខ្យាត.កត្តុ., **បណ្ណរសិយា** វិសេសនៈរបស់ **តិថិយា**ៗ លក្ខណៈក្នុង **សម្បត្តាយ**ៗ លក្ខណកិរិយា, **សីមាយំ** វេសយិកាធារៈក្នុង **ករោតិ**, **ឧបោសថំ** អវុត្តកម្មក្នុង **ករោតិ** ។

## ៧.និមិត្តសត្តមី

ពាក្យនេះជាឈ្មោះ សត្តមីវិភត្តិដែលប្រែថា "និមិត្ត" ដែលជាហេតុឬជាគ្រឿងចំណាំ ត្រូវគ្នានឹងពាក្យថា "ហេតុ, ព្រោះ, ព្រោះតែ ", ត្រូវសម្ពន្ធចូលនឹងនាម ឬនឹងកិរិយា ភ្ជាប់ពាក្យថា "ក្នុង" ដូច្នេះ

**១. ទីបិនោ ចម្មេសុ ហញ្ញតេ** "ដំរី (គឺគេ) សម្លាប់ និមិត្តភ្លុកទ." **ទីបិនោ** វុត្តកម្មៈក្នុង **ហញ្ញតេ**, **ចម្មេសុ** និមិត្តសត្តមីក្នុង **ហញ្ញតេ**ៗ អាខ្យាត.កម្ម., ។

**២. អរិយសាវកោ សុខទុក្ខេ ន វេធតិ** "ព្រះអរិយសាវកមិនញាប់ញ័រ និមិត្តសុខនិងទុក្ខ", **អរិយសាវកោ** សយកត្តាក្នុង **វេធតិ**ៗ អាខ្យាត.កត្តុ., **ន**_សព្ទ បដិសេធក្នុង **វេធតិ**, **សុខទុក្ខេ** និមិត្តសត្តមីក្នុង **ន វេធតិ** ៕

**៣. នត្ថិ ពាលេ សហាយតា** "សហាយតាគុណមិនមាន និមិត្តបុគ្គលពាល", **សហាយតា** សយកត្តាក្នុង **នត្ថិ**ៗ និបាតាអាខ្យាត.កត្តុ., **ពាលេ** និមិត្តសត្តមីក្នុង **នត្ថិ** ។

## ៨.និទ្ធារណៈ

ពាក្យនេះសម្រាប់ហៅសត្តមីវិភត្តិ ដែលប្រែថា "ជំនុំ" ឬ "បណ្តា" ជាសេចក្តីរួមប្រមូលផ្តុំគ្នា, ឯចំនួនដែលត្រូវញែកចេញពី ចំនួនរួមនោះ ហៅថា និទ្ធារណីយៈ។ នេះត្រូវសម្ពន្ធចូលនឹង និទ្ធារណៈម្តងត្រឡប់ទៅចូលនឹង កិរិយារបស់ខ្លួនម្តងទៀតភ្ជាប់ ពាក្យថា "ក្នុង" ដូច្នេះ

១. **តេសុ ទ្វីសុ ឯកោ សោតាបត្តិផលំ បាបុណិ** " ជំនុំ (ភិក្ខុទ.) ពីរអង្គនោះ (ភិក្ខុ) មួយអង្គដល់ហើយនូវ សោតាបត្តិផល", **តេសុ ទ្វីសុ** ទាំងពីរបទ វិសេសនៈរបស់ **ភិក្ខូសុ**។ និទ្ធារណៈក្នុង **ឯកោ ភិក្ខុ**, **ឯកោ** វិសេសនៈរបស់ **ភិក្ខុ**។ និទ្ធារណីយៈរបស់ **ភិក្ខូសុ** នឹងជាសយកត្តាក្នុង **បាបុណិ**។ អាខ្យាត.កត្តុ., **សោតាបត្តិផលំ** អវុត្តកម្មក្នុង **បាបុណិ** ។

២. **អហមេវ កន្ទន្តេសុ ពាលតរោ** "(បណ្តាយើងទ.) កំពុងកន្ទក់កន្ទេញ ខ្ញុំហ្នឹងឯង ជាបុគ្គលល្ងង់ជាង", **កន្ទន្តេសុ** វិសេសនៈរបស់ (**អម្ហេសុ**។) និទ្ធារណៈក្នុង **អហំ**, **ឯវ**-សព្ទ អវធារណៈក្នុង **អហំ**។ និទ្ធារណីយៈរបស់ **អម្ហេសុ** និងជាបកតិកត្តា ក្នុង (**អម្ហិ**។) អាខ្យាត.កត្តុ., **ពាលតរោ** វិកតិកត្តាក្នុង **អម្ហិ** ។

**៣. តេសុ អរិយសាវកានំ ទ្វេយេវ កិច្ចានិ អហេសុំ** "កិច្ចទ. ពីរ មែនពិតបានមានហើយ ដល់បណ្តាមនុស្សទ. នោះព្រះអរិយ-សាវ័កទ." , **ទ្វេ** វិសេសនៈរបស់ **កិច្ចានិ**ៗ សយកត្តាក្នុង **អហេសុំ**ៗ អាខ្យាត. កត្តុ., **ឯវ**-សព្ទ អវធារណៈក្នុង **ទ្វេ**, **តេសុ** វិសេសនៈរបស់ **មនុស្សេសុ**ៗ និទ្ធារណៈក្នុង **អរិយសាវកានំ**ៗ និទ្ធារណីយៈរបស់ **មនុស្សេសុ** និងជាសម្បទានៈក្នុង **អហេសុំ** ។ រូបដោយ និទ្ធារណៈ ។

**៤. ទសសុ បុញ្ញកិរិយាវត្ថូសុ ឯកំ លភិស្សាមិ** "(ខ្ញុំ) នឹងបាននូវ បណ្តាបុញ្ញកិរិយាវត្ថុទ. ១០ បុញ្ញកិរិយាវត្ថុ ១", **(អហំ)** សយកត្តាក្នុង **លភិស្សាមិ**ៗ អាខ្យាត.កត្តុ., **ទសសុ** វិសេសនៈរបស់ **បុញ្ញកិរិយាវត្ថូសុ**ៗ និទ្ធារណៈក្នុង **ឯកំ បុញ្ញកិរិយាវត្ថុំ**, **ឯកំ** វិសេសនៈរបស់ **បុញ្ញកិរិយាវត្ថុំ**ៗ និទ្ធារណីយៈរបស់ **វត្ថូសុ** និងជាអវុត្តកម្មៈក្នុង **លភិស្សាមិ** ។

**៥. ន ហិ សក្កា អម្ហេសុ ឯកេន អបព្វជិតុំ** "មែនបណ្តាយើងទ. ត្រូវជនម្នាក់ មិនអាចដើម្បីមិនបួសទេ", **ហិ** ព្យតិរេកត្ថ-វាចកៈ **អម្ហេសុ** និទ្ធារណៈក្នុង **ឯកេន ជនេន**, **ឯកេន** វិសេសនៈរបស់ **ជនេន**ៗ និទ្ធារណីយៈរបស់ **អម្ហេសុ** និងជាអនភិហិតកត្តាក្នុង **សក្កា**, **ន**-សព្ទ បដិសេធក្នុង **សក្កា**ៗ កិរិយាបទ-ភាវ., **អបព្វជិតុំ**

កុមត្ថសម្បទានក្នុង **សត្ថា** ។

## ៩.សមីបាធារ:

សម្រាប់ហៅសត្តមីវិភត្តិ ដែលប្រែថា "ទៀប" ឬ "ជិត" ប្រាប់ឱ្យដឹងថាទីជិតគ្នាឬក្បែរគ្នាសម្ពន្ធចូលនឹង នាមឬនឹងកិរិយាដែលទាក់ទងគ្នា ថែមពាក្យថា "ក្នុង" ដូច្នេះ

**១. នគរទ្វារេ គាមោ** "ស្រុកទ. ជិតទ្វារនៃក្រុង", **នគរទ្វារេ** សមីបាធារ:ក្នុង **គាមោ**ៗ លិង្គត្ថ: ។

**២. សាវត្ថិយំ វិហរតិ ជេតវនេ** "(ព្រះមានព្រះភាគ) គង់នៅក្នុងវត្តជេតពនជិតក្រុងសាវត្ថី", **(ភគវា)** សយកត្តាក្នុង **វិហរតិ**ៗ អាខ្យាត.កត្តុ., **សាវត្ថិយំ** សមីបាធារ:ក្នុង **វិហរតិ ជេតវនេ** វេសយិកាធារ:ក្នុង **វិហរតិ** ។

**៣. ទ្វេ គាមា នទិយា តីរេ ហោន្តិ** " ស្រុកទ.ពីរមានទៀប ឆ្នេរ នៃស្ទឹង", **ទ្វេ** វិសេសន:របស់ **គាមា**ៗ សយកត្តាក្នុង **ហោន្តិ**ៗ អាខ្យាត.កត្តុ., **នទិយា** សាមិសម្ពន្ធក្នុង **តីរេ**ៗ សមីបាធារ:ក្នុង **ហោន្តិ** ។

**៤. ឯកោ ភិក្ខុ រុក្ខមូលេ និសីទតិ** "ភិក្ខុ មួយអង្គ គង់ហើយទៀបគល់នៃឈើ ", **ភិក្ខុ** សយកត្តាក្នុង **និសីទតិ**ៗ អាខ្យាត.កត្តុ.,

**ឯកោ** វិសេសនៈរបស់ **ភិក្ខុ, រុក្ខមូលេ** សមីបាធារៈក្នុង **និសីទិ** ។

**៥. ព្រាហ្មណោ សត្ថុ បាទមូលេ និបជ្ជិ** "ព្រាហ្មណ៍ក្រាបចុះហើយជិតបាទមូលនៃព្រះសាស្តា", **ព្រាហ្មណោ** សយកត្តាក្នុង **និបជ្ជិ**។ អាខ្យាត.កត្តុ., **សត្ថុ** សាមិសម្ពន្ធក្នុង **បាទមូលេ**។ សមីបាធារៈក្នុង **និបជ្ជិ** ។

## អាលបនៈវិភត្តិ

បទនាមនាម ដែលប្រកបផ្សំ នឹងបឋមាវិភត្តិ ដែលប្រែថា " បពិត្រ, ម្នាល, នែ, ហៃ " ហៅថា អាលបនៈ មាន ២ យ៉ាងគឺ :

## ១.អាលបនវិភត្តិ

ឈ្មោះនេះសំរាប់ហៅបទនាមនាម ដែលប្រកបផ្សំនឹងបឋមាវិភត្តិគឺ **សិ** ឬ **យោ** ក្តី, អព្យយសព្ទបីតួគឺ **យគ្ឃេ, ភន្តេ, ភទន្តេ** ដែលចាត់ជា អាលបនត្ថវាចកៈក្តី វេលាប្រែចេញពាក្យ-អាយតនិបាត ថា "បពិត្រ" ត្រូវសម្ពន្ធថា សគារវាលបនៈ មុនជាងសព្ទទាំងពួង ហើយមិនចូលនឹងសព្ទណាទេ គឺសម្ពន្ធដាច់តែឯង, ប៉ុន្តែក្នុងប្រយោគ ដែលមានបទអាលបនៈ ពីរបទ ត្រូវប្រែបទមួយ ជាអាលបនៈ បទមួយទៀតជា វិសេសនៈ

**១. ជយតុ ភវំ មហារាជ** "បពិត្រមហារាជ សូមព្រះអង្គដ៏

ចំរើនទ្រង់ឈ្នះ ", **មហារាជ** សគារវាលបនៈ **តទំ** សយកត្តាក្នុង **ជយតុ** អាខ្យាត.កត្តុ., ។

**២. ឧបជ្ឈាយោ មេ ភន្តេ ហោហិ** "បពិត្រព្រះតេជះព្រះគុណដ៏ចំរើន (លោកម្ចាស់) ជាព្រះឧបជ្ឈាយ៍របស់ខ្ញុំ", **ភន្តេ** សគារវាលបនៈ (**ត្វំ**) បកតិកត្តាក្នុង **ហោហិ** អាខ្យាត.កត្តុ., **មេ** សាមិសម្ពន្ធក្នុង **ឧបជ្ឈាយោ** វិកតិកត្តាក្នុង **ហោហិ** ។

**៣. ឧបជ្ឈាយោ មេ ភន្តេ អាយស្មា តិស្សត្ថេរោ នាម** " បពិត្រ លោកដ៏ចំរើន ព្រះឧបជ្ឈាយ៍របស់ខ្ញុំ ព្រះនាមតិស្សត្ថេរដ៏មានអាយុ " , **ភន្តេ** សគារវាលបនៈ **ឧបជ្ឈាយោ** លិង្គត្ថៈ **មេ** សាមិសម្ពន្ធក្នុង **ឧបជ្ឈាយោ**, **អាយស្មា** ក្តី **តិស្សត្ថេរោ** ក្តី វិសេសនៈរបស់ **ឧបជ្ឈាយោ**, **នាម**-សព្ទ សញ្ញាជោតកៈក្នុង **តិស្សត្ថេរោ** ៕

**៤. ភន្តេ ថេរ ក្ហឹ គមិស្សថ** "បពិត្រព្រះថេរៈដ៏ចំរើនលោកនឹងទៅក្នុងទីណា", **ភន្តេ** វិសេសនៈរបស់ **ថេរ** សគារវាលបនៈ (**តុម្ហេ** សយកត្តា) ក្នុង **គមិស្សថ** អាខ្យាត.កត្តុ., **ក្ហឹ** វិសេសនៈរបស់ **ឋានេ** អាធារៈក្នុង **គមិស្សថ** ។

**១. ឥទ្ធិ បស្ស មហាពល មោគ្គល្លាន មហិទ្ធិក** " បពិត្រ

ព្រះមោគ្គល្លាន មានកំលាំងច្រើន មានឫទ្ធិច្រើន សូមនិមន្ត សូមលោកមើលចុះ", **មោគ្គល្លាន** សគារវាលបន, (ត្វំ) សយកត្តាក្នុង **បស្សៗ** អាខ្យាត.កត្តុ., **ឥធ្ស**-សព្ទ ឧយ្យោជនត្ថ, **មហាព្វល** ក្តី **មហិទ្ធិក** ក្តី វិសេសនៈរបស់ **មោគ្គល្លាន** ។

## ២.អគារវាលបនៈ

នេះជាឈ្មោះសម្រាប់ហៅ បទនាមនាម ដែលប្រកបផ្សំ នឹងបឋមាវិភត្តិជាពាក្យស្រែកហៅដោយសេចក្តីមិនគោរព ប្រែថា "ម្នាល, នែ, ហៃ" ។ សូម្បី អព្យយសព្ទ ជាអាលបនត្ថវាចកៈ ៩ សព្ទគឺ : **ភណេ, អម្ភោ, អាវុសោ, រេ, អរេ, ហរេ, ហេ, អហេ,** ៩ ក៏សម្គន្ធថា អគារវាលបនៈទាំងអស់ ។

**១. ធម្មំ វោ ភិក្ខវេ ទេសិស្សាមិ** " ម្នាលភិក្ខុទ. (តថាគត) នឹងសំដែងនូវធម៌ដល់អ្នកទាំងឡាយ", **ភិក្ខវេ** អគារវាល-បនៈ **(អហំ)** សយកត្តាក្នុង **ទេសិស្សាមិៗ** អាខ្យាត.កត្តុ., **ធម្មំ** អវុត្តកម្មៈក្នុង **ទេសិស្សាមិ, វោ** សម្បទានក្នុង **ទេសិស្សាមិ** ។

**២. វទេហិ តាវ អាវុសោ ចាលិត** "ម្នាលភិក្ខុចាលិតដ៏មានអាយុ (លោក) ចូរនិយាយទៅមើល", **អាវុសោ** វិសេសនៈរបស់ **ចាលិតៗ** អគារវាលបនៈ, **(ត្វំ)** សយកត្តាក្នុង **វទេហិៗ**

អាខ្យាត.កត្តុ., **តាវ** កិរិយាវិសេសនៈរបស់ **វទេហិ** ។

**៣. អាវុសោ ឱពទ្ធនីត មហល្លក អត្តនោ បមាណំ ន ជានាសិ** "នែភិក្ខុចាស់ដែលគេទូន្មានបានដោយក្រ ដ៏មានអាយុ (លោក) មិនដឹង នូវប្រមាណរបស់ខ្លួន", **អាវុសោ** ក្តី **មហល្លក** ក្តី វិសេសនៈរបស់ **មហល្លក**។ អគារវាលបនៈ (ត្វំ) សយកត្តាក្នុង **ជានាសិ**។ អាខ្យាត. កត្តុ., **ន**_សព្ទ បដិសេធក្នុង **ជានាសិ**, **អត្តនោ** សាមិសម្ពន្ធក្នុង **បមាណំ**។ អវុត្តកម្មៈក្នុង **ជានាសិ** ។

**៤. អរេ ឧដ្ឋកុដ្ឋិ កឹ ត្វំ វទេសិ** "នែអាគមកំណាច ចង្រៃ អាថាម៉េច ? " **អរេ** វិសេសនៈរបស់ **ឧដ្ឋកុដ្ឋិ**។ អគារវាលបនៈ, (ត្វំ) សយកត្តាក្នុង **វទេសិ**។ អាខ្យាត.កត្តុ., **កឹ** កិរិយាវិសេសនៈក្នុង **វទេសិ** ។

**៥. អរេ ខុជ្ជ អតិពហលោដ្ឋកបោលំ តេ មុខំ** " នែមេគមចង្រៃមាត់របស់ហងមានបបូរក្រាស់ឃ្នីកក្រៃពេក ", **អរេ** វិសេសនៈរបស់ **ខុជ្ជ**។ អគារវាលបនៈ, **អតិពហលោដ្ឋកបោលំ** វិសេសនៈរបស់ **មុខំ**, **តេ** សាមិសម្ពន្ធក្នុង **មុខំ**។ លិង្គត្ថៈ ។

## មេរៀនសង្ខេប

បឋមាវិភត្តិមានអត្ថ ៤ យ៉ាង

១. ជាប្រធានក្នុងប្រយោគមិនមានកិរិយា ហៅថា **លិង្គត្ថៈ** ។

២. ជាប្រធានក្នុងប្រយោគកត្តុវាចកៈ ហៅថា **សយកត្តា** ។

៣. ជាប្រធានក្នុងប្រយោគហេតុកត្តុ. ហៅថា **ហេតុកត្តា** ។

៤. ជាប្រធានក្នុងប្រយោគកម្ម.ឬហេតុកម្ម. ហៅថា **វុត្តកម្ម** ។

## ទុតិយាវិភត្តិមានអត្ថ ៦ យ៉ាង

១. ប្រែថា "នូវ" ហៅថា **អវុត្តកម្ម**

២. ប្រែថា "កាន់" ហៅថា **សម្បាបុណិយកម្ម**

៣. ប្រែថា "ញុំាង" ហៅថា **ការិតកម្ម**

៤. ប្រែថា "អស់" ហៅថា **អច្ចន្តសំយោគ**

៥. ប្រែថា "នឹង" ឬ "ចំពោះ" ហៅថា **អកថិតកម្ម**

៦. ជាគ្រឿងធ្វើកិរិយាឱ្យប្លែក ហៅថា **កិរិយាវិសេសនៈ** ។

## តតិយាវិភត្តិមានអត្ថ ៦ យ៉ាង

១. ប្រែថា "ដោយ" ហៅថា **ករណៈ**

២. ប្រែថា "ដោយនូវ" ឬ "តាម" ហៅថា **តតិយាវិសេសនៈ**

៣. ប្រែថា "គឺ"ឬ"ដែល" ហៅថា **អនភិហិតកត្តា**

៤. ប្រែថា "ហេតុ" ឬ "ព្រោះ" ហៅថា **ហេតុ**

៥. ប្រែថា "មាន" ហៅថា **ឥត្ថម្ភូតៈ**

៦. ប្រែថា "ដោយ" ហៅថា **សហត្ថតតិយា** ។

**ចតុត្ថីវិភត្តិ មានអត្ថ ៣ យ៉ាង**

១. ប្រែថា "ដល់" ហៅថា **សម្បទានៈ**

២. ប្រែថា "ដើម្បី ឬ បំរុង" ហៅថា **សម្បទានៈ**

៣. ប្រែថា "នឹង ឬ ចំពោះ" ហៅថា **សម្បទានៈ ២**

**បញ្ចមីវិភត្តិ មានអត្ថ ៣ យ៉ាង**

១. ប្រែថា "អំពី ឬ ចាក" ហៅថា **អបាទានៈ**

២. ប្រែថា "ជាង" ហៅថា **វិភជ្ជនាបាទានៈ**

៣. ប្រែថា "ហេតុ ឬ ព្រោះ" ហៅថា **ហេតុ ២**

**ឆដ្ឋីវិភត្តិមានអត្ថ ៦ យ៉ាង**

១. ប្រែថា "នៃ ឬ របស់" ហៅថា **សាមិសម្ពន្ធៈ**

២. ប្រែថា "នៃ..." ហៅថា **សមូហសម្ពន្ធៈ**

៣. ប្រែថា "នៃ..." ហៅថា **ភាវាទិសម្ពន្ធៈ**

៤. ប្រែថា "កាលបើ, កាលដែល" ហៅថា **អនាទរៈ**

៥. ប្រែថា "ជំនុំ ឬ បណ្តា" ហៅថា **និទ្ធារណៈ**

៦. ប្រែថា "នូវ..." ហៅថា **ឆដ្ឋីកម្មៈ**

## **សត្តមីវិភត្តិមានអត្ថ ៩ យ៉ាង**

១. ប្រែថា "ក្នុង" ហៅថា **បដិច្ឆន្នាធារៈ**

២. ប្រែថា "ក្នុង" ហៅថា **ព្យាបិកាធារៈ**

៣. ប្រែថា "ក្នុង" ហៅថា **វេសយិកាធារៈ**

៤. ប្រែថា "ក្នុង" ហៅថា **កាលត្ថសត្តមី**

៥. ប្រែថា "លើ, ឰដ៏, ត្រង់, នា" ហៅថា **ឧបសិលេសិកាធារៈ**

៦. ប្រែថា "នាកាល, កាលបើ" ហៅថា **លក្ខណៈ**

៧. ប្រែថា "និមិត្ត" ហៅថា **និមិត្តសត្តមី**

៨. ប្រែថា "ជំនុំ ឬ បណ្តា.." ហៅថា **និទ្ធារណៈ**

៩. ប្រែថា "ទៀប ឬ ជិត.." ហៅថា **សមីបាធារៈ ។**

## **អាលបនៈមានអត្ថ ២ យ៉ាង**

១. ប្រែថា "បពិត្រ.." ហៅថា **សគារវាលបនៈ**

២. ប្រែថា "ម្នាល, នែ, ហៃ" ហៅថា **អគារវាលបនៈ ។**

## **គុណនាម**

បទដែលជាគុណនាមមានអត្ថ ៤ យ៉ាងដូច្នេះ

១)ជាគ្រឿងធ្វើនាមនាម ឱ្យមានសេចក្តីប្លែកជាង ប្រក្រតីហៅថា " **វិសេសនៈ** " ឬ " **តុល្យាធិករណវិសេសនៈ** "

ឧ. **អគ្គោ ពុទ្ធោ** ។ (ប្រែ) **ពុទ្ធោ** វីព្រះពុទ្ធ **អគ្គោ** <u>ព្រះអង្គដ៏ប្រសើរ</u> ។

(សម្ពន្ធ) **អគ្គោ** វិសេសនៈរបស់ **ពុទ្ធោ**ៗ លិង្គត្ថៈ ។

២) ជាគុណនាមសុទ្ធក្តី ជានាមនាម តែយកមកប្រើដូចជាគុណនាមក្តី ដែលចូលនឹងកិរិយាសព្ទប្រែថា "មាន" ថា "កើត" ថា "ជា" ហៅថា វិកតិកត្តា (កាលបើមានបទមួយជាវិកតិកត្តា ដូច្នេះត្រង់បទមួយដែលប្រែថា " វី " ដែលជាសយកត្តានោះត្រឡប់ទៅ ជាហៅថា **បកតិកត្តា** ។

ឧ. **អប្បស្សុតោ ហោតិ ខ** (ប្រែ) **បុរិសោ** វីបុរស <u>**អប្បស្សុតោ ហោតិ**</u> ជាអ្នកមានពុទ្ធវចនៈមានប្រមាណតិចស្តាប់ហើយ ។

(សម្ពន្ធ) **បុរិសោ** បកតិកត្តាក្នុង **ហោតិ**ៗ អាខ្យាត.កត្តុ., **អប្បស្សុតោ** វិកតិកត្តាក្នុង **ហោតិ** ។

៣) បទវិសេសន ដែលប្រកបដោយបឋមាវិភត្តិក្នុង ប្រយោគដែលជាកម្មវាចកៈ ហៅថា **វិកតិវុត្តកម្ម**

ឧ. **បាណាតិបាតកម្មស្ស ខោ ភន្តេ** <u>**អការកោ**</u> **ភគោ ខ** (ប្រែ) **ភន្តេ** បពិត្រព្រះអង្គដ៏ចំរើន ( **កុក្កុដមិត្តោ** វីអ្នកនេសាទឈ្មោះកុក្កុដមិត្ត ) **ខោ** គឺព្រះអង្គ **ភគោ** ទ្រង់ធ្វើហើយ <u>**អការកោ**</u>

ឱ្យជាអ្នកមិនធ្វើ **បាណាតិបាតកម្មស្ស** នូវបាណាតិបាតកម្ម (ឬ?) ។

(សម្ពន្ធ) **ភន្តេ** សគារវាលបនៈ **កុក្កុដមិត្តោ** បកតិវុត្តកម្មក្នុង **កតោ**ៗ កិតបទ_កម្មវាចកៈ, **បាណាតិបាតកម្មស្ស** ឆដ្ឋីកម្មក្នុង **អការកោ**ៗ វិកតិវុត្តកម្មក្នុង **កតោ**, **តេ** អនភិហិតកត្តាក្នុង **កតោ** ។

៤) បទវិសេសនៈ ដែលប្រកបដោយទុតិយាវិភត្តិចូលជា មួយនឹងកិរិយាអាខ្យាតថា " ធ្វើ " ជាកត្តុវាចកៈ ហៅថា វិកតិអវុត្តកម្ម (កាលបើមានបទមួយជា វិកតិអវុត្តកម្ម ដូច្នេះត្រង់បទមួយ ដែលប្រែថា "នូវ" ដែលជា អវុត្តកម្មនោះ ត្រឡប់ទៅជាហៅថា **បកតិអវុត្តកម្ម** ៥

ឧ. **ឥមំ អត្ថំ បាកដំ ករោហិ** ៥ (ប្រែ) (ត្វំ វីអ្នក) **ករោហិ** ចូរធ្វើ **អត្ថំ** នូវសេចក្តី **ឥមំ** នេះ **បាកដំ** ឱ្យប្រាកដ ។

(សម្ពន្ធ) ត្វំ សយកត្តាក្នុង **ករោហិ**ៗ អាខ្យាត.កត្តុ., **ឥមំ** វិសេសនៈរបស់ **អត្ថំ**ៗ បកតិអវុត្តកម្មក្នុង **ករោហិ**, **បាកដំ** វិកតិអវុត្តកម្មក្នុង **ករោហិ** ។

## សព្វនាម

បទដែលជាសព្វនាមមានអត្ថ ២ យ៉ាងគឺ :

១) បើជាបុរិសសព្វនាមសម្ពន្ធដូចបទនាមនាម "ត" ដែលប្រែថា "ព្រះអង្គ"

ឧ. ស្វេ សត្ថា ឥធាគមិស្សតិ, មយំ តំ វន្ទិស្សាម, តស្ស ធម្មំ សុណិស្សាម ២ (ប្រែ) ស្វេ ក្នុងថ្ងៃស្អែក សត្ថា រីព្រះជាគ្រូ អាគមិស្សតិ នឹងយាងមក ឥធ (ឋានេ ក្នុងទី)នេះ, មយំ រីយើងទាំង-ឡាយ វន្ទិស្សាម នឹងថ្វាយបង្គំ តំ នូវព្រះអង្គ សុណិស្សាម នឹងស្តាប់ ធម្មំ នូវធម៌ តស្ស នៃព្រះអង្គ ។

(សម្ពន្ធ) សត្ថា សយកត្តាក្នុង អាគមិស្សតិៗ អាខ្យាត.កត្តុ., ស្វេ កាលត្ថសត្តមីក្នុង អាគមិស្សតិ, ឥធ វិសេសនៈរបស់ ឋានេៗ អាធារៈក្នុង អាគមិស្សតិ, មយំ សយកត្តាក្នុង វន្ទិស្សាម សុណិស្សាមៗ អាខ្យាត.កត្តុ., តំ អវុត្តកម្មក្នុង វន្ទិស្សាម, តស្ស សាមិសម្ពន្ធក្នុង ធម្មំៗ អវុត្តកម្មក្នុង សុណិស្សាម ។

"ត" ដែលប្រែថា "លោក" ឧ. មយ្ហំ ឧបជ្ឈាយោ បញ្ចាសីតិវ-ស្សាយុកោ, សោ បន ទេវសិកំ តាវ ភិក្ខុសាមណេរានំ បរិយត្តិធម្មំ វាចេតុំ សក្កោតិ ២ (ប្រែ) ឧបជ្ឈាយោ រីឧបជ្ឈាយ៍ មយ្ហំ របស់ខ្ញុំ បញ្ចាសីតិវស្សាយុកោ មានព្រះជន្ម ៨៥ ឆ្នាំ (ហើយ), បន ប៉ុន្តែ សោ រីលោក សក្កោតិ អាច វាចេតុំ ដើម្បីបង្រៀន បរិយត្តិធម្មំ នូវព្រះបរិយត្តិធម៌ ភិក្ខុសាមណេរានំ ដល់ភិក្ខុ និងសាមណេរទ. តាវ បាននៅឡើយ ។

(សម្ពន្ធ) **មយ្ហំ** សាមិសម្ពន្ធក្នុង **ឧបដ្ឋាយោ។** លិង្គត្ថៈ, **បញ្ញាសីតិវស្សាយុកោ** វិសេសនៈរបស់ **ឧបដ្ឋាយោ**, **បន**-សព្ទ សម្ភារនវាចកៈ, **សោ** សយកត្តាក្នុង **សក្កោតិ។** អាខ្យាត.កត្តុ., **ទេវសិកំ** កិរិយាវិសេសនៈក្នុង **សក្កោតិ**, **តាវ**-សព្ទ កិរិយាវិសេសនៈក្នុង **សក្កោតិ**, **ភិក្ខុសាមណេរានំ** សម្បទានក្នុង **សក្កោតិ**, **បរិយត្តិធម្មំ** អវុត្តកម្មក្នុង **វាចេតុំ។** តុមត្ថសម្បទានក្នុង **សក្កោតិ** ។

"**ត**" ដែលប្រែថា (នាង) ឱ. **វិសាខា មហាឧបាសិកា សទ្ធា អហោសិ ពុទ្ធសាសនេ អភិប្បសន្នា, តថា ច** <u>**តស្សា**</u> **បុត្តធីតរោ** ។ (ប្រែ) **មហាឧបាសិកា** វីមហាឧបាសិកា **វិសាខា** ឈ្មោះវិសាខា **សទ្ធា** ជាស្ត្រីមានសទ្ធា **អភិប្បសន្នា** ជ្រះថ្លាក្រៃពេក **ពុទ្ធសាសនេ** ក្នុងព្រះ ពុទ្ធសាសនា **អហោសិ** បានមានហើយ , **ច** ឯ **បុត្តធីតរោ** វីកូនប្រុសនិងកូនស្រីទាំងឡាយ <u>**តស្សា**</u> របស់នាង **តថា** ក៏ដូច្នោះដែរ ។

(សម្ពន្ធ) **មហាឧបាសិកា** បកតិកត្តាក្នុង **អហោសិ។** អាខ្យាត.កត្តុ., **វិសាខា** សញ្ញាវិសេសនៈរបស់ **មហាឧបាសិកា។** សញ្ញីវិសេ-សយៈ, **សទ្ធា** ក្តី **អភិប្បសន្នា** ក្តី វិកតិកត្តាក្នុង **អហោសិ**, **ពុទ្ធសាសនេ** អាធារៈក្នុង **អភិប្បសន្នា**, **តថា** បុរិមនយជោតកៈ **ច**-

សព្ទ វាក្យារម្ភៈជោតកៈ **តស្សា** សាមិសម្ពន្ធក្នុង **បុត្តធីតរោ** លិង្គត្ថៈ ។

"ត" ដែលប្រែថា "គេ" ថា "គាត់" ៩. **ឯកោ មហល្លកវឡ្ឍកី ឯកគាមវាសីនំ មនុស្សានំ បិយោ អហោសិ មនាបោ, សោហិ តេសំ ឧបការមកាសិ, តស្មឹ បន មតេ, សព្វេបិ តេ ឯកច្ឆន្ទា ហុត្វា សក្កច្ចំ តស្ស សរីរកិច្ចមកំសុ** ។ (ប្រែ) **មហល្លកវឡ្ឍកី** វីជាងឈើចាស់ **ឯកោ** ម្នាក់ **បិយោ មនាបោ អហោសិ** បានជាទីស្រឡាញ់ពេញចិត្ត **មនុស្សានំ** នៃមនុស្សទាំងឡាយ **ឯកគាមវាសីនំ** អ្នកនៅក្នុងស្រុកជាមួយ, **ហិ** ព្រោះ **សោ** វីគាត់ **អកាសិ** បានធ្វើហើយ **ឧបការំ** នូវ សេចក្តីទំនុកបំរុង **តេសំ** ដល់គេទាំងឡាយ, **បន** ក៏ **តស្មឹ** កាលដែលគាត់ **មតេ** ស្លាប់ហើយ, **តេ** វីគេទាំងឡាយ **សព្វេបិ** ទាំងអស់គ្នា **ឯកច្ឆន្ទា ហុត្វា** ជាអ្នកមានសេចក្តីពេញចិត្តតែមួយ **អកំសុ** បានធ្វើហើយ **សរីរកិច្ចំ** នូវសរីរកិច្ច **តស្ស** នៃគាត់ **សក្កច្ចំ** ដោយយកចិត្តទុកដាក់ ។

(សម្ពន្ធ) **ឯកោ** វិសេសនៈរបស់ **មហល្លកវឡ្ឍកី** បកតិកត្តាក្នុង **អហោសិ** អាខ្យាត.កត្តុ., **ឯកគាមវាសីនំ** វិសេសនៈរបស់ **មនុស្សានំ** សាមិសម្ពន្ធក្នុង **បិយោ មនាបោ** វិកតិកត្តាក្នុង **អហោសិ**, **ហិ**_សព្ទ ផលជោតកៈ, **សោ** សយកត្តាក្នុង **អកាសិ**

អាខ្យាត.កត្តុ., **តេសំ** សម្បទានក្នុង **អកាសិ**, **ឧបការំ** អវុត្តកម្មក្នុង **អកាសិ**, **បន** សព្ទវាក្យារម្ភៈ, **តស្មឹ** លក្ខណៈក្នុង **មតេ**ៗ លក្ខណៈកិរិយា, **សព្វេ** វិសេសនៈរបស់ តេៗ សយកត្តាក្នុង **អកំសុ**ៗ អាខ្យាត.កត្តុ., **ចិ**_សព្ទ អបេក្ខត្ថៈក្នុង **សព្វេ**, **ឯកច្ឆន្ទា** វិកតិកត្តាក្នុង **ហុត្វា**ៗ កិរិយាវិសេសនៈក្នុង **អកំសុ**, **សក្កច្ចំ** តតិយាវិសេសនៈក្នុង **អកំសុ**, **តស្ស** សាមិសម្ពន្ធក្នុង **សរីរកិច្ចំ**ៗ អវុត្តកម្មក្នុង **អកំសុ** ។

"**ត**" ដែលប្រែថា "វា" ឧ. **ឯកោ មេ អចជាតបុត្តោ អត្ថិ, នេវ តំ ឱវាទំ គណ្ហាបេតុំ សក្កោមិ, ឥទានិ បន សោ ពាឡ្ហគិលានោ**, "**តុម្ហ**" ដែលប្រែថា "ព្រះអង្គ" ឧ. **ភន្តេ កឹ តុម្ហេយេវ គមិស្សថ** ៗ (ប្រែ) **ភន្តេ** បពិត្រព្រះអង្គដ៏ចំរើន **តុម្ហេ ឯវ** វីព្រះអង្គតែមួយអង្គឯង **គមិស្សថ** នឹងស្តេចទៅ **កឹ** ទេវី ?

(សម្ពន្ធ) **ភន្តេ** សគារវាលបនៈ, **កឹ**_សព្ទ បុច្ឆនត្ថៈ, **តុម្ហេ** សយកត្តាក្នុង **គមិស្សថ**ៗ អាខ្យាត.កត្តុ., **ឯវ**_សព្ទ អវធារណៈក្នុង **តុម្ហេ** ។

"**តុម្ហ**" ដែលប្រែថា "លោក" ឧ. **ភន្តេ កុហឹ តុម្ហេ គមិស្សថ** ។ (ប្រែ) **ភន្តេ** បពិត្រព្រះអង្គដ៏ចំរើន **តុម្ហេ** វីលោក **គមិស្សថ** នឹង និមន្តទៅ **កុហឹ** ក្នុងទីណា ?

(សម្ពន្ធ) **ភន្តេ** សគារវាលបនៈ, **តុម្ហេ** សយកត្តាក្នុង **គមិស្សថ**។ អាខ្យាត.កត្តុ., **កុហឹ** វិសេសនៈរបស់ **ឋានេ**។ អាធារៈក្នុង **គមិស្សថ** ។

"តុម្ហ" ដែលប្រែថា "អ្នក" ឧ. **អាវុសោ ត្វំ មា ឯវំ ចិន្តយិ** ។ (ប្រែ) **អាវុសោ** ម្នាលអាវុសោ **ត្វំ** វីអ្នក **មា** **ចិន្តយិ** កុំគិត **ឯវំ** យ៉ាង នេះឡើយ ។

(សម្ពន្ធ) **អាវុសោ** អគារវាលបនៈ, **ត្វំ** សយកត្តាក្នុង **ចិន្តយិ**។ អាខ្យាត.កត្តុ., **មា**-សព្ទ បដិសេធក្នុង **ចិន្តយិ**, **ឯវំ** កិរិយាវិសេសនៈ ក្នុង **ចិន្តយិ** ។

"តុម្ហ" ដែលប្រែថា "នាង" ឧ. **សចេ ហិ តុម្ហេ មាទិសស្ស ពុទ្ធស្ស សម្មុខីភាវំ នាគមិស្សថ** ។ (ប្រែ) **សចេ ហិ** ប្រសិនបើ **តុម្ហេ** វីនាងទាំងឡាយ **ន** **អាគមិស្សថ** នឹងមិនមកហើយ **សម្មុខី-ភាវំ** កាន់ភាវៈចំពោះមុខ **ពុទ្ធស្ស** នៃព្រះពុទ្ធ **មាទិសស្ស** ប្រាកដដូច តថាគត ។

(សម្ពន្ធ) **សចេ**-សព្ទ បរិកប្បត្ថវាចកៈ, **ហិ**-សព្ទ បទបូរណៈ, **តុម្ហេ** សយកត្តាក្នុង **អាគមិស្សថ**។ អាខ្យាត.កត្តុ., **មាទិសស្ស** វិសេសនៈ របស់ **ពុទ្ធស្ស**។ ភាវាទិសម្ពន្ធៈ **សម្មុខីភាវំ**។ សម្បាបុណិយកម្មក្នុង

**អាគមិស្សថ**, ន-សព្ទ បដិសេធក្នុង **អាគមិស្សថ** ។

"ត្ថម្ភេ" ដែលប្រែថា "ឯង" ឧ. **អរេ ឥតោ តាវ ត្វំ ឯហិ** ៗ (ប្រែ) **អរេ** នែអាចង្រៃ **ត្វំ** រីឯង **ឯហិ** ចូរមក **ឥតោ** ត្រង់នេះ **តាវ** សិន ។

(សម្ពន្ធ) **អរេ** អគារវាលបនៈ, **ត្វំ** សយកត្តាក្នុង **ឯហិ**ៗ អាខ្យាត.កត្តុ., **ឥតោ** អាធារៈក្នុង **ឯហិ**, **តាវ**-សព្ទ កិរិយាវិសេសនៈ ក្នុង **ឯហិ** ។

"ត្ថម្ភ" ដែលប្រែថា "អា" ឧ. **អរេ ទុដ្ឋកុដ្ឋិ កឹ ត្វំ វទេសិ ? មាតិសា ខុជ្ជា នាម ហោតិ** ៗ (ប្រែ) **ទុដ្ឋកុដ្ឋិ** នែអាគំលង់កំណាច **អរេ** ចង្រៃ **ត្វំ** រីអា **វទេសិ** ពោល **កឹ** ថាម៉េច? **មាតិសា** រីស្ត្រីអំបាលដូចអញ **ខុជ្ជា នាម ហោតិ** (នៅថា) ជាស្ត្រីគម ។

(សម្ពន្ធ) **អរេ** វិសេសនៈរបស់ **ទុដ្ឋកុដ្ឋិ**ៗ អគារវាលបនៈ, **ត្វំ** សយកត្តាក្នុង **វទេសិ**ៗ អាខ្យាត.កត្តុ., **កឹ** វិសេសនៈរបស់ **វទេសិ**, **មាតិសា** បកតិកត្តាក្នុង **ហោតិ**ៗ អាខ្យាត.កត្តុ., **ខុជ្ជា** វិកតិកត្តាក្នុង **ហោតិ**, **នាម**-សព្ទ សញ្ញាជោតកៈក្នុង **ខុជ្ជា** ។

"ត្ថម្ភ" ដែលប្រែថា "ហង" ឧ. **អរេ ខុជ្ជេ អតិពហលោដ្ឋ~កបោលំ តេ មុខំ, ឯទំ នាម ( ត្វំ ) វទេហិ** ៗ (ប្រែ) **អរេ ខុជ្ជេ**

នៃមេគម ចង្រៃ **មុខំ** វីមាត់ **តេ** នៃហង **អតិពហលោដ្ឋកចោលំ** មានបបូរក្រោស ឃ្នើកពេកណាស់, **ត្វំ** វីហង **វទេហិ** ចូរថា **ឯវំ** **នាម** ឈ្មោះយ៉ាងនេះ ។

(សម្ពន្ធ) **អរេ** វិសេសនៈរបស់ **ខុជ្ជេ**។ អគារវាលបនៈ, **អតិពហលោដ្ឋកចោលំ** វិសេសនៈរបស់ **មុខំ**, **តេ** សាមិសម្ពន្ធក្នុង **មុខំ**។ លិង្គត្ថៈ, **ត្វំ** សយកត្តាក្នុង **វទេហិ**។ អាខ្យាត.កត្តុ., **ឯវំ** កិរិយា_វិសេសនៈក្នុង **វទេហិ**, **នាម**_សព្ទ សញ្ញាជោតកៈក្នុង **ឯវំ** ។

"**អម្ហ**" សព្ទ ដែលប្រែថា "ខ្ញុំព្រះអង្គ, ខ្ញុំព្រះករុណា, ខ្ញុំបាទ, ខ្ញុំឯង, អញខ្ញុំ, ខ្ញុំម្ចាស់, ខ្ញុំ, អាត្មាភាព, អាត្មា, អញ, យើង, យើងខ្ញុំ" ។

"**អម្ហ**" ដែលប្រែថា "ខ្ញុំព្រះអង្គ" ឧ. **ឧបជ្ឈាយោ** <u>**មេ**</u> **ភន្តេ** **បំសុកូលិកោ**, **ឯវំ** **អហំ** **បិ** **បំសុកូលិកោ** ៗ (ប្រែ) **ភន្តេ** បពិត្រ_ព្រះអង្គដ៏ចំរើន **ឧបជ្ឈាយោ** វីព្រះឧបជ្ឈាយ៍ <u>**មេ**</u> <u>របស់ខ្ញុំព្រះអង្គ</u> **បំសុកូលិកោ** **ហោតិ** ជាអ្នកប្រព្រឹត្តបង្សុកូល, **បិ** ក៏ <u>**អហំ**</u> <u>វីខ្ញុំ_ព្រះអង្គ</u> **បំសុកូលិកោ** **អម្ហិ** ជាអ្នកប្រព្រឹត្តបង្សុកូល **ឯវំ** យ៉ាងនេះ ។

(សម្ពន្ធ) **ភន្តេ** សគារវាលបនៈ, **ឧបជ្ឈាយោ** បកតិកត្តាក្នុង **ហោតិ**។ អាខ្យាត_កត្តុ., **មេ** សាមិសម្ពន្ធក្នុង **ឧបជ្ឈាយោ**, **បំសុកូលិកោ** វិកតិកត្តាក្នុង **ហោតិ**, **អហំ** បកតិកត្តាក្នុង **អម្ហិ**។

អាខ្យាត.កត្តុ., **ឯវំ** កិរិយាវិសេសនៈក្នុង **អម្ហិ**, **ចិ**_សព្ទ អបេក្ខត្ថៈក្នុង **អហំ**, **បំសុកូលិកោ** វិកតិកត្តាក្នុង **អម្ហិ** ។

“**អម្ហ**” ដែលប្រែថា “ខ្ញុំព្រះករុណា” ឧ. **ឯសាហំ ភន្តេ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច, ឧបាសកំ មំ អយ្យោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ** ឧ (ប្រែ) **ភន្តេ** បពិត្រព្រះអង្គដ៏ចំរើន **អហំ** វីខ្ញុំព្រះករុណា **ឯសោ** នេះ **គច្ឆាមិ** សូមដល់ **តំ ភគវន្តំ ច** នូវព្រះដ៏មានព្រះភាគនោះផង **ធម្មំ ច** នូវព្រះធម៌ផង **ភិក្ខុសង្ឃំ ច** នូវភិក្ខុសង្ឃផង **សរណំ** ជាទីពឹងទីរឭក, **អយ្យោ** វីលោកម្ចាស់ **ធារេតុ** សូមចាំទុក **មំ** នូវខ្ញុំព្រះករុណា **ឧបាសកំ** ថាជាឧបាសក **បាណុបេតំ** ដល់នូវព្រះត្រៃ-សរណៈស្មើដោយជីវិត **អជ្ជតគ្គេ** ក្នុងកាលមានថ្ងៃនេះជាដើមតទៅ ។

(សម្ពន្ធ) **ភន្តេ** សគារវាលបនៈ, **ឯសោ** វិសេសនៈរបស់ **អហំ**ៗ សយកត្តាក្នុង **គច្ឆាមិ**ៗ អាខ្យាត.កត្តុ., **តំ** វិសេសនៈរបស់ **ភគវន្តំ**ៗ ក្តី **ធម្មំ** ក្តី **ភិក្ខុសង្ឃំ** ក្តី បកតិអវុត្តកម្មក្នុង **គច្ឆាមិ**, **សរណំ** វិកតិអវុត្ត-កម្មក្នុង **គច្ឆាមិ**, **ច** ទាំងពីរបទ បទសមុច្ចយក្នុង **ធម្មំ ភិក្ខុសង្ឃំ**, **អយ្យោ** សយកត្តាក្នុង **ធារេតុ**ៗ អាខ្យាត.កត្តុ., **មំ** បកតិអវុត្តកម្មក្នុង **ធារេតុ**, **ឧបាសកំ** វិកតិអវុត្តកម្មក្នុង **ធារេតុ**, **បាណុបេតំ** ក្តី **សរណំ**

ក្តី **គតំ** ក្តី វិសេសនៈរបស់ **មំ**, **អជ្ជតគ្គេ** កាលត្ថសត្តមីក្នុង **ធារេត្** ៗ

"**អម្ហ**" ដែលប្រែថា "ខ្ញុំឯង" ឧ. **អហមេវ** **នូន** **ពាលោ** **ហោមិ** ។ (ប្រែ) **អហំ** **ឯវ** វីខ្ញុំឯង **ពាលោ** **ហោមិ** ជាជនពាល **នូន** ដោយពិត ។

(សម្ពន្ធ) **អហំ** បកតិកត្តាក្នុង **ហោមិ**ៗ អាខ្យាត.កត្តុ., **ឯវ**-សព្ទ អវធារណៈក្នុង **ហោមិ**, **នូន** កិរិយាវិសេសនៈក្នុង **ហោមិ**, **ពាលោ** វិកតិកត្តាក្នុង **ហោមិ** ។

"**អម្ហ**" ដែលប្រែថា "ខ្ញុំម្ចាស់" ឧ. **ទេវ** **សចេ** **មេ** **ន** **សទ្ទហសិ**, **ឯតំ** **កោដ្ឋកំ** **បវិស**, **អហន្តំ** **ឥមិនា** **វាតបានេន** **ឱលោកេស្សាមិ** ៗ (ប្រែ) **ទេវ** បពិត្រព្រះអាទិទេព **ចេ** បើ **ត្វំ** វីព្រះអង្គ **ន** **សទ្ទហសិ** ទ្រង់ពុំជឿ (**វចនំ** នូវពាក្យ) **មេ** នៃខ្ញុំម្ចាស់ , **ឯតំ** នុ៎ះ, **អហំ** វីខ្ញុំម្ចាស់ **ឱលោកេស្សាមិ** នឹងចាំមើល **តំ** នូវព្រះអង្គ **វាតបានេន** តាមព្រះកៅវតា (**ភវតា**) **ឥមិនា** នេះ ។

(សម្ពន្ធ) **ទេវ** សគារវាលបនៈ, **សចេ**-សព្ទ បរិកប្បត្ថ, **ត្វំ** សយកត្តាក្នុង **សទ្ទហសិ**ៗ អាខ្យាត.កត្តុ., **មេ** សាមិសម្ពន្ធក្នុង **វចនំ**ៗ អវុត្តកម្មក្នុង **សទ្ទហសិ**, **ន**-សព្ទ បដិសេធក្នុង **សទ្ទហសិ**, **ត្វំ** សយកត្តាក្នុង **បវិស**ៗ អាខ្យាត.កត្តុ., **ឯតំ** វិសេសនៈរបស់

**គោជរូក៌ំ** សម្បាបុណិយកម្មក្នុង **បវិស**, **អហំ** សយកត្តាក្នុង **ឱលោកេស្សាមិ** អាខ្យាត.កត្តុ., **តំ** អវុត្តកម្មក្នុង **ឱលោកេស្សាមិ**, **ឥមិនា** វិសេសនៈរបស់ **ទ្វារេន** វិសេសនត្ថតតិយាក្នុង **ឱលោកេស្សាមិ** ៕

"**អម្ម**" ដែលប្រែថា "ខ្ញុំ" ឧ. **ឥច្ឆាមហំ អម្ម ថេរស្ស សន្តិកេ បព្វជិតុំ** ៕ (ប្រែ) **អម្ម** បពិត្រអ្នកម្តាយ **អហំ** រីខ្ញុំ **ឥច្ឆាមិ** ចង់ **បព្វជិតុំ** ដើម្បីបួស **សន្តិកេ** ក្នុងសំណាក់ **ថេរស្ស** នៃព្រះថេរៈ ។

(សម្ពន្ធ) **អម្ម** សគារវាលបនៈ, **អហំ** សយកត្តាក្នុង **ឥច្ឆាមិ** អាខ្យាត.កត្តុ., **ថេរស្ស** សាមិសម្ពន្ធក្នុង **សន្តិកេ** វេសយិកាធារៈក្នុង **បព្វជិតុំ** តុមត្ថសម្បទានក្នុង **ឥច្ឆាមិ** ៕

"**អម្ម**" ដែលប្រែថា "អាត្មាភាព" ឧ. **តេនហិ មហារាជ អហំ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ** ៕ (ប្រែ) **មហារាជ** បពិត្រមហារាជ **តេនហិ** បើដូច្នោះ **អហំ** រីអាត្មាភាព **បដិបុច្ឆិស្សាមិ** នឹងសូមថ្វាយព្រះពរសួរត្រឡប់ **តំ** **ឯវ** នូវព្រះអង្គវិញ **ឯត្ថបញ្ហេ** ក្នុងប្រស្នានេះ ។

(សម្ពន្ធ) **មហារាជ** សគារវាលបនៈ, **តេនហិ** វិភត្តិបដិរូបកៈ, **អហំ** សយកត្តាក្នុង **បដិបុច្ឆិស្សាមិ**, **ឯវ**-សព្ទ អវធារណៈក្នុង **តំ**, **ឯត្ថ** វិសេសនៈរបស់ **បញ្ហេ** អាធារៈក្នុង **បដិបុច្ឆិស្សាមិ** ។

**"អម្ហ"** ដែលប្រែថា "អាត្មា" ឧ. **អហំ ថេរស្ស ភាគនេ-យ្យោ អម្ហិ ។** (ប្រែ) **អហំ** រីអាត្មា **ភាគិនេយ្យោ អម្ហិ** ជាក្មួយ **ថេរស្ស** នៃព្រះថេរៈ ។

(សម្ពន្ធ) **អហំ** បកតិកត្តាក្នុង **អម្ហិ**ៗ អាខ្យាត.កត្តុ., **ថេរស្ស** សាមិសម្ពន្ធក្នុង **ភាគិនេយ្យោ**ៗ វិកតិកត្តាក្នុង **អម្ហិ ។**

**"អម្ហ"** ដែលប្រែថា "អញ" ឧ. **នាហំ មម បុត្តស្ស អជ្ឈាសយំ ភិន្ទិស្សាមិ ។** (ប្រែ) **អហំ** រីអញ **ន ភិន្ទិស្សាមិ** នឹងមិនទំលាយ **អជ្ឈាសយំ** នូវអធ្យាស្រ័យ **បុត្តស្ស** នៃកូន **មម** របស់អញ ។

(សម្ពន្ធ) **អហំ** សយកត្តាក្នុង **ភិន្ទិស្សាមិ**ៗ អាខ្យាត.កត្តុ., **មម** សាមិសម្ពន្ធក្នុង **បុត្តស្ស**ៗ សាមិសម្ពន្ធក្នុង **អជ្ឈាសយំ**ៗ អវុត្តកម្មក្នុង **ភិន្ទិស្សាមិ ។**

**"អម្ហ"** ដែលប្រែថា "យើង" ឧ. **មហល្លកកាលេ បព្វជិតា មយំ ។** (ប្រែ) **មយំ** រីយើង **បព្វជិតា** បួសហើយ **មហល្លកកាលេ** ក្នុងកាលដែលយើងចាស់ ។

(សម្ពន្ធ) **មហល្លកកាលេ** កាលត្ថសត្តមីក្នុង **បព្វជិតា**ៗ វិសេសនៈរបស់ **មយំ**ៗ លិង្គត្ថៈ ។

២) បើជាវិសេសនសព្វនាម សម្ពន្ធ ដូចគុណនាម ទាំងនិយមៈ ទាំងអនិយមៈ ឧ. យស្មឹំ ភគវតិ មយំ អភិប្បសន្នា, តំ ភគវន្តំ សរណំ គតា ឌ (ប្រែ) មយំ វីយើងទាំងឡាយ អភិប្បសន្នា ជ្រះថ្លាហើយក្រៃពេក ភគវតិ ក្នុងព្រះដ៏មានព្រះភាគ យស្មឹំ អង្គណា, មយំ វីយើង ទាំងឡាយ គតា ដល់ហើយ ភគវន្តំ នូវព្រះដ៏មានព្រះភាគ តំ អង្គនោះ សរណំ ជាទីពឹង ។

(សម្ពន្ធ) មយំ សយកត្តាក្នុង អភិប្បសន្នា។ កិតបទ_កត្តុវាចកៈ, យស្មឹំ វិសេសនៈរបស់ ភគវតិ។ អាធារៈក្នុង អភិប្បសន្នា, មយំ សយកត្តាក្នុង គតា។ កិតបទ_កត្តុវាចកៈ តំ វិសេសនៈរបស់ ភគវន្តំ។ បកតិអវុត្តកម្មក្នុង គតា, សរណំ វិកតិអវុត្តកម្មក្នុង គតា ។ យោ បន ភិក្ខុ សមគ្គស្ស សង្ឃស្ស ភេទាយ បរក្កមេយ្យ, ភេទនសំវត្តនិកំ វា អធិករណំ សមាទាយ បគ្គយ្ហ តិដ្ឋេយ្យ, សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស វចនីយោ ។ (ប្រែ) យោ បន ភិក្ខុ វីភិក្ខុណាមួយ បរក្កមេយ្យ គប្បីព្យាយាម ភេទាយ ដើម្បីការបំបែក សង្ឃស្ស នូវសង្ឃ សមគ្គស្ស ដែលកំពុងព្រមព្រៀងគ្នា, វា ឬថា សមាទាយ ប្រកាន់ហើយ បគ្គយ្ហ ផ្គងឡើងហើយ អធិករណំ នូវអធិករណ៍ ភេទនសំវត្តនិកំ ដែលដឹក នាំសង្ឃឱ្យបែកគ្នា តិដ្ឋេយ្យ

គប្បីស្ថិតនៅ, **ភិក្ខុ** រីភិក្ខុ <u>សោ</u> <u>នោះ</u> **ឯវំ ភិក្ខូហិ វចនីយោ អស្ស** ជាបុគ្គលត្រូវភិក្ខុទាំងឡាយពោលហាមដោយ ពាក្យយ៉ាងនេះ ។

(សម្ពន្ធ) **យោ** វិសេសនៈរបស់ **ភិក្ខុ។** សយកត្តាក្នុង **បរក្កមេយ្យ** និង **តិដ្ឋេយ្យ។** អាខ្យាត.កត្តុ., **បន**_សព្ទ បទបូរណៈក្នុង **យោ, សមគ្គស្ស** វិសេសនៈរបស់ **សង្ឃស្ស។** ឆដ្ឋីកម្មក្នុង **ភេទាយ។** សម្បទានក្នុង **បរក្កមេយ្យ, វា**_សព្ទ វាក្យវិកប្ប, **ភេទនសំវត្តនិកំ** វិសេសនៈ របស់ **អធិករណំ។** អវុត្តកម្មក្នុង **សមាទាយ។** ក្តី **បគ្គយ្ហ** ក្តី បុព្វកាលកិរិយាក្នុង **តិដ្ឋេយ្យ, សោ** វិសេសនៈរបស់ **ភិក្ខុ។** បកតិវុត្តកម្មក្នុង **អស្ស។** អាខ្យាត.កត្តុ., **ភិក្ខូហិ** អនភិហិតកត្តាក្នុង **វចនីយោ, ឯវំ** កិរិយាវិសេសនៈរបស់ **វចនីយោ។** វិកតិវុត្តកម្មក្នុង **អស្ស ។**

## កិរិយាអាខ្យាត

បទដែលជាកិរិយាអាខ្យាតសម្ពន្ធតាមវាចកៈ ទាំង ៥ ដូច្នេះ :

១) បើជាកត្តុវាចកៈហៅថា អាខ្យាតបទ_កត្តុវាចកៈ

**ឧ. សូទោ ឱទនំ បចតិ ។** (ប្រែ) **សូទោ** រីអ្នកគ្រូ **បចតិ** កំពុង ចំអិន **ឱទនំ** នូវបាយ ។

(សម្ពន្ធ) **សូទោ** សយកត្តាក្នុង **បចតិ។** អាខ្យាត_កត្តុ., **ឱទនំ**

អវុត្តកម្មក្នុង **បចតិ** ។

២) បើជាកម្មវាចកៈហៅថា អាខ្យាតបទ-កម្មវាចកៈ ឧ. **សូទេន ឱទនោ** __**បចិយតេ**__ ។ (ប្រែ) **ឱទនោ** វីបាយ **សូទេន** គឺអ្នកគ្រួ __**បចិយតេ**__ __កំពុងចំអិន__ ។

(សម្ពន្ធ) **ឱទនោ** វុត្តកម្មក្នុង **បចិយតេៗ** អាខ្យាត-កម្ម., **សូទេន** អនភិហិតកត្តាក្នុង **បចិយតេ** ។

៣) បើជាភាវវាចកៈ ហៅថា អាខ្យាតបទ-ភាវវាចកៈ ឧ. **ភិក្ខុនា ធម្មំ** __**បរិយាបុណាយតេ**__ ។ (ប្រែ) **ភិក្ខុនា** គឺភិក្ខុ __**បរិយាបុណាយតេ**__ __កំពុងរៀន__ **ធម្មំ** នូវធម៌ ។

(សម្ពន្ធ) **ភិក្ខុនា** អនភិហិតកត្តាក្នុង **បរិយាបុណាយតេៗ** អាខ្យាត-ភាវ., **ធម្មំ** អវុត្តកម្មក្នុង **បរិយាបុណាយតេ** ៕

៤) បើជាហេតុកត្តុវាចកៈ ហៅថា អាខ្យាតបទ-ហេតុកត្តុ-វាចកៈ ឧ. **សាមិកោ ទាសំ អគ្គឹ** __**ជាលេតិ**__ ។ (ប្រែ) **សាមិកោ** វីម្ចាស់ **ទាសំ** ញុាំងខ្ញុំប្រុស __**ជាលេតិ**__ __ឱ្យអុជ__ **អគ្គឹ** នូវភ្លើង ។

(សម្ពន្ធ) **សាមិកោ** ហេតុកត្តាក្នុង **ជាលេតិៗ** អាខ្យាត-ហេតុកត្តុ., **ទាសំ** ការិតកម្មក្នុង **ជាលេតិ**, **អគ្គឹ** អវុត្តកម្មក្នុង **ជាលេតិ** ។

៥) បើជាហេតុកម្មវាចកៈ ហៅថា អាខ្យាតបទ-ហេតុកម្មវាចកៈ

ឧ. **សាមិកេន ទាសំ ឱទនោ ចាចាបិយតេ** ។ (ប្រែ) **ឱទនោ** រីបាយ **សាមិកេន** គឺម្ចាស់ **ទាសំ** ញុំាងខ្ញុំប្រុស **ចាចាបិយតេ** ឱ្យចំអិន ។

(សម្ពន្ធ) **ឱទនោ** វុត្តកម្មក្នុង **ចាចាបិយតេ**ៗ អាខ្យាត-ហេតុកម្ម., **សាមិកេន** អនភិហិតកត្តាក្នុង **ចាចាបិយតេ**, **ទាសំ** ការិតកម្មក្នុង **ចាចាបិយតេ** ។

## កិរិយាកិតកៈ

កិតបទ ដែលជាកិរិយា មាន ៨ យ៉ាងផ្សេងៗ គ្នា ដូច្នេះ :

### អន្ត និង មាន-បច្ច័យ

១) បើរៀងទុកខាងដើមនាមនាមដែលជាម្ចាស់របស់ហៅថា វិសេសនៈ ឧ. **ខន្ធាទីសុ បន ភគវេន នុ ខោ មុខេន ឥមំ បដិបទំ ភជេន្តោ អហំ សត្ថុ អជ្ឈាសយំ គណ្ហិតុំ សក្ខិស្សាមិ ខ** (ប្រែ) **បន** ក៏ **អហំ** រីអញ **ភជេន្តោ** កាលឆ្លើយ **បដិបទំ** នូវសេចក្ដីប្រតិបត្តិ **ឥមំ** នេះ (**មុខេសុ** ជំនុំមុខទ.) **ខន្ធាទីសុ** មានខន្ធជាដើម **មុខេន** ដោយមុខ **ភគវេន នុ ខោ** ណាអេះ **សក្ខិស្សាមិ** នឹងអាច **គណ្ហិតុំ** ដើម្បីតម្រូវ **អជ្ឈាសយំ** នូវអធ្យាស្រ័យ **សត្ថុ** នៃព្រះសាស្តា ។

(សម្ពន្ធ) **បន**-សព្ទ វចនាលង្ការៈ, **អហំ** សយកត្តាក្នុង **សក្ខិស្សាមិ**ៗ អាខ្យាត-កត្តុ., **ខន្ធាទីសុ** និទ្ធារណសត្តមីក្នុង **មុខេន**ៗ តតិយានិទ្ធារណីយៈរបស់ **ខន្ធាទីសុ** និងជាករណត្ថតតិយាក្នុង **កថេន្តោ**, **កតរេន** វិសេសនៈរបស់ **មុខេន**, **នុ ខោ** បទបូរណៈក្នុង **កតរេន**, **ឥមំ** វិសេសនៈរបស់ **បដិបទំ**ៗ អវុត្តកម្មក្នុង **កថេន្តោ**ៗ វិសេសនៈរបស់ **អហំ**, **សត្ថុ** សាមិសម្ពន្ធក្នុង **អជ្ឈាសយំ**ៗ អវុត្តកម្មក្នុង **គណ្ហិតុំ**ៗ តុមត្ថសម្បទានក្នុង **សក្ខិស្សាមិ** ៕

២) បើរៀងទុកខាងចុងនាមនាម ដែលជាម្ចាស់របស់ ហៅថា អព្ភន្តរកិរិយា ឧ. **បុត្តោ មាតាបិតរេសុ សម្មា បដិបជ្ជន្តោ** ៕ (ប្រែ) **បុត្តោ** រីកូន **បដិបជ្ជន្តោ** កាលប្រតិបត្តិ **សម្មា** ដោយប្រពៃ **មាតាបិតរេសុ** ក្នុងមាតានិងបិតាទាំងឡាយ ។

(សម្ពន្ធ) **បុត្តោ** លិង្គត្ថៈ, **មាតាបិតរេសុ** អាធារៈក្នុង **បដិបជ្ជន្តោ**, **សម្មា** តតិយាវិសេសនៈរបស់ **បដិបជ្ជន្តោ**ៗ អព្ភន្តរកិរិយារបស់ **បុត្តោ** ៕

## **ត-បច្ច័យ**

៣) បើប្រកបដោយបឋមាវិភត្តិ ចូលនិងកិរិយាថា "កើត" ថា "មាន" ថា "ជា" ហៅថា វិកតិកត្តា ឧ. **(អហំ) អជ្ជតគ្គេ បាណុបេតំ សរណំ ពុទ្ធំ គតោស្មិ** ៕ (ប្រែ) **អហំ** រីខ្ញុំ **គតោ** ជាបុគ្គលដល់

ហើយ **ឲ្យន្តិ** នូវព្រះពុទ្ធ **សរណំ** ជាទីពឹង **បាណុបេតំ** ស្មើដោយជីវិត **អជ្ជតគ្គេ** ក្នុងកាលមានថ្ងៃនេះជាដើម **អស្មិ** មាន ។

(សម្ពន្ធ) **អហំ** បកតិកត្តាក្នុង **អស្មិ**ៗ អាខ្យាត_កត្តុ., **អជ្ជតគ្គេ** កាលត្ថសត្តមីក្នុង **គតោ**, **បាណុបេតំ** វិសេសនៈរបស់ **សរណំ**ៗ វិកតិអវុត្តកម្មក្នុង **គតោ**, **ឲ្យន្តិ** បកតិអវុត្តកម្មក្នុង **គតោ**ៗ វិកតិកត្តា ក្នុង **អស្មិ** ១

៤) បើប្រកបដោយបឋមាវិភត្តិ ចូលនឹងកិរិយាដទៃ ក្រៅពីកិរិយា ថា "កើត" ថា "មាន" ថា "ជា" ហៅថា អព្ភន្តរកិរិយា ឧ. **វិសាខា សសុរំ វីជមានា ឋិតា តំ (បិណ្ឌចារិកត្ថេរំ) ទិស្វា សសុរស្ស អាចិក្ខិតុំ អយុត្តន្តិ យថា សោ ថេរំ បស្សតិ, ឯវំ អបគន្ត្វា អដ្ឋាសិ** ។(ប្រែ) **វិសាខា** វីនាងវិសាខា **សសុរំ វីជមានា ឋិតា** កំពុងឈរបក់នូវ ឪពុកក្មេក **ទិស្វា** ឃើញហើយ (**បិណ្ឌចារិ-កត្ថេរំ** នូវព្រះថេរៈអ្នកមាន កិរិយាត្រាច់ទៅដើម្បីបិណ្ឌបាតជាវត្ត) **តំ** នោះ **ចិន្តេត្វា** គិតហើយ **សសុរស្ស អាចិក្ខិតុំ អយុត្តំ ឥតិ** ថាវីកិរិយាប្រាប់ដល់ ឪពុកក្មេក មិនគួរឡើយដូច្នេះ **អបគន្ត្វា អដ្ឋាសិ** បានគេចទៅ ឈរនៅហើយ **សោសេដ្ឋី** វីសេដ្ឋីនោះ **បស្សតិ** ឃើញ **ថេរំ** នូវព្រះថេរៈ **យថា** យ៉ាងណា **ឯវំ** យ៉ាងនោះ ។

(សម្ពន្ធ) **វិសាខា** សយកត្តាក្នុង **អដ្ឋាសិ។** អាខ្យាត_កត្តុ., **សសុរំ** អវុត្តកម្មក្នុង **វិជមានា។** អព្ភន្តរកិរិយាក្នុង **ឋិតា។** អព្ភន្តរកិរិយារបស់ **វិសាខា,** **តំ** វិសេសនៈរបស់ **បិណ្ឌចារិកត្ថេរំ។** អវុត្តកម្មក្នុង **ទិស្វា។** បុព្វកាលកិរិយាក្នុង **ចិន្តេត្វា,** **សសុរស្ស** សម្បទានក្នុង **អាចិក្ខិតុំ។** តុមត្ថកត្តាក្នុង **អយុត្តំ។** កិតបទ_កត្តុវាចកៈ, **ឥតិ**_សព្ទ អាការៈក្នុង **ចិន្តេត្វា។** បុព្វកាលកិរិយាក្នុង **អដ្ឋាសិ,** **សោ** វិសេសនៈរបស់ **សេដ្ឋី។** សយកត្តាក្នុង **បស្សតិ។** អាខ្យាត_កត្តុ., **យថា** កិរិយាវិសេសនៈក្នុង **បស្សតិ,** **ថេរំ** អវុត្តកម្មក្នុង **បស្សតិ,** **ឯវំ** កិរិយាវិសេសនៈក្នុង **អបគន្ត្វា** **អដ្ឋាសិ,** **អបគន្ត្វា** សមានកាលកិរិយាក្នុង **អដ្ឋាសិ** ។

៥) បើប្រកបដោយទុតិយាវិភត្តិ ហើយចូលនឹងកិរិយា អាខ្យាតណាមួយ ហៅថា វិសេសនៈខ្លះ ហៅថា វិកតិអវុត្តកម្ម ខ្លះ : **ត**_បច្ច័យ ជាវិសេសនៈ ឧ. **ឧប្បន្នំ** **លាភំ** **អន្តរាយំ** **ជនេតិ** ៥ (ប្រែ) (**បុគ្គលោ** វីបុគ្គល) **អន្តរាយំ** **ជនេតិ** រមែងព្រេកអរ **លាភំ** នូវលាភ **ឧប្បន្នំ** ដែលកើតឡើង ហើយ ។ **ត**_បច្ច័យ ជាវិកតិអវុត្តកម្ម ។

ឧ. **ធម្មំ** **សុចរិតំ** **ចរេ** ៥ (ប្រែ) (**បុគ្គលោ** វីបុគ្គល) **ចរេ** គប្បីប្រព្រឹត្ត **ធម្មំ** នូវធម៌ **សុចរិតំ** ឱ្យជាធម៌គឺខ្លួនប្រព្រឹត្តល្អហើយ

(ឱ្យជាសុចរិត) ។

(សម្ពន្ធ) **បុគ្គលោ** សយកត្តាក្នុង **ចរេ**។ អាខ្យាត-កត្តុ., **ធម្មំ** បកតិអវុត្តកម្មក្នុង **ចរេ**, **សុចរិតំ** វិកតិអវុត្តកម្មក្នុង **ចរេ** ៕

៦) បើជាកិរិយារបស់ឥត្ថម្ភូត ហៅថា ឥត្ថម្ភូតកិរិយា ឧ. **សា ទាសី ភិន្នេន សីសេន លោហិតេន បគ្ឃរន្តេន បដិវិស្សកានំ ឧជ្ឈាបេសិ** ៕ (ប្រែ) **ទាសី** រីខ្ញុំស្រី **សា** នោះ **សីសេន** មានក្បាល <u>**ភិន្នេន**</u> <u>បែកហើយ</u> **លោហិតេន** មានឈាម <u>**បគ្ឃរន្តេន**</u> <u>កាលហូរចេញ</u> **បដិវិស្សកានំ** ញ៉ាំងជនអ្នកស្និទ្ធស្នាលទាំងឡាយ **ឧជ្ឈាបេសិ** ឱ្យ (រត់) ខ្វាត់ខ្វាយហើយ ។

(សម្ពន្ធ) **សា** វិសេសនៈរបស់ **ទាសី**។ ហេតុកត្តាក្នុង **ឧជ្ឈាបេសិ**។ អាខ្យាត-ហេតុកត្តុ., **សីសេន** ឥត្ថម្ភូតតតិយាក្នុង **ភិន្នេន**។ ឥត្ថម្ភូតកិរិយា, **លោហិតេន** ឥត្ថម្ភូតតតិយាក្នុង **បគ្ឃរន្តេន**។ ឥត្ថម្ភូតកិរិយា, **បដិវិស្សកានំ** ការិតកម្មក្នុង **ឧជ្ឈាបេសិ** ៕

៧) បើជាកិរិយារបស់អនាទរៈហៅថា អនាទរកិរិយា ឧ. <u>**សាមណេរស្ស**</u> **ធម្មំ** <u>**ទេសេន្តស្ស**</u>, **អន្ធការោ ជាតោ** ៕ (ប្រែ) <u>**សាមណេរស្ស**</u> <u>កាលដែលសាមណេរ</u> <u>**ទេសេន្តស្ស**</u> <u>កំពុងសំដែង</u> **ធម្មំ** នូវធម៌, **អន្ធការោ** រីងងឹត **ជាតោ** កើតឡើងហើយ ។

(សម្ពន្ធ) **សាមណេរស្ស** អនាទរៈក្នុង **នេសេន្តស្ស** អនាទរៈ-កិរិយា, **ធម្មំ** អវុត្តកម្មក្នុង **ទេសេន្តស្ស**, **អន្ធភាវោ** សយកត្តាក្នុង **ជាតោ** កិតបទ-កត្តុវាចកៈ។

៨) បើជាកិរិយារបស់លក្ខណៈ ហៅថា លក្ខណកិរិយា ឧ. **មនោ បន,ឯកច្ចេសុ ចេតសិកេសុ** <u>**អនុប្បន្នេសុបិ**</u>, **ឧប្បជ្ជតិយេវ ៕**

(ប្រែ) **បន** ក៏ **មនោ** វិចិត្ត, **ចេតសិកេសុ** នាកាលចេតសិកទាំងឡាយ **ឯកច្ចេសុ** ពួកខ្លះ <u>**អនុប្បន្នេសុបិ**</u> <u>ទុកជាកាលមិនទាន់កើតឡើង</u>, **ឧប្បជ្ជតិ ឯវ** គង់កើតឡើងបានដែរ ។

(សម្ពន្ធ) **បន**-សព្ទ វាក្យារម្ភៈ, **មនោ** សយកត្តាក្នុង **ឧប្បជ្ជតិ** អាខ្យាត-កត្តុ., **ឯកច្ចេសុ** វិសេសនៈរបស់ **ចេតសិកេសុ** លក្ខណៈក្នុង **អនុប្បន្នេសុ** លក្ខណកិរិយា, **អបិ**-សព្ទ សម្ភាវនត្ថៈក្នុង **អនុប្បន្នេសុ**, **ឯវ**-សព្ទ អវធារណៈក្នុង **ឧប្បជ្ជតិ ៕**

កិរិយាកិតកៈ គ្រប់គ្រងប្រយោគ បទដែលជាកិរិយាគ្រប់គ្រងប្រយោគ គឺក្នុងនោះមិនចាំបាច់មាន កិរិយាអាខ្យាតនៅនោះផងក៏អាចកើតជាប្រយោគបាន យ៉ាងនេះហៅថា កិរិយាកិតកៈ គ្រប់គ្រងប្រយោគ, ប្រើបានបច្ច័យ ៣ តួគឺ **ត**, **តព្វ**, **អនីយ**-បច្ច័យ, មានឈ្មោះ ហៅតាមវាចកៈទាំង ៥ ដូច្នេះ :

១) បើជាកត្តុវាចកៈ ហៅថា កិតបទ_កត្តុវាចកៈ, ឧ. **ភិក្ខុ គាមំ បិណ្ឌាយ បវិដ្ឋោ ។** (ប្រែ) **ភិក្ខុ** រីភិក្ខុ **បវិដ្ឋោ** ចូលទៅហើយ **គាមំ** កាន់ស្រុក **បិណ្ឌាយ** ដើម្បីបិណ្ឌបាត ។

(សម្ពន្ធ) **ភិក្ខុ** សយកត្តាក្នុង **បវិដ្ឋោ**ៗ កិតបទ_កត្តុ., **គាមំ** សម្បាបុណិយកម្មក្នុង **បវិដ្ឋោ**, **បិណ្ឌាយ** សម្បទានក្នុង **បវិដ្ឋោ** ។

២) បើជាកម្មវាចកៈ ហៅថា កិតបទ_កម្មវាចកៈ ឧ. **សត្ថារា ទេសិតោ អយំ ធម្មោ ។** (ប្រែ) **ធម្មោ** រីធម៌ **អយំ** នេះ **សត្ថារា** គឺព្រះជាគ្រូ **ទេសិតោ** សំដែងហើយ ។

(សម្ពន្ធ) **អយំ** វិសេសនៈរបស់ **ធម្មោ**ៗ វុត្តកម្មក្នុង **ទេសិតោ**ៗ កិតបទ_កម្មវាចកៈ **សត្ថារា** អនភិហិតកត្តាក្នុង **ទេសិតោ ។**

៣) បើជាភាវវាចកៈ ហៅថា កិតបទ_ភាវវាចកៈ ឧ. **ភរិយំ មេ និស្សាយ ភយេន ឧប្បន្នេន ភវិតព្វំ ។** (ប្រែ) **ភយេន** គឺភ័យ **ឧប្បន្នេន** កើតឡើងហើយ **និស្សាយ** ព្រោះអាស្រ័យ **ភរិយំ** នូវប្រពន្ធ **មេ** នៃអញ **ភវិតព្វំ** គប្បីមាន ។

(សម្ពន្ធ) **ភរិយំ** អវុត្តកម្មក្នុង **និស្សាយ**, **មេ** សាមិសម្ពន្ធក្នុង **ភរិយំ**, **និស្សាយ** ហេតុកាលកិរិយាក្នុង **ឧប្បន្នេន**, **ភយេន** អនភិហិតកត្តាក្នុង **ភវិតព្វំ**ៗ កិតបទ_ភាវវាចកៈ, **ឧប្បន្នេន** អព្ភន្តរ_

កិរិយារបស់ **តយេន ៗ**

៤) បើជាហេតុកត្តុវាចកៈ ហៅថា កិតបទ-ហេតុកត្តុវាចកៈ ឧ. **អាចរិយោ អន្តេវាសិកេ វិនយំ សិក្ខាបេន្តោ ៗ** (ប្រែ) **អាចរិយោ** វីអាចារ្យ **អន្តេវាសិកេ** ញុាំងសិស្សទាំងឡាយ **សិក្ខាបេន្តោ** កាលឱ្យរៀន **វិនយំ** នូវវិន័យ ។

(សម្ពន្ធ) **អាចរិយោ** ហេតុកត្តាក្នុង **សិក្ខាបេន្តោៗ** កិតបទ-ហេតុកត្តុវាចកៈ, **អន្តេវាសិកេ** ការិតកម្មក្នុង **សិក្ខាបេន្តោ, វិនយំ** អវុត្តកម្មក្នុង **សិក្ខាបេន្តោ ៗ**

៥) បើជាហេតុកម្មវាចកៈ ហៅថា កិតបទ-ហេតុកម្មវាចកៈ ឧ. **វិនយោ អាចរិយេន អន្តេវាសិកេ សិក្ខាបេតព្វោ** ។ (ប្រែ) **វិនយោ** វីវិន័យ **អាចរិយេន** គឺអាចារ្យ **អន្តេវាសិកេ** ញុាំងអន្តេវាសិកទាំងឡាយ **សិក្ខាបេតព្វោ** គប្បីឱ្យរៀន ។

(សម្ពន្ធ) **វិនយោ** វុត្តកម្មក្នុង **សិក្ខាបេតព្វោៗ** កិតបទ-ហេតុកម្មវាចកៈ **អាចរិយេន** អនភិហិតកត្តាក្នុង **សិក្ខាបេតព្វោ, អន្តេវាសិកេ** ការិតកម្មក្នុង **សិក្ខាបេតព្វោ ៗ**

## អព្យយកិរិយា

បទកិរិយាដែលប្រកបដោយ **ត្វា, ត្វាន, តូន**-បច្ច័យ មានឈ្មោះ

សម្ពន្ធ ៧ យ៉ាងគឺ :

១) បុព្វកាលៈ អតីតកាលដែលគ្រាន់តែ ប្រាប់ថាកន្លងហើយ ហៅថា "បុព្វកាល" ឱ្យប្រែថា "ហើយ" ឬថា "រួចហើយ" ក៏បានខ្លះ ត្រូវប្រែមុន កិរិយារបស់ប្រធាន ឧ. **សោ ភត្តំ** **គណ្ហិត្វា** **ភុញ្ជិ** ។ (ប្រែ) **សោ** វីគាត់ **គណ្ហិត្វា** ទទួលហើយ **ភត្តំ** នូវភត្ត **ភុញ្ជិ** បរិភោគហើយ ។

(សម្ពន្ធ) **សោ** សយកត្តាក្នុង **ភុញ្ជិ**ៗ អាខ្យាត-កត្តុ., **ភត្តំ** អវុត្តកម្មក្នុង **គណ្ហិត្វា**ៗ បុព្វកាលកិរិយាក្នុង **ភុញ្ជិ** ។

២) បរិយោសានកាលៈ អតីតកាលដែលកន្លងស្រេចហើយ ហៅថា "បរិយោសានកាល" ឱ្យប្រែថា "លុះហើយ" ឬថា " លុះ, រួច, ហើយ ក៏បានខ្លះ, ត្រូវប្រែក្រោយបន្ទាប់អាខ្យាតកិរិយាដែល មាន រូប សព្ទធាតុ ត្រូវគ្នានឹងខ្លួនដែរ ឧ. **អយំ កុលបុត្តោ មំ ទិស្វា មម សង្គហំ ករិស្សតិ, ကត្វា ច បន មហាសម្បត្តឹ លភិស្សតិ** ។

(ប្រែ) **កុលបុត្តោ** វីកុលបុត្រ **អយំ** នេះ **ទិស្វា** ឃើញហើយ **មំ** នូវអញ **ករិស្សតិ** នឹងធ្វើ **សង្គហំ** នូវសេចក្តីសង្គ្រោះ **មម** ដល់អញ, **កត្វា ច បន** ក៏លុះធ្វើរួចហើយ **លភិស្សតិ** នឹងបាន **មហាសម្បត្តឹ** នូវសម្បត្តិច្រើន ។

(សម្ពន្ធ) **អយំ** វិសេសនៈរបស់ **ភុលបុត្តោ**ៗ សយកត្តាក្នុង **ភរិស្សតិ**, **លភិស្សតិ**ៗ អាខ្យាត-កត្តុ., **មំ** អវុត្តកម្មក្នុង **ធិស្វា**ៗ បុព្វកាលកិរិយាក្នុង **ភរិស្សតិ**, **មម** សម្បទានក្នុង **ភរិស្សតិ**, **សង្គហំ** អវុត្តកម្មក្នុង **ភរិស្សតិ**, **ភត្វា** បរិយោសានកាលកិរិយាក្នុង **លភិស្សតិ**, **ច បន** ទាំង ២ សព្ទវាក្យារម្ភៈក្នុង **ភត្វា**, **មហាសម្បត្តឹ** អវុត្តកម្មក្នុង **លភិស្សតិ ។**

៣) សមានកាលៈ កាលដែលប្រាប់សេចក្ដីមានលំនាំជាបច្ចុប្បន្នថា "កំពុងតែ" ឬ "ដែលកំពុង" ហៅថា "សមានកាល" ត្រូវប្រែមុនកិរិយា របស់ប្រធាន, តែមិនចេញពាក្យថា "ហើយ" ទេ, គ្រាន់តែប្រែចេញសព្ទ ប៉ុណ្ណោះ ឧ. **សេដ្ឋី ឧបាហនំ** <u>**អារុយ្ហ**</u> **ឆត្តំ** <u>**ធារេត្វា**</u> **មគ្គេន គច្ឆតិ ។** (ប្រែ) **សេដ្ឋី** វិសេដ្ឋី <u>**អារុយ្ហ**</u> <u>ពាក់</u> **ឧបាហនំ** នូវស្បែកជើង <u>**ធារេត្វា**</u> <u>បាំង</u> **ឆត្តំ** នូវឆ័ត្រ **គច្ឆតិ** ទៅ **មគ្គេន** តាមផ្លូវ ។

(សម្ពន្ធ) **សេដ្ឋី** សយកត្តាក្នុង **គច្ឆតិ**ៗ អាខ្យាត-កត្តុ., **ឧបាហនំ** អវុត្តកម្មក្នុង **អារុយ្ហ**ៗ សមានកាលកិរិយាក្នុង **គច្ឆតិ**, **ឆត្តំ** អវុត្តកម្មក្នុង **ធារេត្វា**ៗ សមានកាលកិរិយាក្នុង **គច្ឆតិ**, **មគ្គេន** តតិយាវិសេសនៈក្នុង **គច្ឆតិ ។**

៤) អបរកាលៈ កាលដែលប្រាប់ដំណើររបស់កិរិយាសព្ទដែលតួ

ប្រធានត្រូវសម្រេច, តបន្ទាប់អំពីកិរិយារបស់ប្រធានទៅ ហៅថា "អបរកាល" ត្រូវប្រែក្រោយកិរិយារបស់ប្រធាន ប្រែថា "ហើយ" ក៏បាន មិនថា "ហើយ" ក៏បានតាមគួរដល់ដំណើរសេចក្តី ឧ. **ធម្មកថិកោ ធម្មាសនេ និសីទិ តត្ថេវ ឋបិតំ ចិត្តពីជនឹ គហេត្វា ។** (ប្រែ) **ធម្មកថិកោ** វិធម្មកថិក **និសីទិ** អង្គុយហើយ **ធម្មាសនេ** លើធម្មាសនៈ **គហេត្វា** ចាប់ **ចិត្តពីជនឹ** នូវផ្លិតដ៏វិចិត្រ **ឋបិតំ** ដែលគេដាក់ហើយ **តត្ថ ឯវ ធម្មាសនេ** លើធម្មាសនៈនោះស្រាប់ ។

(សម្ពន្ធ) **ធម្មកថិកោ** សយកត្តាក្នុង **និសីទិ**។ អាខ្យាត_កត្តុ., **ធម្មាសនេ** ឧបសិលេសិកាធារៈក្នុង **និសីទិ**, **តត្ថ** វិសេសនៈរបស់ **ធម្មាសនេ**។ ឧបសិលេសិកាធារៈក្នុង **ឋបិតំ**, **ឯវ**_សព្ទ អវធារណៈក្នុង **តត្ថ**, **ឋបិតំ** វិសេសនៈរបស់ **ចិត្តពីជនឹ**។ អវុត្តកម្មក្នុង **គហេត្វា**។ អបរកាលកិរិយាក្នុង **និសីទិ ។**

៥) ហេតុកាល កាលដែលប្រាប់ដំណើរសេចក្តីថា "ព្រោះ" ឬ "ព្រោះតែ" ហៅថា "ហេតុកាល" ត្រូវប្រែក្រោយកិរិយារបស់ប្រធាន, ប្រែថា "ហេតុ" ឬ "ព្រោះ" ក៏បានខ្លះ ឧ. **ឥទំ មេ ទុក្ខំ តុម្ហេ និស្សាយ ជាតំ ។** (ប្រែ) **ទុក្ខំ** វិសេចក្តីទុក្ខព្រួយ **ឥទំ** នេះ **ជាតំ** កើតហើយ **មេ** ដល់ខ្ញុំ **និស្សាយ** ព្រោះអាស្រ័យ **តុម្ហេ** នូវអ្នក

ទាំងឡាយ ។

(សម្ពន្ធ) **ឥធំ** វិសេសនៈរបស់ **ឧក្ខំ**ៗ សយកត្តាក្នុង **ជាតំ**ៗ កិតបទ_កត្តុវាចកៈ, **មេ** សម្បទានក្នុង **ជាតំ**, **តុម្ហេ** អវុត្តកម្មក្នុង **និស្សាយ**ៗ ហេតុកាលកិរិយាក្នុង **ជាតំ** ៕

៦) នាមវិសេសនៈ កាលដែលប្រើជាវិសេសនៈ របស់នាមសព្ទ ហៅថា "នាមវិសេសនៈ" ត្រូវប្រែមុនកិរិយារបស់ប្រធាន មិនប្រែថា "ហើយ" ទេ ឧ. **ឋបេត្វា** **ទ្វេ** **អគ្គសាវកេ** **អវសេសា** **អរហត្តំ** **បាបុណឹសុ** ៕ (ប្រែ) **អវសេសា** វីភិក្ខុដ៏សេសទាំងឡាយ **ឋបេត្វា** លើកទុក **អគ្គសាវកេ** នូវអគ្គសាវ័កទាំងឡាយ **ទ្វេ** ពីរ **បាបុណឹសុ** ដល់ហើយ **អរហត្តំ** នូវព្រះអរហត្ត ។

(សម្ពន្ធ) **អវសេសា** សយកត្តាក្នុង **បាបុណឹសុ**ៗ អាខ្យាត_កត្តុ., **ឋបេត្វា** នាមវិសេសនៈរបស់ **អវសេសា**, **ទ្វេ** វិសេសនៈរបស់ **អគ្គសាវកេ**ៗ អវុត្តកម្មក្នុង **ឋបេត្វា**, **អរហត្តំ** អវុត្តកម្មក្នុង **បាបុណឹសុ** ៕

៧) កិរិយាវិសេសនៈ កាលដែលប្រើជាវិសេសនៈ របស់កិរិយា_សព្ទគឺនាំកិរិយាសព្ទឱ្យមានសេចក្ដីប្លែកជាងប្រក្រតី ដូចកិរិយារបស់ប្រធាន, មិនប្រែថា "ហើយ" ទេ ឧ. **តីណិ** **រតនានិ** **ឋបេត្វា** **អញ្ញំ** **មេ** **បដិសរណំ** **នត្ថិ** ៕ (ប្រែ) **បដិសរណំ** វីទីពឹង **អញ្ញំ** ឯទៀត **មេ**

របស់ខ្ញុំ **នត្ថិ** មិនមានទេ <u>**ឋបេត្វា**</u> <u>វៀរលែង</u> **រតនានិ** នូវរតនៈទាំងឡាយ **តីណិ** បី ។

(សម្ពន្ធ) **បដិសរណំ** សយកត្តាក្នុង **នត្ថិ**ៗ និបាតាខ្យាត_កត្តុ., **តីណិ** វិសេសនៈរបស់ **រតនានិ**ៗ អវុត្តកម្មក្នុង **ឋបេត្វា**ៗ កិរិយាវិសេសនៈរបស់ **នត្ថិ**, **អញ្ញំ** វិសេសនៈរបស់ **បដិសរណំ**, **មេ** សាមិសម្ពន្ធក្នុង **សរណំ** ៗ

## តថា លិង្គត្ថៈ

ពាក្យថា "**តថា**" ជានិបាតប្រាប់ឧបមេយ្យ និងនិបាតប្រាប់ប្រការ, តែក្នុងទីនេះ និយាយចំពោះតែដែលយកមកប្រើជំនួស បឋមាវិភត្តិដែលប្រែថា " រីយ៉ាងនោះ " ត្រូវ សម្ពន្ធថា "លិង្គត្ថៈ" ឧ. **អជ្ជេវ ពុទ្ធំ សរណំ វជាហិ ធម្មញ្ច សង្ឃញ្ច បសន្នចិត្តោ** <u>**តថេវ**</u> **សិក្ខាបទានិ បញ្ច អខណ្ឌផុល្លានិ សមាទិយស្សុ** ៗ (ប្រែ) **ត្វំ** រីអ្នក **បសន្នចិត្តោ** មានចិត្តជ្រះថ្លាហើយ **វជាហិ** ចូរដល់ **ពុទ្ធំ ច** នូវព្រះពុទ្ធផង **ធម្មំ ច** នូវព្រះធម៌ផង **សង្ឃំ ច** នូវព្រះសង្ឃផង **សរណំ** ជាទីពឹង **អជ្ជេ ឯវ** ក្នុងថ្ងៃនេះទៅ, <u>**តថា**</u> <u>**ឯវ**</u> <u>រីយ៉ាងនោះឯង</u> **តថា ឯវ** គឺថា **ត្វំ** រីអ្នក **បសន្នចិត្តោ** មានចិត្តជ្រះថ្លា **សមាទិយស្សុ** ចូរសមាទាន **សិក្ខាបទានិ** នូវសិក្ខាបទទាំងឡាយ **បញ្ច** ប្រាំ

**អខណ្ឌផុល្លានិ** មានកិរិយាដាច់ និង កិរិយាធ្លុះធ្លាយមិនមាន (កុំឱ្យដាច់ និងធ្លុះធ្លាយ) ។

(សម្ពន្ធ) **ត្វំ** សយកត្តាក្នុង **ចរាហិ**ៗ អាខ្យាត-កត្តុ., **អជ្ជ** កាលត្ថសត្តមីក្នុង **ចរាហិ**, **ឯវ**-សព្ទ អវធារណៈក្នុង **អជ្ជ**, **ពុទ្ធំ** ក្ដី **ធម្មំ** ក្ដី **សង្ឃំ** ក្ដី បកតិអវុត្តកម្មក្នុង **ចរាហិ**, **សរណំ** វិកតិអវុត្តកម្មក្នុង **ចរាហិ**, **ច** ទាំងពីរសព្ទបទសមុច្ចយក្នុង **ធម្មំ សង្ឃំ**, **បសន្នចិត្តោ** វិសេសនៈរបស់ **ត្វំ**, **តថា** លិង្គត្ថៈ, **ឯវ**-សព្ទ អវធារណៈក្នុង **តថា**, **ត្វំ** សយកត្តាក្នុង **សមាទិយស្សុ**ៗ អាខ្យាត-កត្តុ., **តថា ឯវ** បទវិវរណៈក្នុង **បសន្នចិត្តោ**ៗ បទវិវរណីយៈរបស់ **តថា ឯវ** និងជាវិសេសនៈរបស់ **ត្វំ**, **សិក្ខាបទានិ** អវុត្តកម្មក្នុង **សមាទិយស្សុ**, **បញ្ច** ក្ដី **អខណ្ឌ-ផុល្លានិ** ក្ដី វិសេសនៈរបស់ **សិក្ខាបទានិ** ៕

## អលំ លិង្គត្ថៈ

**អលំ**-សព្ទនេះ បើតាមធម្មតាជានិបាតបដិសេធ ប្រាប់សេចក្ដីឃាត់ហាមដាច់ខាត ប្រែថា "កុំ, កុំឡើយ, ណ្ហើយ, ល្មមហើយ" តែក្នុងវិធីនេះ លោកប្រើជាបឋមាវិភត្តិវិញ ប្រែថា " វីល្មមហើយ " ឬថា " វីកុំឡើយ " ត្រូវសម្ពន្ធថា "លិង្គត្ថៈ" ឧ. **បក្កមតាយស្មា ឥមម្ហា អាវាសា, អលន្តេ ឥធ វាសេន** ៕ (ប្រែ) **អាយស្មា**

វិលោកដ៏មានអាយុ **បក្កមតុ** ចូរចៀសចេញ **អាវាសា** អំពីអាវាស **ឥមម្ហា** នេះ, **អលំ** វិកុំឡើយ **វាសេន** ដោយកិរិយានៅ **ឥធ** (**អាវាសេ** ក្នុងអាវាស) នេះ **តេ** នៃលោក ។

(សម្ពន្ធ) **អាយស្មា** សយកត្តាក្នុង **បក្កមតុ**ៗ អាខ្យាត_កត្តុ., **ឥមម្ហា** វិសេសនៈរបស់ **អាវាសា**ៗ អបាទានក្នុង **បក្កមតុ**, **អលំ** លិង្គត្ថៈ, **តេ** សាមិសម្ពន្ធក្នុង **វាសេន**ៗ ករណត្ថតតិយាក្នុង **អលំ** ៥

## សាធុ លិង្គត្ថៈ

**សាធុ**_សព្ទ នេះជានាមនាមសុទ្ធក៏មាន អព្យយសព្ទក៏មាន, ដែលជានាមនាមសុទ្ធមានវិធីសម្ពន្ធបានតាមការប្រែដែលចេញ ពាក្យជា អាយតនិបាតក្នុងពួកវិភត្តិនោះៗ និងវាចកៈនោះៗ, ដែលជាអព្យយសព្ទក៏អាចសម្ពន្ធបានច្រើនយ៉ាង ដូចកិរិយាវិសេសនៈ ឬ ចុះក្នុងសេចក្តីអង្វរ ហៅថា អាយាចនត្ថវាចកៈជាដើម, តែក្នុងទីនេះនឹងលើកយកមកនិយាយតែក្នុងចំណែកដែល សម្ពន្ធថា លិង្គត្ថៈ ប៉ុណ្ណោះ ដូចឧទាហរណ៍ថា : **សត្ថា សាធូតិ វត្វា បុរតោ អគមាសិ ៥** (ប្រែ) ព្រះជាគ្រូត្រាស់ហើយថា **សាធុ** ដូច្នេះ ទ្រង់ស្តេចទៅហើយខាងមុខ "**សាធុ** វិ អំពើញុំាងប្រយោជន៍ឱ្យសំរេច", បើប្រែដូច្នេះ **សាធុ** ត្រូវសម្ពន្ធថា លិង្គត្ថៈ, បើប្រែថា "ព្រះជាគ្រូទ្រង់ត្រាស់ហើយថា ល្អហើយ

ដូច្នេះ បានទ្រង់ស្តេចទៅហើយខាងមុខ" ដូច្នេះ **សាធុ** ត្រូវសម្ពន្ធថា សរុបក្នុង **ឥតិ** ២

(សម្ពន្ធ) **សត្ថា** សយកត្តាក្នុង **អគមាសិ**។ អាខ្យាត-កត្តុ., **សាធុ** លិង្គត្ថៈ, **ឥតិ** អាការៈក្នុង **វត្វា**។ បុព្វកាលកិរិយាក្នុង **អគមាសិ**, **បុរតោ** គតិយាវិសេសនៈក្នុង **អគមាសិ** ២ មួយបែបទៀតថា **សត្ថា** សយកត្តាក្នុង **អគមាសិ**។ អាខ្យាត-កត្តុ., **សាធុ** សរុបក្នុង **ឥតិ**។ សព្ទអាការៈក្នុង **វត្វា**។ បុព្វកាលកិរិយាក្នុង **អគមាសិ**, **បុរតោ** គតិយាវិសេសនៈក្នុង **អគមាសិ** ២

## សច្ចវាចកៈ លិង្គត្ថៈ

នេះជាឈ្មោះសំរាប់ហៅ **ឯវំ**-សព្ទ ត្រង់ដែលប្រើជំនួសបឋមាវិភត្តិ គឺត្រង់ដែលប្រែថា " រីយ៉ាងនោះ, រីយ៉ាងហ្នឹង ឬ រីយ៉ាង-ហ្នឹងហើយ " ឧ. **ឯវំ កិរ អាវុសោ** ២ (ប្រែ) ម្នាលអាវុសោ បានឮថា រីយ៉ាងនោះឬ ?

(សម្ពន្ធ) **អាវុសោ** អគារវាលបនៈ, **កិរ**-សព្ទ អនុស្សវនត្ថៈ, **ឯវំ** សច្ចវាចកលិង្គត្ថៈ ។

## តុមត្ថកត្តា (តុំ-បច្ច័យ)

ឈ្មោះនេះសំដៅយកអ្នកធ្វើជាប្រធានក្នុងប្រយោគចុះក្នុង

អត្ថនៃ **តុំ-**បច្ច័យ លោកបញ្ញត្តឱ្យសម្ពន្ធ ចំពោះតែ (តុមត្ថកត្តា) តែម្យ៉ាង ឧ. **តុម្ហេហិ អជ្ជ ឧឡារំ ពុទ្ធសក្ការំ កាតុំ វដ្ដតិ ។** (ប្រែ) វីកិរិយាគឺអ្នកទាំងឡាយ ធ្វើនូវសក្ការៈដ៏សមគួរដល់ព្រះពុទ្ធ ឱ្យលើសលុប់ក្នុងថ្ងៃនេះ ទើបគួរ ។

(សម្ពន្ធ) **កាតុំ** តុមត្ថកត្តាក្នុង **វដ្ដតិ**ៗ អាខ្យាត-កត្តុ., **តុម្ហេហិ** អនភិហិតកត្តាក្នុង **កាតុំ**, **អជ្ជ** កាលត្ថសត្តមីក្នុង **កាតុំ**, **ឧឡារំ** វិសេសនៈរបស់ **ពុទ្ធសក្ការំ**ៗ អវុត្តកម្មក្នុង **កាតុំ ។**

## តុមត្ថសម្បទាន (តុំ-បច្ច័យ)

ឈ្មោះនេះសំរាប់ហៅបទនាមកិតកៈដែលលោក ប្រើជំនួសចតុត្ថីវិភត្តិ ប្រែចេញពាក្យជាអាយតនិបាត "ដើម្បី" (គឺថា **តុំ-**បច្ច័យនោះកាលបើប្រកបផ្សំនឹងធាតុសម្រេចជាបទនាមកិតកៈហើយ នឹងចែកតាម វិភត្តិនាមទាំង ៧ ផ្លាស់រូបទៅផ្សេងៗ មិនបាន, គ្រាន់តែប្រើជំនួសបឋមាវិភត្តិប្រែថា " វី " និងចតុត្ថីវិភត្តិប្រែថា "ដើម្បី" ប៉ុណ្ណោះ, ដែលប្រើជំនួសបឋមាវិភត្តិ នោះបាននិយាយ ពីខាងដើមរួចមកហើយ, ដែលប្រើជំនួសចតុត្ថីវិភត្តិនេះ ហៅថា តុមត្ថសម្បទាន ប្រែថា "សម្បទាន ចុះក្នុងអត្ថនៃ **តុំ-**បច្ច័យ" ព្រោះថាសព្ទនេះសម្រេចមកពី **តុំ-**បច្ច័យ, តែដល់វេលាប្រែត្រឡប់ ជាចេញអាយតនិបាតរបស់

ចតុត្ថីវិភត្តិថា "ដើម្បី" ទៅវិញបានជាហៅថា តុមត្ថសម្បទាន, ត្រូវសម្ពន្ធចូលនឹងកិរិយាសព្ទ ឬនាមសព្ទដែលមានសេចក្តីទាក់ទងរកគ្នា ភ្ជាប់ពាក្យថា "ក្នុង" ដូច្នេះ ។ ម្យ៉ាងទៀត ត្រូវដឹងថាបើកាលណាប្រែថា " វី " ត្រូវថែមពាក្យថា កិរិយា ឬ សេចក្តី ឬ ដំណើរ ឬ អំពើមកទៀត តាមសមគួរដល់ការប្រកប, បើប្រែថា "ដើម្បី" មិនបាច់ថែមឡើយ គ្រាន់តែថា "ដើម្បី" ហើយធាតុយ៉ាងម៉េចៗ ក៏ថាយ៉ាងនោះៗ ទៅ ហើយគ្មានពហុវចនៈទេ មានតែឯកវចនៈម្យ៉ាង, ទាំងជំនួសបឋមាវិភត្តិនិង ចតុត្ថីវិភត្តិបានឥតមានទាស់) ឧ. **តយា សទ្ធឹយេវ គន្តុំ ឥច្ឆាមិ** ។(ប្រែ) ខ្ញុំចង់ដើម្បីទៅជាមួយនឹងអ្នកដែរ ។

(សម្ពន្ធ) **អហំ** សយកត្តាក្នុង **ឥច្ឆាមិ**ៗ អាខ្យាត_កត្តុ., **តយា** សហត្ថតតិយាក្នុង **សទ្ធឹ**ៗ កិរិយាសមវាយក្នុង **ឥច្ឆាមិ**, **ឯវ**_សព្ទអវធារណៈក្នុង **សទ្ធឹ**, **គន្តុំ** តុមត្ថសម្បទានក្នុង **ឥច្ឆាមិ** ៕

## ភិន្នាធារៈ

ពាក្យថា " ភិន្នាធារៈ " នេះ ជាឈ្មោះសំរាប់ហៅ បទក្នុងពួកសត្តមីវិភត្តិដែលប្រែចេញពាក្យអាយតនិបាតថា "ក្នុង" ឧ. **ឯវំ ឥមស្មឹ ការណេ សា វិសាខា និទ្ទោសា អហោសិ** ៕ (ប្រែ) នាងវិសាខានោះ ជាស្រ្តីឥតមានទោស ក្នុងហេតុ នេះបានមានហើយដោយ

ប្រការយ៉ាងនេះ ។

(សម្ពន្ធ) **សា** វិសេសនៈរបស់ **វិសាខា** ។ បកតិកត្តាក្នុង **អហោសិ** ។ អាខ្យាត-កត្តុ., **ឯវំ**-សព្ទ បការត្ថៈ, **ឥមស្មឹ** វិសេសនៈរបស់ **ការណេ** ។ ភិន្នាធារៈក្នុង **និទ្ទោសា** ។ វិកតិកត្តាក្នុង **អហោសិ** ៕

ពាក្យថា "អាធារៈ" នេះ ក៏មានលក្ខណៈប្រហែលគ្នានឹង ភិន្នាធារៈដែរ តែភិន្នាធារៈ សម្ពន្ធចូលនឹងនាម, ចំណែក អាធារៈ នេះ សម្ពន្ធ ចូលនឹងកិរិយា ៩. **តាតា មយ្ហំ បិតា ន ឯតំ សន្ធាយ កថេសិ, ឥទំ បន សន្ធាយ កថេសិ អម្ម តវ សស្សុសសុរ-ស្សាមិកានំ អគុណំ ទិស្វា ពហិ តស្មឹ តស្មឹ គេហេ ឋត្វា មា កថេសីតិ ឯវរូបេន ហិ អគ្គិនា សទិសោ អគ្គិ នាម នត្ថិ** ៕

(ប្រែ) ម្នាលអ្នកទាំងឡាយ បិតា របស់ខ្ញុំ មិនពោលហើយ សំដៅនូវ អធិប្បាយនុ៎ះទេ មានសេចក្ដីពិសេសថា បិតារបស់ខ្ញុំ ពោលហើយ សំដៅនូវហេតុនេះថា "ម្នាលនាង នាងឃើញហើយនូវទោស មិនមែន ជាគុណរបស់ឪពុកក្មេក និងម្ដាយក្មេក និងប្ដីទាំងឡាយរបស់នាង កុំឈរពោលហើយក្នុងផ្ទះនោះ ៗ ឰដ៏ខាងក្រៅ" ដូច្នេះ មែនពិត ឈ្មោះថាភ្លើង ប្រាកដស្មើដោយភ្លើង មានសភាពយ៉ាងនេះ មិនមាន ឡើយ ។

(សម្ពន្ធ) **តាតា** អគារវាលបនៈ, **មយ្ហំ** សាមិសម្ពន្ធក្នុង **បិតា**ៗ សយកត្តាក្នុង **ភវេសិ**ៗ អាខ្យាត-កត្តុ., **ន**-សព្ទ បដិសេធក្នុង **សន្ធាយ ភវេសិ**, **ឯតំ** វិសេសនៈរបស់ **អត្ថំ**ៗ អវុត្តកម្មក្នុង **សន្ធាយ**ៗ សមាន-កាលកិរិយាក្នុង **ភវេសិ**, **បន**-សព្ទ វិសេសនត្ថៈ (**មម បិតា**) សយកត្តាក្នុង **ភវេសិ**ៗ អាខ្យាត-កត្តុ., **ឥទំ** វិសេសនៈរបស់ **ការណំ**ៗ អវុត្តកម្មក្នុង **សន្ធាយ**ៗ សមានកាលកិរិយាក្នុង **ភវេសិ**ៗ អាខ្យាត-កត្តុ., **អម្ម** អគារវាលបនៈ, **ត្វំ** សយកត្តាក្នុង **ភវេសិ**ៗ អាខ្យាត-កត្តុ., **តវ** សាមិសម្ពន្ធក្នុង **សស្សុសសុរស្សាមិកានំ**ៗ សាមិសម្ពន្ធក្នុង **អគុណំ**ៗ អវុត្តកម្មក្នុង **ឱស្វា**ៗ បុព្វកាលកិរិយាក្នុង **ភវេសិ**, **ពហិ** អាធារៈក្នុង **ភវេសិ**, **តស្មិំ** ទាំងពីរបទ វិសេសនៈរបស់ **គេហេ**ៗ អាធារៈក្នុង **ភវេសិ**, **ឋត្វា** សមានកាលកិរិយាក្នុង **ភវេសិ**, **មា**-សព្ទ បដិសេធក្នុង **ឋត្វា ភវេសិ** , **ឥតិ**-សព្ទ អាការៈក្នុង **ភវេសិ**, **ហិ**-សព្ទ *ទឡ្ហករណត្ថៈ* **អគ្គិ** សយកត្តាក្នុង **នត្ថិ**ៗ អាខ្យាត-កត្តុ., **ឯវរូបេន** វិសេសនៈរបស់ **អគ្គិនា**ៗ ករណត្ថៈតតិយាក្នុង **សទិសោ**ៗ វិសេសនៈ របស់ **អគ្គិ**, **នាម**-សព្ទ សញ្ញាជោតកៈក្នុង **អគ្គិ** ៕

## សត្តមីបច្ចត្តៈ

ពាក្យនេះជាឈ្មោះសំរាប់ហៅបទនាមនាមដែលប្រកបដោយ

សត្តមីវិភត្តិដូចគ្នា តែសត្តមីពួកនេះប្រើជំនួសបឋមាវិភត្តិ កាច់សត្តមីវិភត្តិ ប្រែចេញពាក្យជាអាយតនិបាតថា " វី " តាមពួកបឋមាវិភត្តិ, សត្តមី ក្នុងទីនេះហៅថា សត្តមីបច្ចត្ថៈ ប្រែថា "សត្តមី" ចុះក្នុងអត្ថនៃបទបឋមា" ព្រមទាំងមានអំណាចអាចធ្វើជាតួប្រធាន ក្នុងប្រយោគនោះបានផង, តែគុណនាមរបស់សត្តមីបច្ចត្ថៈ នោះច្រើនតែប្រកបដោយបឋមាវិភត្តិ វៀរលែងតែ សព្វនាមចេញ ។ ឧ. **ឥមស្មិំ ហោតិ សីលស្មឹ ២** (ប្រែ) វីសីលមែននេះ មានដល់ភិក្ខុនោះ ។

(សម្ពន្ធ) **សីលស្មឹ** សត្តមីបច្ចត្ថៈក្នុង **ហោតិ**ៗ អាខ្យាត_កត្តុ., **ឥទំ** វិសេសនៈរបស់ **សីលស្មឹ**, **ថិ**_សព្ទ អបេក្ខត្ថៈក្នុង **ឥទំ**, **អស្ស** វិសេសនៈរបស់ **ភិក្ខុនោ**ៗ សម្បទានក្នុង **ហោតិ ២**

## គុណនាមពិសេស

បទគុណនាម បើនិយាយចំពោះតែបទដែលមានប្រើប្រាស់ក្រែលនោះមានឈ្មោះសម្ពន្ធដូចបាននិយាយរួចមកហើយ, តែបើនិយាយតាមបែបសម្ពន្ធ សម្រាប់បទគុណនាម ឱ្យអស់ជើងអស់ដៃទៅក៏ឃើញថាមាន ៣ យ៉ាង គឺសញ្ញាវិសេសនៈ ១, វិសេសលាភី ១, សរុបនិទស្សនៈ ១, បណ្តាគុណនាមទាំង ៣ យ៉ាងនេះ, គុណនាមមួយៗ សុទ្ធតែចុះក្នុងអត្ថផ្សេងៗ គ្នា ដូចនិយាយ តទៅនេះ :

## ១) សញ្ញាវិសេសនៈ

ពាក្យនេះសំរាប់ហៅ បទគុណនាម ដូចគ្នាមាន លក្ខណៈប្រហែលគ្នានឹងបទវិសេសនៈ ធម្មតា ដូចបាននិយាយរួចមកហើយពីខាងដើមនោះដែរ ប្លែកគ្នាតែ វេលាប្រែមានពាក្យអែបសម្រួលថា "ឈ្មោះ, ឈ្មោះថា" ចូលមកផង ប៉ុណ្ណោះ ឧ. **អស្សមោ តិដ្ឋតិ វេស្សន្តរោ រាជា ឞ** (ប្រែ) "ព្រះបរមក្សត្រិយ៍ព្រះនាមវេស្សន្តរ ទ្រង់គង់ ក្នុងអាស្រម" ។

(សម្ពន្ធ) **វេស្សន្តរោ** សញ្ញាវិសេសនៈរបស់ **រាជា**។ សញ្ញាវិ-សេសយៈ និងជាសយកត្តាក្នុង **តិដ្ឋតិ**។ អាខ្យាត-កត្តុ., **អស្សមោ** វេសយិកាធារៈក្នុង **តិដ្ឋតិ**។

## ២) វិសេសលាភី

ឈ្មោះនេះមិនមែនមានលក្ខណៈ ដូចគុណនាមសុទ្ធនោះទេ គ្រាន់ជាបទរាយសេចក្តីរបស់នាមនាម ដែលជាម្ចាស់របស់ឱ្យច្បាស់លាស់ឡើងប៉ុណ្ណោះ វេលាប្រែត្រូវសម្រួលពាក្យថា " គឺ ", ទោះបីមានលិង្គប្លែកពីបទ នាមនាមដែលជាម្ចាស់របស់ខ្លះក៏បានមិនជាអ្វី, បទទីពីរ ដែលទទួលពាក្យថា "គឺ" នេះឯងហៅថា " វិសេសលាភី ", ត្រូវសម្ពន្ធចូលនឹងនាមនាមដែលជាម្ចាស់របស់ ឧ. **យស្ស ឯតា**

**ធនា អត្ថិ ឥត្ថិយា បុរិសស្ស វា ។** (ប្រែ) ទ្រព្យទាំងឡាយ នុ៎ះ មានដល់អ្នកណា គឺប្រុសឬ ឬថា គឺស្រី ។

(សម្ពន្ធ) **ឯតា** វិសេសនៈរបស់ **ធនា។** សយកត្តាក្នុង **អត្ថិ។** អាខ្យាត_កត្តុ., **យស្ស** សម្បទានក្នុង **អត្ថិ, ឥត្ថិយា** ក្តី **បុរិសស្ស** ក្តី វិសេសលាភីរបស់ **យស្ស, វា** ទាំងពីរសព្ទ បទវិកប្បត្ថៈក្នុង **ឥត្ថិយា បុរិសស្ស ។**

## ៣) សរូបនិទស្សនៈ

ឈ្មោះនេះសំរាប់ហៅបទនាមនាមច្រើនបទដែល នៅរួមគ្នា ដែលចែករំលែកមកពីបទនាមនាម ដែលជាម្ចាស់របស់ តែដើមកំណើត ក៏ជានាមនាមសុទ្ធ ដូចវិសេសលាភីដែរគ្រាន់តែមិនមែនជាឥស្សរៈ ចំពោះខ្លួន ត្រូវចូលនឹងបទនាមនាម ដទៃដែលជាម្ចាស់របស់ខ្លួន ប៉ុណ្ណោះ ហៅថា សរូបនិទស្សនៈ ។ ឧ. **កេសកល្យាណំ មំសក-ល្យាណំ** អដ្ឋិកល្យាណំ **ឆវិកល្យាណំ វយកល្យាណំ បញ្ច កល្យាណានិ ។** (ប្រែ) លក្ខណៈល្អទាំងឡាយ ៥ យ៉ាង គឺល្អសក់ គឺល្អសាច់ គឺល្អឆ្អឹង គឺល្អសម្បុរថ្ងៃ គឺល្អវ័យ ។

(សម្ពន្ធ) **កេសកល្យាណំ** ក្តី, **មំសកល្យាណំ** ក្តី, **អដ្ឋិក-**ល្យាណំ ក្តី, **ឆវិកល្យាណំ** ក្តី, **វយកល្យាណំ** ក្តី សរូបនិទស្សនៈ

របស់ **កល្យាណានិ** ៗ សរូបនិទស្សនីយៈ និងជាលិង្គត្ថៈ, **បញ្ច** វិសេសនៈ របស់ **កល្យាណានិ** ២

## **កិរិយាបធានន័យ**

នេះសំដៅយកកិរិយាដែលប្រកបដោយ **ត្វានិ**-បច្ច័យ ដែលធ្វើក្នុងប្រយោគដែលមានប្រធានពីរតួ តែវចនៈផ្សេងគ្នា, គឺក្នុងសង្កាត់ខាងដើម និយាយដល់មនុស្សច្រើននាក់ ឬវត្ថុច្រើននៅរួមគ្នា, ក្នុងសង្កាត់ខាងចុងលើក ឡើងនិយាយតែមនុស្សម្នាក់ ឬវត្ថុតែម្យ៉ាង មានលក្ខណៈប្រហែលគ្នា នឹងប្រយោគនិទ្ធារណៈ, តែក្នុងសង្កាត់ខាងចុងប្រើកិរិយាអាខ្យាតដែលជាធំក្នុងប្រយោគ, បទប្រធានខាងដើម ហៅថា បកតិកត្តា ឬ សយកត្តា ទទេៗ ទៅសម្ពន្ធចូលក្នុងកិរិយា **ត្វានិ**-បច្ច័យខាងចុងហើយហៅ កិរិយានោះថា "កិរិយាបធានន័យ" មិនបាច់ចូលនឹងកិរិយាតទៅឡើយ ឧ. **តេ ករិ ទ្វេ សហាយកា ធម្មស្សវ-នត្ថាយ គច្ឆន្តេន មហាជនេន សទ្ធិំ ជេតវនំ គន្ត្វា, ឯកោ ធម្មកថំ អស្សោសិ** ២ (ប្រែ) បានឮថា (ចោរទាំងឡាយ) នោះជាសំឡាញ់នឹងគ្នាពីរនាក់ ទៅហើយកាន់វត្តជេតវ័ន មួយអន្លើដោយមហាជន, កាលទៅ ដើម្បីប្រយោជន៍ដល់កិរិយាស្តាប់នូវធម៌, ចោរម្នាក់បានស្តាប់ហើយ នូវធម្មកថា ។

(សម្ពន្ធ) **ភិរ**_សព្ទ អនុស្សរនត្ថៈ, **តេ** ក្តី **ទ្វេ** ក្តី វិសេសនៈរបស់ **ចោរា**។ បកតិកត្តាក្នុង **គន្ទា**, **សហាយកា** វិកតិកត្តាក្នុង **គន្ទា**, **ធម្មស្សវនត្ថាយ** សម្បទានក្នុង **គច្ឆន្តេន**។ វិសេសនៈរបស់ **មហាជនេន**។ សហត្ថតតិយាក្នុង **សទ្ធឹ**។ កិរិយាសមវាយក្នុង **គន្ទា**, **ជេតវនំ** សម្បាបុណិយកម្មក្នុង **គន្ទា**។ កិរិយាបធានន័យ, **ឯកោ** វិសេសនៈរបស់ **ចោរោ**។ សយកត្តាក្នុង **អស្សោសិ**។ អាខ្យាត_កត្តុ., **ធម្មកថំ** អវុត្តកម្មក្នុង **អស្សោសិ** ។

## **កិរិយាបរាមាស**

សព្ទដែលមានឈ្មោះដូច្នេះ បានដល់ **យំ** និង **យស្មា** ដែលជាប់ជំពាក់ជាមួយ នឹងកិរិយាមិនមែនជាវិសេសនៈ ប្លែកតែមិនបានសំដែង អាការៈរបស់កិរិយា ឱ្យមានសេចក្តីប្លែកជាងប្រក្រតីទៅប៉ុណ្ណោះ ហើយព្រមទាំងមិនមែនជាគុណសព្ទផង ព្រោះហេតុដូច្នោះបានជាលោកហៅឈ្មោះម្យ៉ាងទៀតថា "កិរិយាបរាមាស" ។ **យំ** និង **យស្មា** ទាំងពីរសព្ទនេះ ច្រើនរៀងទុកខាងដើមប្រយោគ រៀងទុកកណ្តាលមួយៗ, វេលា ប្រែក៏ប្រែទទេៗ ទៅ, **យំ** ខ្លះប្រែថា "ព្រោះ, ឯណា" វេលាសម្ពន្ធ ចូលនឹងកិរិយាអាខ្យាត ឬ កិតកៈ ដែលជាធំក្នុងប្រយោគ នោះ ។ ឧ. **យំ មេ ភន្តេ ភគវា (ហោតិ) បព្វជ្ជំ**

**អច្ឆរាសតានំ បដិលាភាយ ភក្ខុជបានានំ, មុញ្ចាមហំ ភន្តេ ភគវន្តំ ឯតស្មា បដិស្សវា ឲ**(ប្រែ) បពិត្រព្រះអង្គដ៏ចំរើន ព្រះមានជោគ ជាអ្នកធានារបស់ខ្ញុំព្រះអង្គដើម្បីញ៉ាំងខ្ញុំព្រះអង្គ ឱ្យបានចំពោះនូវ រយនៃស្រីអប្សរទ. ប្រាំមានជើងដូចជាជើងនៃព្រាប ដោយសំដីប្ដេជ្ញា គឺបុគ្គលគប្បីធ្វើចំពោះឯណា, បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គដោះ នូវព្រះមានជោគចាកសំដីប្ដេជ្ញា គឺបុគ្គលគប្បីធ្វើចំពោះនោះ ។ **យស្មា ពុទ្ធា ឧបជ្ជមានា មហាជនំ រាគកន្តារាទីហិ តារេន្តិ, តស្មា ពុទ្ធានំ ឧប្បាទោ សុខោ ហោតិ ឲ**(ប្រែ) ព្រះពុទ្ធទាំងឡាយ កាល ទ្រង់កើតឡើង រមែងញ៉ាំងមហាជន ឱ្យឆ្លងចាកកន្តារៈទាំងឡាយ មាន រាគកន្តារៈជាដើម ព្រោះហេតុឯណា, ព្រោះហេតុនោះ ដំណើរកើត ឡើងនៃព្រះពុទ្ធទាំងឡាយ ជាសភាវៈនាំមកនូវសេចក្ដីសុខ ។

(សម្ពន្ធ) **ភន្តេ** សគារវាលបនៈ, **ភគវា** បកតិកត្តាក្នុង **ហោតិ**១ អាខ្យាត-កត្តុ., **យំ** កិរិយាបរាមាសក្នុង **ហោតិ**, **មេ** សាមិសម្ពន្ធក្នុង **បាដិភោគោ**១ វិកតិកត្តាក្នុង **ហោតិ**, **បញ្ចន្នំ** វិសេសនៈ របស់ **អច្ឆរាសតានំ**១ ឆដ្ឋីកម្មក្នុង **បដិលាភាយ**១ សម្បទានក្នុង **បាដិភោគោ**, **ភក្ខុជបានានំ** វិសេសនៈរបស់ **អច្ឆរាសតានំ**, **ភន្តេ** សគារវាលបនៈ, **អហំ** សយកត្តាក្នុង **មុញ្ចាមិ**១ អាខ្យាត-កត្តុ., **ភគវន្តំ**

អវុត្តកម្មក្នុង **មុញ្ចាមិ**, **ឯតស្មា** វិសេសនៈរបស់ **បដិសោតា**ៗ អបាទានក្នុង **មុញ្ចាមិ**, **ពុទ្ធា** ហេតុកត្តាក្នុង **តារេន្តិ**ៗ អាខ្យាតបទ-ហេតុកត្តុវាចកៈ, **យស្មា** កិរិយាបរាមាសក្នុង **តារេន្តិ**, **ឧបជ្ជមានា** អព្ភន្តរកិរិយារបស់ **ពុទ្ធា**, **មហាជនំ** ការិតកម្មក្នុង **តារេន្តិ**, **រាគកន្តារាទីហិ** អបាទានក្នុង **តារេន្តិ**, **តស្មា** ហេតុក្នុង **ឧប្បាទោ**, **ពុទ្ធានំ** សាមិសម្ពន្ធក្នុង **ឧប្បាទោ**ៗ បកតិកត្តាក្នុង **ហោតិ**ៗ អាខ្យាត-កត្តុ., **សុខោ** វិកតិកត្តាក្នុង **ហោតិ** ฯ

## កិរិយាបទ

ពាក្យថា "កិរិយាបទ" នេះមានឈ្មោះពីរយ៉ាងគឺ :

កិរិយាបទ-កម្មវាចកៈ១, កិរិយាបទ-ភាវវាចកៈ១, កិរិយាសព្ទ ដែលមាន ឈ្មោះដូច្នេះ មានពីរបទគឺ **សក្កា** និង **អលំ**, តែបំណង យកចំពោះត្រង់ដែល ប្រែជាប្រយោគកម្ម និងភាពតែប៉ុណ្ណោះ ។ បើ **សក្កា** និង **អលំ** ជាកម្មវាចកៈ ក៏ហៅបាន "កិរិយាបទ-កម្មវាចកៈ" ទៅ, បើ **សក្កា** និង **អលំ** ជាភាវវាចកៈ ក៏ហៅបាន "កិរិយាបទ-ភាវវាចកៈ" ទៅ ។ (កិរិយាបទ-កម្មវាចកៈ) ឧ. **យេន ញាណេន សក្កា សោ ( តណ្ហាទឡ្ហកី ) ទដ្ឋុំ** ฯ (ប្រែ) ជាងឈើគឺតណ្ហានោះ (គឺតថាគត) អាចដើម្បីឃើញដោយញាណឯណា ។

(សម្ពន្ធ) **សោ** វិសេសនៈរបស់ **តណ្ហាទឡ្ហកី។** វុត្តកម្មក្នុង **សក្កា។** កិរិយាបទ_កម្មវាចកៈ, **យេន** វិសេសនៈរបស់ **ញាណេន។** ករណត្ថតតិយាក្នុង **ឧដ្ឋី។** តុមត្ថសម្បទានក្នុង **សក្កា ។**

(កិរិយាបទ_ភាវវាចកៈ) ៦. **មារ តាទិសានំ សតសហស្សេ-នាបិ មម បុត្តស្ស ភយំ ឧប្បាទេតុំ** <u>**ន សក្កា**</u>**, បុត្តោ ហិ មេ អសន្តាសី វីតតណ្ហោ មហាវីរយោ មហាបញ្ញោ ។** (ប្រែ) ម្នាលមារ គឺសែននៃជនទាំងឡាយ ប្រាកដដូចជាអ្នកនោះ <u>ក៏មិនអាច</u> ដើម្បីញុាំងភ័យឱ្យកើតឡើង ដល់កូននៃតថាគតដែរ, ព្រោះថា កូននៃតថាគត អ្នកឥតមានសេចក្តីតក់ស្លុត អ្នកមានតណ្ហាទៅប្រាសហើយ អ្នកមានព្យាយាមដ៏ធំ អ្នកមានប្រាជ្ញាដ៏ច្រើន ។

(សម្ពន្ធ) **មារ** អគារវាលបនៈ, **តាទិសានំ** សាមិសម្ពន្ធក្នុង **សតសហស្សេនាបិ, សតសហស្សេន** អនភិហិតកត្តាក្នុង **សក្កា។** កិរិយាបទ_ភាវវាចកៈ **អបិ**_សព្ទ អបេក្ខត្ថៈក្នុង **សតសហស្សេន, មម** សាមិសម្ពន្ធក្នុង **បុត្តស្ស។** សម្បទានក្នុង **ឧប្បាទេតុំ, ភយំ**ការិតកម្មក្នុង **ឧប្បាទេតុំ។** តុមត្ថសម្បទានក្នុង **សក្កា, ន**_សព្ទ បដិសេធៈក្នុង

សក្កា, ហិ_សព្ព ផលជោតកៈ, បុត្តោ លិង្គត្ថៈ, មេ សាមិសម្ពន្ធក្នុង បុត្តោ, អសន្តាសី ក្តី វីតតណ្ហោ ក្តី មហាវីរយោ ក្តី មហាបញ្ញោ ក្តី វិសេសនៈរបស់ បុត្តោ ។

សក្កា ចុះក្នុងអត្ថ ៣ យ៉ាងគឺ ៈ

១_សយកត្ថា "វីកិរិយា គឺ...អាច" ឧ. តត្ថ (ឋានេ) នំ (រាជានំ) អាគតំ គហេតុំ (តុម្ហេហិ) សក្កា ភវិស្សតិ ។

២_ទិកតិកត្ថា "ជា" ឧ. យថា (តំ ទានំ កេនចិ) ន សក្កា ហោតិ ។បេ។ ឥតិ វត្តុំ ឯវំ ទានំ សង្ខ្យឹសុ ។

៣_កិរិយាបទ "អាច" ភាវវាចកៈ ឧ. (មយា) សក្កា នុ ខោ ឥមេ ( ភិក្ខូ ) ភិន្ទិតុំ ។

កម្មវាចកៈ ឧ. ធនំ នាម (កេនចិ) សក្កា ឧប្បាទេតុំ ។ ពុទ្ធា ច នាម ន សក្កា សថេន អារាធេតុំ ។

អលំ ចុះក្នុងអត្ថ ៤ យ៉ាងគឺ ៈ

១. បដិសេធលិង្គត្ថ "វីកុំឡើយ, ល្មមហើយ" ឧ. អលំ មហារាជា ។

២. វិសេសនៈ "គួរ, ល្មម" ឧ. សុវណ្ណបព្វតស្ស ឧត្វាបិ ន អលំ ឯកស្ស ។

៣. វិកតិកត្តា "ជា" ឧ. តំ (ធនំ) មេ ឯកស្ស អត្តភាវេ ជីវិតវុត្តិយា ន អលំ (ហោតិ) ฯ

៤. កិរិយាបទ " គួរ, អាច, ល្មម " ភាវវាចក: ឧ. ថេរេន អលំ ភាតុំ ฯ កម្មវាចក: ឧ. នវហិ ភិក្ខវេ អង្គេហិ សមន្នាគតំ កុលំ (ភិក្ខុនា) អនុបគន្ត្វា ឧបគន្តុំ ន អលំ ฯ

ឯវំ_សព្ទ មានអត្ថ ៥ យ៉ាងគឺ :

១. សច្ចវាចក លិង្គត្ថ: " រឺយ៉ាងហ្នឹង " ឧ. ឯវំ ភិក្ខវេ ? ឯវំ ភន្តេ ฯ

២. កិរិយាវិសេសនៈ "យ៉ាងនោះ" ឧ. មយំ ឥទានិ ឯវំ ន ករិស្សាម ฯ

៣. នាមវិសេសនៈ "យ៉ាងនោះ, យ៉ាងនេះ" ឧ. ឯវំ (ភាវេ, វចនេ) ការណេ វុត្តេ ฯ

៤. បការត្ថៈ "ដោយបការៈដូច្នោះ" ឧ. ឯវំ ឥមា (ឥត្ថិយោ) អប្បមាទវិហារិនិយោ ភវិស្សន្តិ ฯ

៥. ឧបមេយ្យជោតក "យ៉ាងនោះ, ដូច្នោះ" ឧ. ឯវំ តុម្ហេ ហិ អាតាបិនោ សំវេគិនោ ភវេយ្យាថ ฯ ឧ. យថា ទណ្ឌេន គោបាលោ គាវោ បាជេតិ គោចរំ ឯវំ ជរា ច មច្ចុ

ច អាយុំ បាចេន្តិ បាណិនំ ។

ឥថា មានអត្ថ ៥ យ៉ាងគឺ :

១. លិង្គត្ថៈ និង វិវរណៈ " វីយ៉ាងនោះ" ឧ. មហារាជ មនុស្សត្តំ នាម ទុល្លភំ ឯវ (ហោតិ) ឥថា សទ្ធម្មស្សវនំ (ទុល្លភំ ហោតិ) ។

២. កិរិយាវិសេសនៈ " យ៉ាងនោះ, ដូច្នោះ " ឧ. សា (ឥត្ថី) បន ។បេ។ ឥតិ (ចិន្តេនេន) ឥថា អកាសិ ។

៣. បការត្ថៈ "ដោយបការៈដូច្នោះ, នោះ" ឧ. យថា (ឥមេ សត្តា សាវកា) ឥមំ គេហំ ន បវិសន្តិ ឥថា គហបតឹ បរិភិន្ទិស្សាមិ ។

៤. សម្បិណ្ឌនត្ថៈ " ម្យ៉ាងវិញទៀត "

៥. ឧបមេយ្យជោតកៈ "ដូច្នេះ" ឧ. យថា អហំ (ឧណ្ហស្ស តសាមិ) ឥថា អញ្ញេបិ (សត្តា) ឧណ្ហស្ស តសន្តិ ។

ឥតិ_សព្ទ ចុះក្នុងអត្ថ ៨ យ៉ាងគឺ :

១. អាការត្ថៈ "ដូច្នេះ" សម្ពន្ធចូលនិងកិរិយា ឱ."ឥធ វស្សំ វសិស្សាមិ ឥធ ហេមន្តគិម្ហីសុ" ឥតិ ពាលោ វិចិន្តេតិ អន្តរាយំ ន ពុជ្ឈតិ ។

២. **សរូបៈ** "គឺ ឬដូច្នេះ" សម្ពន្ធចូលនិងបទនាម ឧ. **មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទន្តិ អយំ ធម្មទេសនា ភត្ត ភាសិតា ។**

៣. **អាទ្យត្ថៈ** " មានបទថា ដូច្នេះជាដើម " ឧ. **អក្កោច្ឆិ មំ អវធិ មន្តិ ឥមំ ធម្មទេសនំ សត្ថា ជេតវនេ វិហរន្តោ តិស្សត្ថេរំ អារព្ភ កថេសិ ។**

៤. **និទស្សនៈ** "ព្រោះហេតុដូច្នោះ" រៀងខាងដើមប្រយោគ ប្រែក្រោយបង្អស់ ឧ. **ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ (ហោតិ) ។**

៥. **ហេត្វត្ថៈ** "ព្រោះហេតុដូច្នោះ" សម្ពន្ធវិគ្គហៈ ឧ. **សហ ភរិយាយ យោ វត្តតីតិ សភរិយោ (បុរិសោ) ។**

៦. **បការៈ** "ដោយបការៈដូច្នេះ" ឧ. **ឥតិ យន្តំ ឥទមេតំ បដិច្ច វុត្តំ ។**

៧. **សមាបន្នៈ** "ដូច្នេះឯង" រៀងចុងបញ្ចប់សេចក្តី ឧ. **សម្បត្តបរិសាយបិ ទេសនា សាត្ថិកា សផលា អហោសីតិ ។**

៨. **សញ្ញាជោតកៈ** "ឈ្មោះ" ប្រើជំនួសនាមសព្ទ ឧ. **សិន្ធវាតិ**

សិន្ធុទរដ្ឋេ ជាតា អស្សា ៗ

ឧបមាជោតកៈ និង ឧបមេយ្យជោតកៈ ឧបមាមាននិបាត ៤ យ៉ាង យថា សេយ្យថាបិ "ដូចជា, យ៉ាងណា, យ៉ាងណាមិញ", វិយ, ឥវ "បីដូច ឬ ដូចជា, ហាក់ដូចជា, ប្រហែលដូចជា" ឧបមាជោតកៈ ៗ

ក. យថា នទី ច បន្ថោ ច បានាគារំ សភា បបា, ឯវំ លោកិត្ថិយោ នាម (ហោន្តិ) វេលា តាសំ ន វិជ្ជតិ ៗ

ខ. សេយ្យថាបិ ភិក្ខវេ យានិ កានិចិ ជង្គលានំ បាណានំ បទជាតានិ, សព្វានិ តានិ ហត្ថិបទេ សមោធានំ គច្ឆន្តិ, ហត្ថិបទំ តេសំ, អគ្គមក្ខាយតិ, យទិទំ មហន្តត្តេន, ឯវមេវ ខោ ភិក្ខវេ យេ កេចិ កុសលា ធម្មា សព្វេ តេ អប្បមាទមូលកា អប្បមាទសមោសរណា, អប្បមាទោ តេសំ ធម្មានំ អគ្គមក្ខាយតិ ៗ

គ. ថេរោ ចក្កវត្តិរញ្ញោ សន្តិកា បដិលទ្ធមហាលាភោ មហាយោធោ វិយ តុដ្ឋមានសោ សាវកបារមីញ្ញាណេ ឋត្វា បព្វជ្ជាសនានុមោទនំ អារភិ ៗ

ឃ. ឧរគោវ តចំ ជិណ្ណំ ហិត្វា គច្ឆតិ សន្តនុំ, ឯវំ សរីរេ និព្ភោគេ បេតេ កាលកតេ សតិ ៗ

វិយ, ឥវ, យថា, មានអត្ថ ៤ យ៉ាងគឺ :

១. ឧបមាលិង្គត្ថ "ដូចជា" ជាប្រយោគជ្រែក ក្នុងប្រយោគធំ ត្រូវប្រែរូប ឧ. មម ទ្វេ បុត្តា អគ្គិក្ខន្ធា វិយ ជលន្តា វិចរន្តិ ។

២. ឧបមាវិសេសនៈ ឧ. ឥតិ អស្ស ពលវមច្ឆេរំ ពន្ធិត្វា គណ្ហន្តំ វិយ សទ្ធាចិត្តំ បដិពាហតិយេវ ។

៣. ឧបមាវិកតិកត្តា ឧ. ថេរស្ស សរីរំ ឧក្កាហិ អាទិត្តំ វិយ អហោសិ ។

៤. ឧបមាវិកតិអវុត្តកម្មៈ ឧ. បក្ខន្ទិនាតិ បក្ខន្ទនាទិនា បរេសំ (ជនានំ) កច្ចានិ អត្តនោ កិច្ចានិ វិយ (កត្វា ឧស្សេន្តេនាតិ) (អត្តោ) ។

ឧបមាវិសេសនៈ ឧ. ឥមេ ( ធុត្តកា ) ពុទ្ធសាសនំ បរិគ្គណ្ហន្តា វិយ វទន្តិ ។ សោ ឧប្បន្នទោមនស្សោ បព្វតេន វិយ សោកទុក្ខេន អជ្ឈោត្ថដោ អហោសិ ។ អហំ មាតរិ មតាយ មាតរំ វិយ បិតរិ មតេ បិតរំ វិយ តុម្ហេ អលត្ថំ ។

វិកតិកត្តា បទវិកតិកត្តានេះ រៀងជិតកិរិយាដែល ប្រែថា "ជា" គឺ ភូ, ហុ, អស, ជន_ធាតុ ណាមួយក្នុង កត្តុវាចកៈ និងហេតុកត្តុ_វាចកៈមានរូបជាបឋមាវិភត្តិ, ក្នុងកម្មវាចកៈ និងភាវ_

វាចកៈ មានរូប ជាតតិយាវិភត្តិ ។ ឧ. ន ភិក្ខវេ ឥទានេវ អហំ ឥមេសំ បច្ចយោ ច បតិដ្ឋា ច ជាតោ តស្មា អញ្ញេនបិ អត្តនត្ថសទិសេន ភវិតព្វំ ។

ឧបមាវិកតិកត្តា វិកតិកត្តាដែលមាន ឥវ ឬ វិយ-សព្ទ រូបជាមួយអាចប្រើកិរិយាសព្ទ ត្វា ឬ តុំ ក៏បាន ។ ឧ. សោ តាវទេវ អដ្ឋបរិក្ខារធរោ សដ្ឋិវស្សត្ថេរោ វិយ អហោសិ តេន អត្តនត្ថេរេន វិយ ភវិតុំ វដ្ដតិ ។

## វិកតិអវុត្តកម្ម (កត្តុ.)

ឧ. សបុត្តទារំ មំ តវ គេហេ ទាសំ ករោហិ អថ សត្ថា តំ ព្យាធិនា អភូតំ កត្វា ទស្សេសិ ។

ឧបមាវិកតិអវុត្តកម្ម ឧ. ឯកោ តេន កតំ វត្តំ អត្តនា កតំ វិយ (កត្វា) ទស្សេន្តោ មុខោទកទន្តកដ្ឋានំ បដិយាទិតភាវំ ញត្វា វទតិ ។

## វិកតិវុត្តកម្ម (កម្មវាចកៈ)

ឧ. (កុក្កុដមិត្តោ) បាណាតិបាតកម្មស្ស វោ ភន្តេ អការកោ កតោ។ ឥទំ សរីរំ កម្មេន អដ្ឋីនំ នគរំ កតំ មំសលោហិតលេបនំ ។

## ប្រយោគពិសេស

ប្រយោគនេះហៅតាមលក្ខណៈនៃការប្រែចែកជាប្រយោគធំៗ ៥ យ៉ាងគឺ :

### ១-កាកោលោកន័យ

នេះជាឈ្មោះវិសេសរបស់ប្រយោគមិនមែនជាឈ្មោះ សម្ពន្ធទេ គឺក្នុងប្រយោគនេះ បទតែមួយ ត្រូវប្រែពីរដង ហៅថា **កាកោ-លោកន័យ** មានន័យដូចការ ក្រឡេកមើលរបស់ក្អែក ។

សេចក្តីថាកាលបើក្អែកហើរទៅទំទីណាហើយ តែងបែរត្រឡប់មើលផ្លូវដែលខ្លួនហើរមកម្តងទៀត ឯប្រយោគបាលីក៏មានន័យដូច្នោះដែរ គឺប្រែបទណាម្តងហើយក៏ប្រែបទដទៃ ទើបត្រឡប់មកបទនោះម្តងទៀត មានន័យដូចការក្រឡេកមើលរបស់ក្អែក កាកោលោកន័យ ។

ឧ. **ចន្ទសុរិយេហិ មេ អត្ថោ តេ មេ ទេហីតិ យាចិតោ ។**

(ប្រែ ) **អត្ថោ** វីសេចក្តីត្រូវការ **ចន្ទសុរិយេហិ** ដោយព្រះចន្ទ និងព្រះអាទិត្យទ. **មេ** របស់ខ្ញុំ, **ត្វំ** វីលោក <u>**មេ**</u> គឺខ្ញុំ **យាចិតោ** សុំហើយ **ទេហិ** ចូរអោយ **តេ** (**ចន្ទសុរិយេ** នូវ...ទ.) នោះ <u>**មេ**</u> ដល់ខ្ញុំ ។

**មេ** ក្នុងទីនេះត្រូវប្រែ ២ វិភត្តិគឺ តតិយា និងចតុត្ថីហើយសម្ពន្ធ

២ ឈ្មោះគឺ ជាអនភិហិតកត្តាក្នុង **យាចិតោ** និងជាសម្បទានៈក្នុង **ទេហិ ។**

**កេន លោកោ តមោ ភូតោ តំ មេ អក្ខាហិ បុច្ឆិតោ ។**

**២_នាគសោណ្ឌិ**

ប្រែថា ប្រមោយដំរី (ដំរីយោលដៃ) នេះជាឈ្មោះ ប្រយោគ ដែលប្រែរួចម្តងហើយ ត្រូវវិលត្រឡប់មក ប្រែម្តងទៀតដូចប្រមោយដំរី តែងមូរចូលមករកខ្លួនជានិច្ច មិនលាតត្រង់ទៅមុខទេ ជាប្រយោគ បញ្ជាក់ហេតុផល ត្រូវតាំងជាប្រយោគ **យស្មា តស្មា** ប្រែទទួល ហេតុផលនៃគ្នា និងគ្នា ឧទាហរណ៍ :

**អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ ។** (ប្រែ) **សង្ខារា** វី... **អនិច្ចា វត** មិនទៀង ទេហ្ន៎, **សង្ខារា** វី... **ឧប្បាទវយធម្មិនោ** មានការកើតឡើងនិងការ សូន្យទៅជាធម្មតា (**យស្មា** ព្រោះហេតុណា **តស្មា** ព្រោះហេតុនោះ) **សង្ខារា** វី... **អនិច្ចា វត...** ។ **សង្ខារា** វី... **ឧប្បជ្ជិត្វា** កើតឡើងហើយ **និរុជ្ឈន្តិ** រលត់ទៅវិញ (**យស្មា... តស្មា** ....) **សង្ខារា** វី.... **ឧប្បាទវយធម្មិនោ** មាន....។ **វូបសមោ** វីកិរិយា ចូលទៅរំងាប់ **តេសំ សង្ខារានំ** ...នៃ..ទ. នោះ **សុខោ** ជាសុខ ។

## ៣_នាគពាធ

នេះជាឈ្មោះ **ឥតិ**_សព្ទ ដែលសម្ពន្ធថា សរុប ឬអាការ នោះឯងដែលលោករៀងទុកខុសធម្មតា គឺតាមធម្មតា **ឥតិ**_សព្ទ នេះត្រូវរៀងទុកត្រង់ទីបំផុត សេចក្ដីនៃវគ្គមួយៗ តែក្នុងគាថានេះ លោករៀងទុកខាង ក្នុងសេចក្ដីទៅវិញ ដើម្បីរក្សាឆន្ទ ជាដើម, ប៉ុន្តែ សូម្បីលោករៀងទុកក្នុងវគ្គកណ្ដាលដូច្នេះក៏ដោយក៏នៅតែផ្ទុក សេចក្ដីបានទាំងអស់ សូមមើលឧទាហរណ៍ តទៅនេះ ។

**ចន្ទសុរិយេហិ មេ អន្តោ តេ មេ ទេហីតិ យាចិតោ**

(ប្រែ) **មាណវោ** រី... **អាហ**... **ចន្ទសុរិយេហិ មេ អន្តោ តេ មេ ទេហិ យាចិតោ ឥតិ** ថាដូច្នេះ "**អន្តោ** រី... **ចន្ទសុរិយេហិ** ដោយ...។ ល ។ **តេ ចន្ទសុរិយេ** នូវ... **មេ** ដល់ខ្ញុំ ។

**ឥតិ**_សព្ទ ដែលលោករៀងទុកខាងក្នុងដូច្នេះ រមែងផ្ទុកសេចក្ដីបានទាំងខាងមុខទាំងខាងក្រោយដោយជុំវិញ មានអាការដូចការរឹតរួតនៃពស់ ព្រោះវា រុំព័ទ្ធចំណី ជុំវិញហេតុនោះទើបលោកហៅថា **នាគពាធ** "ការបៀតបៀននៃនាគ " ជាឈ្មោះប្រយោគ បែបនេះឯង ។

## ៤_អដ្ឋានសម្បយុត្ត

ពាក្យនេះជាឈ្មោះរបស់ **ចិ**_សព្ទ ដែលលោករៀងទុកក្នុងកន្លែង

មួយ វេលាប្រែត្រូវទាញទៅដាក់កន្លែងមួយទៀតដោយ ប្រកាន់យកសេចក្ដីដែលខ្លួន គួរប្រកបចូលក្នុងទីនោះនិងរក្សាទុកឱ្យ នៅកន្លែងដើមពុំបាន ដូចជា **ទុត្តម្បិ ចេតំ** វេលាប្រែ ត្រូវទាញ **បិ** ទៅភ្ជាប់និង **ឯតំ** ទៅជា **ទុត្តំ ច ឯតំបិ** ។ **បិ** ក្នុងទីនេះ ត្រូវសម្ពន្ធថា អបេក្ខត្ថក្នុង **ឯតំ** ប្រែថា **ច** ក៏ **ឯតំបិ វចនំ** វីពាក្យសូម្បីនេះ **ភគវតា** គឺ... **ទុត្តំ** ត្រាស់ហើយ ។

## ៥.ពេយ្យាល

ពាក្យនេះ សម្រាប់ហៅប្រយោគបាលីដែលកាត់ខ្លីដើម្បីកាត់ចោលបទដដែលៗ ជាពាក្យដែលលោករៀងទុក ក្នុងវគ្គមុន និងវគ្គក្រោយ ឯវគ្គកណ្ដាលលោកកាត់ចេញហើយដាក់ "។បេ។" ឬ "។ល។" ជំនួសវិញ ជាសញ្ញាប្រាប់ថា ចាប់ពីនេះដល់នោះនឹងមានសេចក្ដី ដូចគ្នា វេលាប្រែត្រូវដាក់បំពេញឱ្យដូចគ្នា ដូចប្រយោគថា " **ថេរោ ន ខ្វាហំ ភន្តេ ឯត្ថ ភគវតោ សទ្ធាយ គច្ឆាមិ, សទ្ធិន្ទ្រិយំ ។បេ។ អមតបរិយោសានំ យេសំ ន្ហនេតំ ភន្តេ អញ្ញាតំ អសុតំ អទិដ្ឋំ អវិទិតំ អសច្ឆិកតំ អផុសិតំ បញ្ញាយ តេ តត្ថ បរេសំ សទ្ធាយ គច្ឆេយ្យុំ ។ សទ្ធិន្ទ្រិយំ ។បេ។ អមតបរិយោ-សានន្តិ ឯវន្តំ បញ្ហំ ព្យាកាសិ ។** (ធម្មបទ ភាគ៤ សារីបុត្តត្ថេរ

វត្ថុ) នេះជាប្រយោគ បេយ្យាល ព្រោះ លោកកាត់ ចោលបទដដែលៗ ត្រង់កណ្ដាលចេញហើយដាក់ ។បេ។ ជំនួសវិញ ។ ប្រយោគពេញត្រូវមាន **សទ្ធិន្ទ្រិយំ (ភាវិតំ ពហុលីកតំ អមតោគធំ ហោតិ) អមតបរិយោសានំ** ក្នុងប្រយោគនេះបើប្រែឱ្យពេញត្រូវដាក់បញ្ចូល ៥ ដង តាមឥន្ទ្រីយ៍ ៥ គឺ **វីរិយិន្ទ្រិយំ** ។បេ។ **សតិន្ទ្រិយំ** ។បេ។ **សមាធិន្ទ្រិយំ** ។បេ។ **បញ្ញិន្ទ្រិយំ** ។បេ។ ដូច **សទ្ធិន្ទ្រិយំ** ខ

ម្យ៉ាងទៀត ទោះបីប្រយោគមិនមាន "។បេ។" ឬ "។ល។" ក៏ដោយ តែប្រយោគដែលស្រដៀងគ្នានេះវេលា ប្រែត្រូវបញ្ចូលមកដោយខ្លួនឯង ក៏ហៅថា **បេយ្យាល** ដូចគ្នា ។

**ប្រយោគតាមបាលីវេយ្យាករណ៍ មាន ៥ គឺ :**

១. ប្រយោគ កត្តុវាចក:

២. ប្រយោគ កម្មវាចក:

៣. ប្រយោគ ហេតុកត្តុវាចក:

៤. ប្រយោគ ហេតុកម្មវាចក:

៥. ប្រយោគ ភាវវាចក:

**ប្រយោគតាមវិធីសម្ពន្ធមាន ៦ យ៉ាងគឺ :**

១. ប្រយោគ លិង្គត្ថ:

២. ប្រយោគ ឥត្ថម្ភូតៈ

៣. ប្រយោគ អនាទរៈ

៤. ប្រយោគ លក្ខណៈ

៥. ប្រយោគ កិរិយាបធានន័យ

៦. ប្រយោគ កិរិយាបរាមាសៈ

**ប្រយោគតាមលក្ខណៈនៃការប្រែមាន ៥ យ៉ាងគឺ ៈ**

១. ប្រយោគ កាកោលោកន័យ

២. ប្រយោគ នាគសោណ្ឌិ

៣. ប្រយោគ នាគពាធៈ

៤. ប្រយោគ អឌ្ឍានសម្បយុត្តៈ

៥. ប្រយោគ បេយ្យាលៈ

# ចប់បែបរៀនភាសាបាលី

# ភាគទី ៣

**ចិរំ  តិដ្ឋតុ  ពុទ្ធសាសនំ**

សូមពុទ្ធសាសនា  ឋិតថេរយូរយារ

រុងរឿងថ្លៃថ្លា  អង្វែងទៅហោង ។

វត្តដំរីស,ថ្ងៃទី ៣១ ខែមករា ឆ្នាំ ព.ស ២៥៥០ / គ.ស ២០០៦

គ្រូបង្រៀនភាសាបាលី អាយុ ៨០ ឆ្នាំ

**ច្រាក់ ឃុន**